switchasia

Funded by the European Union

# ករណីសិក្សាអំពីលទ្ធកម្ម សាធារណៈប្រកបដោយ និរន្តរភាពនៅកម្ពុជា











# ការថ្លែងអំណរគុណ

ករណីសិក្សាអំពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅកម្ពុជា (Cambodia's Sustainable Public Procurement) ត្រូវបានរៀបចំដោយ EU SWITCH-Asia សមាសភាគគាំទ្រគោលនយោបាយ ដែលមានលោក ទេព គន្ធារ៉ា ជំនាញការជាតិ ជាអ្នកធ្វើការសិក្សានេះដោយផ្ទាល់ និងមានការគាំទ្របច្ចេកទេសពីសំណាក់លោកស្រី Elodie Maria-Sube អ្នកសម្របសម្រួលគម្រោង, លោក Sanjay Kumar អ្នកជំនាញជាន់ខ្ពស់, លោកស្រី Sylvie Zaitra អ្នកជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលោកស្រីបណ្ឌិត Zinaida Fadeeva ប្រធានក្រុមការងារ SWITCH-Asia សមាសភាគគាំទ្រគោលនយោបាយ។

ក្រុមអ្នកជំនាញសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍, ធនាគារពិភពលោក, អភិវឌ្ឍន៍អាស៊ី, អង្គការ GIZ Cambodia, សភាពាណិជ្ជកម្មសហភាពអឺរ៉ុបនៅកម្ពុជា (EUROCHAM) និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងករណីសិក្សានេះ។ យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរួមចំណែកដ៏មានតម្លៃរបស់ក្រសួង និងតួអង្គពាក់ព័ន្ធទាំងអស់ ក្នុងការរចនារៀបចំការវាយតម្លៃ និងការចូលរួមរបស់ពួកគេ នៅក្នុងដំណើរការវាយតម្លៃតាំងពីដើមដល់ចប់។

យើងសូមថ្លែងអំណរគុណយ៉ាងស្មោះអស់ពីដួងចិត្តផងដែរ ចំពោះអ្នកទាំងអស់ ដែលបានចូលរួមដោយទឹកចិត្តសប្បុរស ក្នុងការឆ្លុះបញ្ចាំង និងផ្តល់ការយល់ដឹងស៊ីជម្រៅរបស់ខ្លួន សម្រាប់របាយការណ៍មួយនេះ។ ឆន្ទៈរបស់ពួកគេក្នុងការចែករំលែកបទពិសោធន៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការឈានទៅបង្កើតបានរបាយការណ៍នេះ។ យើងសូមទទួលយកទស្សនៈទាំងឡាយ និងអរគុណចំពោះពេលវេលាដ៏មានតម្លៃ និងការខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធ ដើម្បីជាប្រយោជន៍ដើម្បីបង្កើនការយល់ដឹងរបស់យើងខ្ញុំ អំពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅប្រទេសកម្ពុជា និងនៅក្នុងតំបន់។

យើងខ្ញុំជឿជាក់ថា ករណីសិក្សានេះ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវទស្សនៈ និងការយល់ដឹងស៊ីជម្រៅរបស់អ្នកពាក់ព័ន្ធទាំងអស់ ហើយថា គំហើញសំខាន់ៗនៅក្នុងការសិក្សានេះ មានភាពស្របតាមការយល់ឃើញ ចំណាប់អារម្មណ៍ ការចូលរួម និងបទពិសោធន៍របស់ពួកគេ នៅក្នុងការជំរុញ និងបន្តការអនុវត្ត SPP តាមរយៈកិច្ចសហការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ក្រុមអ្នកជំនាញរបស់ SWITH-Asia សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ជាពិសេសប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា ដែលបានផ្តល់ការគាំទ្រយ៉ាងវិសេសវិសាល និងជាតុចូលសំខាន់ៗ ក្នុងការសម្របសម្រួលរហូតដល់បង្កើតបានរបាយការណ៍នេះ។

ក្រុមអ្នកជំនាញបានខិតខំយកអស់លទ្ធភាពក្នុងការធានាឱ្យបាននូវគុណភាពនៅក្នុងរបាយការណ៍នេះ ហើយនឹងទទួលខុសត្រូវទាំងស្រុងចំពោះកំហុសទាំងឡាយ ប្រសិនបើមាន ដោយសារការខ្វះចន្លោះណាមួយ។


**រៀបរៀងដោយ៖**

លោក ទេព គន្ធារ៉ា

**ពិនិត្យដោយ៖**

លោកស្រី Elodie Maria-Sube
លោក Sanjay Kumar

**យល់ព្រម ដោយ៖**

លោកស្រីបណ្ឌិត Zinaida Fadeeva
ប្រធានក្រុមការងារ

Funded by
the European Union

**The SWITCH-Asia Programme**

© 2024 SWITCH-Asia

## ការបដិសេធទទួលខុសត្រូវ

ព័ត៌មាន និងមាតិកានៅក្នុងឯកសារនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមអ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈយល់ឃើញរបស់សហភាពអឺរ៉ុបឡើយ។

# មាតិកា


អក្សរកាត់ ........ 5
សង្ខេបអំពីរបាយការណ៍ ........ 7
**ជំពូក ១. សេចក្តីផ្តើម ........ 9**
១.១ សាវតារ ........ 9
១.២ គោលបំណង ........ 10
១.៣ អភិក្រម និងវិធីសាស្ត្រ ........ 10
១.៤ បញ្ហាប្រឈម ........ 12
**ជំពូក ២. ទិដ្ឋភាពទូទៅស្តីពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ........ 13**
២.១ បញ្ហាសង្គម ........ 13
២.២ បញ្ហាបរិស្ថាន ........ 14
២.៣ ការប្រើប្រាស់គ្មាននិរន្តរភាព ........ 15
២.៤ ទិដ្ឋភាពសេដ្ឋកិច្ចសង្គមក្នុងវិស័យកសិ-ស្បៀងអាហារនៅកម្ពុជា ........ 16
២.៥ បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ........ 16
**ជំពូក ៣. ទិដ្ឋភាពរួមផ្នែកគោលនយោបាយ និងការវិភាគ ........ 18**
៣.១ ក្របខ័ណ្ឌគោលនយោបាយសម្រាប់ SPP ........ 18
៣.២ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌច្បាប់ជាតិ ........ 24
**ជំពូកទី៤៖ ឧត្តមានុវត្តន៍ និងមេរៀនដកបទពិសោធន៍ ........ 27**
៤.១ ការពិភាក្សាអំពីគំហើញ ........ 27
ផ្នែកសំខាន់ទី១៖ ក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រង ........ 27
ផ្នែកសំខាន់ទី២៖ ការធ្វើសមាហរណកម្មគោលការណ៍លទ្ធកម្មដោយនិរន្តរភាព ទៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:27
ផ្នែកសំខាន់ទី៣៖ ស្ថាប័នទទួលការចាត់តាំងឱ្យបង្កើត និងអនុវត្តលទ្ធកម្មសាធារណៈបៃតង ........ 28
ផ្នែកសំខាន់ទី៤៖ យន្តការ SPP និង SCP បច្ចុប្បន្ន ........ 30
ផ្នែកសំខាន់ទី៥៖ ការយល់ដឹង និងការកសាងសមត្ថភាពg ........ 30
៤.២ សហគមន៍សកល និងវិស័យឯកជន ........ 31
**ជំពូក ៥. សេចក្តីសន្និដ្ឋាន ........ 33**
**ជំពូក ៦. អនុសាសន៍សម្រាប់ធ្វើសកម្មភាព ........ 34**
៦.១ មេរៀនដកពិសោធន៍សំខាន់ៗ៖ ........ 34
៦.២ អនុសាសន៍ ........ 34
ឧបសម្ព័ន្ធ ក. ម៉ាទ្រីសសម្រាប់វិភាគកត្តានយោបាយ សេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា (PEST) ........ 36
ឧបសម្ព័ន្ធ ខ. បញ្ជីឈ្មោះស្ថាប័ន/ទីភ្នាក់ងារ ដែលបានជួបពិគ្រោះយោបល់ ........ 38
ឧបសម្ព័ន្ធ គ. បញ្ជីសំណួរ ........ 40
ឯកសារយោង ........ 43

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CCCSP | ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា |
| CE | សេដ្ឋកិច្ចចក្រា |
| CSDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| CSOs | អង្គការសង្គមស៊ីវិល |
| DGE | នាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| DPs | ដៃគូអភិវឌ្ឍន៍ |
| ENR Code | ក្រមបរិស្ថាននិងធនធានធម្មជាតិ ឆ្នាំ២០២៣ |
| EU Delegation | ប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា |
| EUROCHAM | សភាពាណិជ្ជកម្មសហភាពអឺរ៉ុប |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GDPP | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GIZ | សាជីវកម្មអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| HEF | មូលនិធិសមធម៌សុខាភិបាល |
| IDP | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ |
| ID-Poor program | កម្មវិធីកំណត់អត្តសញ្ញាណជនក្រីក្រ |
| ISC | វិទ្យាស្ថានស្តង់ដារកម្ពុជា (ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) |
| KII | ជនផ្តល់សម្ភាសគោល |
| MAPS | វិធីសាស្ត្រសម្រាប់វាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOE | ក្រសួងបរិស្ថាន |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយមy |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |

| | |
|---|---|
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NGGP | គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង |
| PEST | កត្តានយោបាយ សេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា |
| PFM/RP | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (កម្មវិធីកំណែទម្រង់) |
| PIM | សៀវភៅស្តីពីគោលការណ៍នាំការអនុវត្តគម្រោង |
| PP Law | ច្បាប់ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣ |
| PPP Law | ច្បាប់ស្តីពីភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន |
| PSC | សមាសភាគទ្រទ្រង់គោលនយោបាយ |
| PS-PI | យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS-IV | យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ |
| SCP | ការប្រើប្រាស់ និងការផលិតប្រកបដោយនិរន្តរភាព |
| SNAs | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SPP | លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព |
| TWG | ក្រុមការងារបច្ចេកទេស |
| USD | ដុល្លារអាមេរិក |
| WB | ធនាគារពិភពលោក |

# សង្ខេបអំពីរបាយការណ៍

សេចក្តីសង្ខេបនេះ រៀបរាប់អំពីទិដ្ឋភាពរួមស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅកម្ពុជា។ នៅក្នុងនេះ វារំលេចឡើងនូវកិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដើម្បីបញ្ចូលការគិតគូរអំពីនិរន្តរភាពទៅក្នុងដំណើរការលទ្ធកម្មសាធារណៈ សំដៅលើកកម្ពស់ SCP និងឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិរបស់កម្ពុជាឱ្យបានទូលំទូលាយ។ ជាផ្នែកមួយនៃករណីសិក្សាសម្រាប់កម្ពុជា សេចក្តីសង្ខេបនេះបង្ហាញជូនពីស្ថានភាពបច្ចុប្បន្ន គំនិតផ្តួចផ្តើមសំខាន់ៗ បញ្ហាប្រឈម និងអនុសាសន៍មួយចំនួន សម្រាប់ជំរុញ SPP និង SCP នាពេលខាងមុខ។

មួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃ SCP និង SPP ដើម្បីរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ មានកិច្ចខិតខំជាច្រើនត្រូវបានធ្វើឡើងក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដើម្បីគាំទ្រការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាក្រសួងដែលទទួលខុសត្រូវសំខាន់សម្រាប់ការលើកកម្ពស់ការអនុវត្ត SPP ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិសំខាន់ៗ ដូចជា GIZ, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា និងកម្មវិធីតំបន់ឈ្មោះ SWITCH Asia ក្រោមការគាំទ្រថវិកាដោយសហភាពអឺរ៉ុប។ សកម្មភាពកសាងសមត្ថភាព និងគម្រោងសាកល្បងតាមវិស័យជាក់លាក់ (ឧ. ស្លាកមេត្រីបរិស្ថាន) ក៏ត្រូវបានធ្វើឡើងផងដែរ ដើម្បីជាស់តឿនភាគីពាក់ព័ន្ធអំពីសារៈសំខាន់នៃក្របខ័ណ្ឌគោលនយោបាយ និងវិធានចាំបាច់ទាំងឡាយ សម្រាប់លើកកម្ពស់ SCP/SPP នៅកម្ពុជា រួមជាមួយនឹងផែនទីចង្អុលផ្លូវ និងអនុក្រឹត្យស្តីពី SCP ដែលបានរៀបចំជាសេចក្តីព្រាងរួចហើយ។

បច្ចុប្បន្ននេះ គំនិតផ្តួចផ្តើមមួយចំនួនដែលកំពុងត្រូវបានអនុវត្ត និង/ឬមាននៅក្នុងគ្រោងផែនការរួចហើយ ដើម្បីបង្កើតភាពជាដៃគូក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធ សម្រាប់គាំទ្រដល់ SPP និង SCP នៅកម្ពុជា។ គម្រោងសហការក្នុងចំណោមដៃគូអភិវឌ្ឍន៍ ដូចជា GIZ, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និង EU-SWITCH Asia ជាដើម នឹងផ្តោតខ្លាំងទៅលើការកសាងសមត្ថភាព ការអភិវឌ្ឍស្ថាប័ន និងការដាក់បញ្ចូលស្តង់ដារបរិស្ថាន និងបច្ចេកវិទ្យានវានុវត្តន៍ទៅក្នុង SCP, SPP និងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងមូល។ វិធីសាស្ត្រសម្រាប់វាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ (MAPS) ត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកកំពុងធ្វើការសិក្សា ដោយក្នុងនោះ ធនាគារពិភពលោកបានសង្កត់ធ្ងន់លើលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងធ្វើការវាយតម្លៃអំពីការត្រៀមលក្ខណៈរបស់កម្ពុជាសម្រាប់ទទួលយកប្រព័ន្ធនេះ។

ថ្វីត្បិតតែមានវឌ្ឍនភាពខ្លះក៏ដោយ ក៏គេនៅតែសង្កេតឃើញថានៅមានបញ្ហាប្រឈមជាច្រើន ដែលបន្តរាំងការរីកចម្រើនរបស់ SPP និង SCP នៅកម្ពុជា។ នៅក្នុងនោះមាន ការផ្សព្វផ្សាយ និងការយល់ដឹងអំពីសារៈសំខាន់នៃទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាពនៅមានកម្រិតតិចតួច, កង្វះសមត្ថភាព និងភាពចាំបាច់មានគោលនយោបាយ និក្របខណ្ឌច្បាប់គ្រប់ជ្រុងជ្រោយ។ លើសពីនេះទៀត ការតម្រឹម SPP ឱ្យស្របតាមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតាមវិស័យនានា នៅតែជាបញ្ហាប្រឈមនៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីជំរុញ SPP និង SCP ឱ្យជឿនលឿនទៅមុខ របាយការណ៍នេះបានស្នើអនុសាសន៍មួយចំនួនដូចខាងក្រោមសម្រាប់យកទៅអនុវត្ត៖

១. គាំទ្រដល់ការបង្កើតវិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំ សម្រាប់លទ្ធកម្មប្រកបដោយនិរន្តរភាព រួមទាំងអនុក្រឹត្យផងដែរ ដែលជាបុរេលក្ខខណ្ឌសម្រាប់ SPP និងនីតិវិធីលម្អិត សម្រាប់ផ្សារភ្ជាប់ SPP ជាមួយការសិក្សាដែលកំពុងដំណើរការរៀបចំប្រព័ន្ធលទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិករបស់រាជរដ្ឋាភិបាល (e-GP) ដែលកិច្ចការទាំងអស់នេះ គឺជាផ្នែកមួយនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

២. រៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេស ដែលមានបរិបទស្រដៀងគ្នាជាមួយកម្ពុជា ដើម្បីស្វែងយល់ស៊ីជម្រៅ និងដកស្រង់បទពិសោធន៍ដ៏មានតម្លៃស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រកបដោយនិរន្តរភាព។ ពង្រឹងកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់មន្ត្រីរាជរដ្ឋាភិបាល និងអ្នកអនុវត្តកិច្ចលទ្ធកម្ម ដើម្បីបង្កើនចំណេះដឹង និងជំនាញក្នុងការធ្វើលទ្ធកម្មប្រកបដោយនិរន្តរភាព។

៣. ការបង្កើតឱ្យមានថ្នាលបណ្ដុះបណ្ដាលអនឡាញ ដែលជាកាតព្វកិច្ចខានមិនបាន ជាពិសេសសម្រាប់អ្នកធ្វើការសម្រេចចិត្ត, មន្ត្រីកម្រិតគោលនយោបាយ និងអ្នកអនុវត្តលទ្ធកម្ម គឺជារឿងមួយសំខាន់ណាស់។ ថ្នាលបណ្ដុះបណ្ដាលទាំងនោះ គួរតែត្រូវបានរៀបចំឱ្យស្របតាមគោលការណ៍នៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) និងស្របតាមវិធាន និងបទប្បញ្ញត្តិ ស្ដីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (SPP) ដែរ។ តាមរយៈការអនុវត្តគំនិតផ្ដួចផ្ដើមទាំងនេះ យើងអាចលើកកម្ពស់ការកសាងសមត្ថភាពឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់ការប្រើប្រាស់យ៉ាងទូលំទូលាយ នូវការអនុវត្តកិច្ចលទ្ធកម្មប្រកបដោយនិរន្តរភាព នៅតាមគ្រប់កម្រិតនៃអភិបាលកិច្ច។

៤. បង្កើតសេចក្ដីសង្ខេបគោលនយោបាយ ឬឯកសារទស្សនៈទានសំខាន់ៗ ដែលកាន់តែរំលេចសារៈសំខាន់ នៃសេចក្ដីព្រាងផែនទីចង្អុលផ្លូវ SPP ដែលបានធ្វើបច្ចុប្បន្នភាព, ការយល់ដឹងពីបទពិសោធន៍របស់ប្រទេសផ្សេងទៀត និងការបង្កើតអនុក្រឹត្យស្ដីពី SCP ដើម្បីគូសបញ្ជាក់ពីតម្រូវការក្នុងការអនុវត្ត SPP នៅកម្ពុជា។

៥. ធ្វើសមាហរណកម្មប្រព័ន្ធលទ្ធកម្មទាំងអស់ សម្រាប់គម្រោងពីក្រៅប្រទេស និងគម្រោងដែលផ្ដល់មូលនិធិដោយរាជរដ្ឋាភិបាល ទៅក្នុងប្រព័ន្ធមួយដែលមានលក្ខណៈឯកភាពស្អិតរមួត។ សមាហរណកម្មនេះ គួរធ្វើតាមបែបម៉្យាងដែលច្របាច់បញ្ចូលលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវសម្រាប់និរន្តរភាព ដើម្បីត្រៀមសម្របវាជាមួយនឹងដំណើរការពេញលេញនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) នាពេលអនាគត។

៦. គាំទ្រការពិនិត្យឡើងវិញលើសៀវភៅណែនាំការអនុវត្តគម្រោង (PIM) ដើម្បីបញ្ចូលគោលការណ៍ និងស្តង់ដារលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព សម្រាប់ប្រព័ន្ធលទ្ធកម្មថ្នាក់ក្រោមជាតិ ដោយការធ្វើការពាក់ព័ន្ធជាមួយគ្រប់ភាគី និងសម្របតាមការទម្លាប់អនុវត្តប្រកបដោយនិរន្តរភាព។

៧. ជំរុញភាពជាដៃគូជាមួយអង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធនានា ដើម្បីសម្រួលដល់ការចែករំលែកចំណេះដឹង និងអនុវត្តគំនិតផ្ដួចផ្ដើមនានាទាក់ទិនទៅនឹង SCP និង SPP ឱ្យមានប្រសិទ្ធភាព។

៨. សូមសង្កត់ធ្ងន់លើការចាប់យកបច្ចេកវិទ្យានវានុវត្តន៍ មានលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាដើម ដើម្បីបង្កើនតម្លាភាព, ប្រសិទ្ធភាព និងនិរន្តរភាព នៅក្នុងដំណើរការលទ្ធកម្មសាធារណៈ។ រាល់ការរៀបចំកែសម្រួល ឬធ្វើបច្ចុប្បន្នភាព លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវគិតគូរដល់ការបញ្ចូលលក្ខណៈវិនិច្ឆ័យនិរន្តរភាពទៅក្នុងដំណើការធ្វើការសម្រេចចិត្តជារ។

៩. អនុវត្តយន្តការតាមដាន និងវាយតម្លៃ ដើម្បីវាយតម្លៃប្រសិទ្ធភាព និងឥទ្ធិពលនៃគំនិតផ្ដួចផ្ដើម SPP និង SCP ដោយធ្វើយ៉ាងណាឱ្យមានការកែលម្អជាបន្តបន្ទាប់ និងឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ មន្ត្រីដែលទទួលខុសត្រូវលើការត្រួតពិនិត្យលទ្ធផលនៃដំណើរការលទ្ធកម្ម ចាំបាច់ត្រូវយល់ជ្រាបឱ្យច្បាស់អំពីគោលគំនិតថ្មីស្ដីពីការចាយវាយឱ្យបានផលសមតាមតម្លៃជាលុយ (value for money) ដោយធ្វើការច្របាច់បញ្ចូលកម្មវត្ថុនៃគោលដៅអភិវឌ្ឍន៍ទូលំទូលាយមានលក្ខណៈស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា ទៅក្នុងដំណើរការលទ្ធកម្មសាធារណៈ។

១០. បង្កើតឱ្យមានយន្តការស្ថាប័នស្នូលមួយសម្រាប់ដើរតួជាច្រកចូល ដូចជា ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ SCP (SCP TWG) ដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងកិច្ចសហការ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន និងក្រសួងមានសមត្ថកិច្ចផ្សេងទៀតផងដែរ។

១១. ដោយសារលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ជាគោលនយោបាយយុទ្ធសាស្ត្រពហុផ្នែក គេចាំបាច់ត្រូវមានការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងក្រសួងទទួលខុសត្រូវនានា ដើម្បីធានាឱ្យការអនុវត្តសម្រេចបានជោគជ័យ។ ក្នុងន័យនេះ គួរបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់មួយ ដោយមានវត្តមានក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដឹកនាំរួមគ្នា រួមដោយតំណាងមកពីក្រសួងពាក់ព័ន្ធនានាជាសមាជិក ដើម្បីសម្របសម្រួល និងតាមដានការអនុវត្ត S/GPP ក្នុងក្របខ័ណ្ឌពេលវេលាសមស្របមួយ។ យន្តការនេះ ត្រូវមានវត្តមានរបស់អ្នករៀបចំគោលនយោបាយ និងអ្នកតាក់តែងច្បាប់មកពីក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដឹកនាំសម្របសម្រួលការអនុវត្តចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយប្រព័ន្ធលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពឱ្យកាន់តែមានប្រសិទ្ធភាព។

# ជំពូក ១. សេចក្តីផ្តើម

## ១.១ សាវតារ

នៅទូទាំងពិភពលោក លទ្ធកម្មសាធារណៈ ត្រូវបានទទួលស្គាល់ថាជាឧបករណ៍ដ៏មានអានុភាព ដែលរដ្ឋាភិបាលអាចបង្កើត និងប្រើប្រាស់ជាបន្តបន្ទាប់ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន។ នៅក្នុងក្របខ័ណ្ឌនៃរបៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាព លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) ត្រូវបានចាត់ទុកថាជាចំណុចដៅមួយ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១២ (SDG 12.7)។ ទោះបីជាមានការទទួលស្គាល់នូវសារៈសំខាន់របស់វាក្តី ក៏ SPP ជារឿយៗ មិនត្រូវបានគេយកទៅគិតគូរឱ្យបានស៊ីជម្រៅនៅក្នុងក្របខ័ណ្ឌនៃគោលបំណងអភិវឌ្ឍន៍ជាតិ ហើយក៏មិនត្រូវបានបញ្ចូលឱ្យបានពេញលេញ ទៅក្នុងដំណើរការធ្វើកម្មវិធី ការធ្វើផែនការហិរញ្ញវត្ថុ និងថវិការបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាពនោះទេ។

ជាប្រពៃណី ការអនុវត្ត SPP ច្រើនតែធ្វើក្រោមទស្សនៈតូចចង្អៀត ដោយផ្តោតសំខាន់តែទៅលើកិច្ចលទ្ធកម្មសាធារណៈនៃផលិតផល និងការផ្គត់ផ្គង់ឱ្យបានតម្លៃទាបសម្រាប់រយៈពេលខ្លីបំផុត ហើយមើលរំលងផលប៉ះពាល់យូរអង្វែងទៅលើសេដ្ឋកិច្ច បរិស្ថាន និងសង្គម ដែលអាចមានតម្លៃខ្ពស់ជាងការសម្រេចចិត្តធ្វើលទ្ធកម្មនោះទៅទៀត។ ត្រង់នេះឆ្លុះឱ្យឃើញពីកង្វះការគិតគូរសម្រាប់បញ្ចូលលក្ខណៈវិនិច្ឆ័យនិរន្តរភាពបរិស្ថាន ឬសង្គម និងលក្ខខណ្ឌតម្រូវ ទៅក្នុងដំណើរការដេញថ្លៃ និងកិច្ចសន្យាធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងសំណង់ស៊ីវិល រួមទាំងគម្រោងសាងសង់ខ្នាតធំ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផងដែរ។ អាស្រ័យហេតុនេះ វាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយចំណុចខ្វះខាតនេះ ព្រោះវាដើរតួនាទីសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចសង្គមរយៈពេលវែង និងកាត់បន្ថយបញ្ហាប្រឈមបរិស្ថាន ដូចជាការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវៈចម្រុះ និងការបំពុលគ្រប់ប្រភេទ។

ដើម្បីធានាបាននូវការអនុវត្ត SPP មានប្រសិទ្ធភាព និងស្របតាមនិន្នាការសកលស្តីពីនិរន្តរភាព ដំណោះស្រាយសំខាន់មួយគឺការផ្សារភ្ជាប់ឱ្យបានរឹងមាំរវាងលទ្ធកម្មប្រកបដោយនិរន្តរភាព និងគោលដៅអភិវឌ្ឍន៍ជាតិ។ ចំណងភ្ជាប់នេះគឺជាគន្លឹះក្នុងការតម្រឹមយុទ្ធសាស្ត្រ SPP ឱ្យស្របតាមផែនការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទូលំទូលាយ និងបញ្ជ្រាបលក្ខណៈវិនិច្ឆ័យប្រកបដោយនិរន្តរភាព ទៅក្នុងប្រព័ន្ធលទ្ធកម្មរបស់ប្រទេសដែលមានស្រាប់។ ប្រព័ន្ធទាំងនេះគួរអមដោយសៀវភៅណែនាំប្រតិបត្តិការរួមគ្នាលម្អិតមួយស្តីពី (i) ការរចនា/រៀបចំគម្រោង, (ii) ការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ, (iii) ក្របខ័ណ្ឌថវិកា និង (iv) ដំណើរការ និងនីតិវិធីលទ្ធកម្ម។ លើសពីនេះ វាមានសារៈសំខាន់ណាស់ក្នុងការបែងចែកធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាព SPP។ នៅក្នុងនោះក៏ត្រូវមានផងដែរនូវការផ្តល់ហិរញ្ញប្បទាន និងការផ្តល់ឱកាសការកសាងសមត្ថភាព និងការបណ្តុះបណ្តាលជាបន្តបន្ទាប់សម្រាប់មន្ត្រីដែលចូលរួមក្នុងដំណើរការលទ្ធកម្ម។ តាមរយៈការធ្វើដូច្នេះ បន្តិចម្តងៗ រាជរដ្ឋាភិបាលអាចចាប់យកទម្លាប់អនុវត្តប្រកបដោយនិរន្តរភាព និងជំរុញការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។

តាមរយៈកម្មវិធីមានឈ្មោះថា EU Green Deal and Global Gateway សហភាពអឺរ៉ុបបានប្តេជ្ញាចិត្តក្នុងការគាំទ្រដល់ប្រទេសនានា ក្នុងការបោះជំហានទៅរកសេដ្ឋកិច្ចចក្រា ដែលបញ្ចេញកាបូនទាប និងមានប្រសិទ្ធផលធនធាន ស្របជាមួយនឹងការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP)។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ សមាសភាគគាំទ្រគោលនយោបាយរបស់ SWITCH-Asia (PSC) មានគោលដៅរក្សាបានកំណើនវឌ្ឍនភាពរបស់ SCP តាមរយៈការពង្រីក និងបញ្ជ្រាបគោលនយោបាយ SCP នៅក្នុងប្រទេសចំនួន ៤១ ចាប់តាំងពីមជ្ឈិមបូព៌ា រហូតដល់អាស៊ីខាងត្បូង អាស៊ីកណ្តាល អាស៊ីអាគ្នេយ៍ និង អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ("តំបន់គោលដៅ")។ ក្នុងរយៈពេល ៤៨ខែ គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ មកក្រុមការងារ SWITCH ASIA PSC បានសហការជាមួយដៃគូអនុវត្តគម្រោង (GOPA និង NIRAS), ប្រតិភូសហភាពអឺរ៉ុប, អង្គការក្នុងតំបន់ និងបណ្តាញនានា ដើម្បីជំរុញគោលនយោបាយស្តីពី SCP នៅប្រទេសកម្ពុជា, វៀតណាម, បង់ក្លាដែស និងម៉ាឡេស៊ី។ SWITCH ASIA PSC និងដៃគូរបស់ខ្លួន ធ្វើការផ្តល់ប្រឹក្សាបច្ចេកទេស ការផ្លាស់ប្តូរចំណេះដឹង និងការកសាងសមត្ថភាពដល់រដ្ឋាភិបាលនានា ជាពិសេសផ្តោតលើបរិស្ថាន និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។

នៅកម្ពុជា ក្រុមអ្នកជំនាញរបស់ SWITCH ASIA ធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រតិភូសហភាពអឺរ៉ុប និងដៃគូសំខាន់ៗដូចជា GIZ, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការសង្គមស៊ីវិល ដូចជាអង្គការតម្លាភាពកម្ពុជា (TIC)។ គោលដៅរួមរបស់យើង គឺផ្តល់ជំនួយបច្ចេកទេស និងការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ក្នុងការតម្រឹមក្របខ័ណ្ឌច្បាប់ និងគោលនយោបាយលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១២ (SDG #12) និងការលើកកំពស់ SPP ឱ្យក្លាយជាបទដ្ឋានគតិយុត្តិសំខាន់ដើម្បីគាំទ្រដល់ការធ្វើអន្តរកម្មរបស់កម្ពុជា ទៅនៅលើគន្លងសេដ្ឋកិច្ចចក្រា ដែលបញ្ចេញកាបូនទាប និងប្រើប្រាស់ធនធានមានប្រសិទ្ធផលខ្ពស់។

ផ្អែកលើគំហើញតាមរយៈការសិក្សាបឋមមួយ ដែលកម្មវិធី SWITCH-Asia បានលើកយកមកបង្ហាញនៅកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនក្នុងឆ្នាំ២០២៣ កន្លងទៅ ពេលនេះ SWITCH ASIA កំពុងធ្វើការសិក្សាគ្រប់ជ្រុងជ្រោយមួយទៀត ដែលហៅថា "ករណីសិក្សាស៊ីជម្រៅ"។ កិច្ចការនេះមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន និងតួអង្គពាក់ព័ន្ធក្នុងផ្នែកឯកជនមួយចំនួន។ តាមរយៈដំណើរការពិគ្រោះយោបល់នេះ យើងមានបំណងកំណត់ឱ្យបានពីតម្រូវការ និងបញ្ហាប្រឈមជាក់លាក់ សម្រាប់ការលើកកម្ពស់ SPP នៅកម្ពុជា។ គំហើញទាំងនោះ នឹងជួយសម្រួលដល់ការរៀបចំបង្កើតអន្តរាគមន៍ចំគោលដៅ និងគាំទ្រការដល់បង្កើតផែនទីចង្អុលផ្លូវជាតិមួយសម្រាប់រៀបចំក្របខ័ណ្ឌស្តីពី SPP។

## ១.២ គោលបំណង

គោលបំណងនៃករណីសិក្សានេះ គឺបានមកពីការសិក្សាស្វែងយល់ជាបឋមមួយ ហើយសំដៅធ្វើការចងក្រងឯកសារអំពីឧត្តមានុវត្តន៍នៅក្នុងផ្នែកបរិស្ថាន និងលទ្ធកម្មប្រកបដោយការទទួលខុសត្រូវ។ គោលបំណងទាំងនោះមានដូចខាងក្រោម៖

១. ដើម្បីពិនិត្យមើលនូវគោលនយោបាយ ឯកសារច្បាប់ និងបទប្បញ្ញត្តិនានារបស់កម្ពុជាទាក់ទងនឹងបញ្ហាជុំវិញគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ដែលគាំទ្រដល់ការបញ្ចូលការគិតគូរពីនិរន្តរភាពទៅក្នុងការសម្រេចចិត្តក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ការពិនិត្យផ្ទៀងផ្ទាត់នេះមានគោលបំណងកំណត់ថាតើមានគម្លាតសំខាន់ៗ និងចំណុចជាក់លាក់ណាខ្លះដែលត្រូវកែលម្អ សម្រាប់ធ្វើការពង្រឹកទម្លាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅកម្ពុជា។

២. ដើម្បីស្វែងយល់អំពីក្រសួង-ស្ថាប័នជំនាញដែលជាប់ពាក់ព័ន្ធក្នុងការបង្កើត និងអនុវត្តការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅកម្ពុជា។ កិច្ចការនេះរួមមានការវិភាគទិដ្ឋភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈទូលំទូលាយ, កំណត់អត្តសញ្ញាណយន្តការអន្តរក្រសួង និងស្វែងយល់អំពីតួនាទីរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ ដែលមានឥទ្ធិពលលើការអនុវត្ត SPP នៅកម្ពុជា។

៣. ចងក្រងឱ្យបានទូលំទូលាយនូវករណីសិក្សាគំរូ ដែលរំលេចពីជោគជ័យនៃការអនុវត្តល្អៗស្តីពី SPP នៅតាមវិស័យអាទិភាពណាដែលអាចយកទៅអនុវត្តសាកល្បង និងមានលទ្ធភាពពង្រីកទៅថ្ងៃមុខ។

៤. លើកអនុសាសន៍ជាក់លាក់ និងអាចអនុវត្តបានសម្រាប់ដៃគូ និងក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីសហការគ្នាលើកកម្ពស់ SPP នៅកម្ពុជា។ អនុសាសន៍ទាំងនោះនឹងសម្របតាមចំណុចផ្តើមជាយុទ្ធសាស្ត្រសម្រាប់ជំរុញ SCP និង SPP នៅកម្ពុជា ហើយផ្តល់ជាផែនទីចង្អុលផ្លូវជាតិ សម្រាប់យកទៅអនុវត្តឱ្យមានប្រសិទ្ធភាព។

## ១.៣ អភិក្រម និងវិធីសាស្ត្រ

ឆ្លើយតបទៅនឹងគោលបំណងទាំងនេះប្រកបដោយប្រសិទ្ធភាព ក្រុមអ្នកជំនាញបានប្រើអភិក្រមទូលំទូលាយនៅក្នុងការប្រមូល, ការបកស្រាយ និងការរាយការណ៍ទិន្នន័យ ជាជំហានៗដូចខាងក្រោម៖

១. **ការបង្កើតកម្រងសំណួរមេ៖** ក្រុមការងារបានរចនាកម្រងសំណួរមេ ដែលតម្រូវតាមក្រុមពាក់ព័ន្ធសំខាន់ចំនួនបី៖ (i) ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល, (ii) ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល, និង (iii) វិស័យឯកជន។

២. **ការប្រមូលទិន្នន័យតាមរយៈការពិនិត្យឯកសារ និងការពិគ្រោះយោបល់៖** ក្រុមការងារបានធ្វើការពិនិត្យឯកសារយ៉ាងល្អិតល្អន់ ដែលរួមមានឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធ របាយការណ៍ និងឯកសារយោងនានាពាក់ព័ន្ធ SPP។ លើសពីនេះ ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ម្ចាស់ជំនួយ ក្រុមហ៊ុនឯកជន និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

៣. **ការបកស្រាយ និងការវិភាគ៖** ទិន្នន័យដែលប្រមូលបាន ត្រូវឆ្លងកាត់ការពិនិត្យ និងវិភាគយ៉ាងហ្មត់ចត់។ អ្នកប្រឹក្សាយោបល់ប្រើវិធីសាស្ត្រផ្ទៀងផ្ទាត់ទិន្នន័យជាមួយប្រភពផ្សេងៗយ៉ាងល្អិតល្អន់ រួចទើបធ្វើសុពលកម្មទិន្នន័យទាំងនោះ។

៤. **ការចូលពាក់ព័ន្ធជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ៖** ក្រុមអ្នកជំនាញបានធ្វើការយ៉ាងសកម្មជាមួយតួអង្គពាក់ព័ន្ធនៅក្នុងដំណើរការប្រមូលទិន្នន័យទាំងមូល។ ក្នុងនោះមានក្រសួង-ស្ថាប័ន ម្ចាស់ជំនួយ ក្រុមហ៊ុនឯកជន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គោលបំណងចម្បង គឺដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅអំពីតួនាទី ឥទ្ធិពល និងការគាំទ្ររបស់ក្រសួង-ស្ថាប័ននីមួយៗទាក់ទងនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព, ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព, និងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។




**គំនូសតាងទី១៖ ដំណើរការរបស់ករណីសិក្សា**

## ១.៤ បញ្ហាប្រឈម

ដំណើរការនៃករណីសិក្សាអំពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅកម្ពុជា បានជួបបញ្ហាខ្លះៗ ដូចជា៖

**ទិន្នន័យដែលអាចរកបានមានតិចតួច៖** ការរកបានទិន្នន័យដែលអាចទុកចិត្តបានស្តីពីគោលនយោបាយ បទប្បញ្ញត្តិ និងការអនុវត្ត ទាក់ទងនឹងការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) និង លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) មិនមែនជារឿងងាយស្រួលប៉ុន្មានទេ ដោយសារ SCP និង SPP ជាគំនិតថ្មីសន្លាងនៅកម្ពុជា។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ដំបូងគេត្រូវកំណត់តួអង្គពាក់ព័ន្ធសំខាន់ៗនៅក្នុងរាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ អភិក្រមនេះមានគោលបំណងស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅអំពីតម្រូវការ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការបង្កើត ការលើកកម្ពស់ និងការបន្តរក្សាទម្លាប់អនុវត្ត SCP និង SPP ផ្អែកលើមេរៀនដកពិសោធន៍មានតម្លៃដែលមានពីមុនមក។

**ពេលវេលាមានកំណត់៖** ដំណើរការវាយតម្លៃជួបប្រទះបញ្ហាពេលវេលាដោយសារតែវាមានកំណត់ ដូច្នេះវាអាចប៉ះពាល់ដល់វិសាលភាព និងជម្រៅនៃកិច្ចការប្រមូល និងការវិភាគទិន្នន័យ និងការរៀបចំបង្កើតផែនទីចង្អុលផ្លូវជាតិទូលំទូលាយមួយ សម្រាប់ SPP។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ករណីសិក្សាបានផ្តល់អាទិភាពដល់ការចូលរួមរបស់តួអង្គពាក់ព័ន្ធដែលជាគោលដៅ ដូចជា ការពិគ្រោះយោបល់ក្រៅផ្លូវការជាដើម។ បន្ទាប់ពីមានកិច្ចប្រជុំរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថានរួចមក ករណីសិក្សានេះបានធ្វើការពាក់ព័ន្ធជាមួយតួអង្គផ្សេងទៀតផងដែរ។ កិច្ចប្រជុំនេះរួមគ្នានេះ មានគោលបំណងស្វែងរកការឯកភាពគ្នាលើក្របខ័ណ្ឌនៃឯកសារទស្សនាទានមួយសម្រាប់ធ្វើជាមូលដ្ឋាន និងដើម្បីកំណត់សកម្មភាពអាទិភាពនានា សម្រាប់កិច្ចសហការ និងការផ្តល់ជំនួយបច្ចេកទេសនាពេលខាងមុខ។

**ទិដ្ឋភាពគោលនយោបាយស្មុគស្មាញ៖** បើមើលទៅលើទិដ្ឋភាពគោលនយោបាយ, SCP និង SPP នៅតាមក្រសួង-ស្ថាប័ននៅកម្ពុជា មានលក្ខណៈដាច់ដោយឡែកៗពីគ្នា មានភាពស្មុគស្មាញ ហើយខ្វះបទប្បញ្ញត្តិ ការណែនាំ និងនីតិវិធីលម្អិតសម្រាប់អនុវត្ត។ ការព្យាយាមស្វែងយល់ដឹងអំពីភាពស្មុគស្មាញនេះ និងរកមើលថាតើមានគម្លាត ការត្រួតស៊ីគ្នា និងភាពមិនស៊ីចង្វាក់គ្នានៅត្រង់ណាខ្លះ មិនមែនជាកិច្ចការសាមញ្ញប៉ុន្មានទេ។ ដោយហេតុនេះហើយ បានជាដំណើរការរបស់ករណីសិក្សានេះត្រូវធ្វើការពាក់ព័ន្ធយ៉ាងសកម្មជាមួយក្រសួងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសមាគមវិស័យឯកជន ដើម្បីប្រមូលការយល់ដឹង និងទស្សនៈពីគ្រប់ភាគី ទាំងខាងតម្រូវការ និងខាងផ្គត់ផ្គង់។ ការពិគ្រោះជាមួយតួអង្គពាក់ព័ន្ធទាំងនេះ មានគោលបំណងស្វែងយល់ឱ្យកាន់តែច្បាស់អំពីតម្រូវការ និង បញ្ហាប្រឈមផ្សេងៗពាក់ព័ន្ធជាមួយការផ្លាស់ប្តូរពីការធ្វើលទ្ធកម្មសាធារណៈតាមបែបប្រពៃណី ទៅជា SPP វិញ ស្របតាមនិន្នាការពិភពលោក និង គោលនយោបាយជាតិ។

**កង្វះ SPP ដែលមានការចែងច្បាស់លាស់, កង្វះការយល់ដឹងរបស់ភាគីពាក់ព័ន្ធ និងកង្វះតួនាទីនាំមុខ៖** ការណ៍ដែលគ្មានក្របខ័ណ្ឌ SPP ច្បាស់លាស់ អមជាមួយនឹង ការយល់ដឹង និងសមត្ថភាពមានកម្រិតទាបក្នុងចំណោមភាគីពាក់ព័ន្ធ រួមទាំងក្រសួងសំខាន់ៗផង បង្កជារបាំងមួយដល់ការរៀបចំបង្កើត និងការអនុវត្តទម្លាប់លទ្ធកម្មប្រកបដោយនិរន្តរភាព។ ស្ថានភាពនេះអាចនាំឱ្យមានការជំទាស់ទៅនឹងការផ្លាស់ប្តូរ និងអាចបង្កការលំបាកសម្រាប់ការរុញ SPP ទៅមុខ នៅកម្ពុជា ផងដែរ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ជាកិច្ចការសំខាន់ណាស់ដែលគេត្រូវរៀបចំឱ្យមានកិច្ចសន្ទនារួមគ្នាក្នុងចំណោមក្រសួងសំខាន់ៗ ដែលទទួលខុសត្រូវលើលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព និងកិច្ចសន្ទនាឱ្យបានទូលំទូលាយជាមួយដៃគូអភិវឌ្ឍន៍ (រួមមានធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, អង្គការ GIZ ជាដើម) និងតួអង្គពាក់ព័ន្ធក្នុងវិស័យឯកជន (ឧ. EUROCHAM) ផងដែរ។ ការសន្ទនាទាំងនេះគួរមានក្រសួងរាជរដ្ឋាភិបាល ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ជាអ្នកដឹកនាំធ្វើ។ គោលដៅចម្បងនៃកិច្ចសន្ទនាទាំងនេះ គឺដើម្បីសម្រួលដល់ការចែករំលែកចំណេះដឹង, ផ្លាស់ប្តូរឧត្តមានុវត្តជាមួយគ្នា និងជំរុញឱ្យមានកិច្ចខិតខំរួមគ្នាក្នុងការបង្កើតយុទ្ធសាស្ត្រ និងឧបករណ៍ ដែលលើកកម្ពស់លទ្ធកម្មសាធារណៈដែលមានមេត្រីបរិស្ថាន។

# ជំពូក ២. ទិដ្ឋភាពទូទៅស្តីពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា

សេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនស្វាហាប់ និងរឹងមាំនៅក្នុងទសវត្សរ៍កន្លងទៅនេះ។ ពីឆ្នាំ២០១១[1] ដល់ឆ្នាំ២០១៩ កម្ពុជាមានកំណើន ផ.ស.ស ប្រចាំឆ្នាំក្នុងអត្រាលើសពី ៧% ជានិច្ច ប៉ុន្តែកំណើននេះធ្លាក់ចុះយ៉ាងគំហុក ក្នុងពេលជំងឺរាតត្បាតកូវីដ-១៩ វាយលុកក្នុងអំឡុងឆ្នាំ២០២០-២០២១។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រដើម្បីស្តារសេដ្ឋកិច្ចចេញពីវិបត្តិសុខភាព និងពីវិបត្តិសេដ្ឋកិច្ចសកលឡើងវិញ រហូតដល់ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជារើបឡើង និងទទួលបានកំណើន ៥.២% ក្នុងឆ្នាំ ២០២២។ ផ.ស.ស សម្រាប់ប្រជាជនកម្ពុជាម្នាក់ក្នុងមួយឆ្នាំដែលមានត្រឹមតែ ៨០០,៣ដុល្លារអាមេរិក ក្នុងឆ្នាំ២០១១ បានកើនដល់ ១៧៥៩,៦ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២២[2]។ ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច និងការប្រើប្រាស់ មួយផ្នែកបានមកដោយសារកំណើនប្រជាជនយ៉ាងឆាប់រហ័ស ជាពិសេសនៅក្នុងទីក្រុង និងទីប្រជុំជនធំៗទូទាំងប្រទេស។ ឧទាហរណ៍ ចំនួនប្រជាជនបានកើនឡើងពី ១៣.៩ លាននាក់ក្នុងឆ្នាំ ២០០៨ ដល់ ១៦.៧លាននាក់ក្នុងឆ្នាំ២០២២[3]។ ដូច្នេះការដោះស្រាយបញ្ហាប្រឈមទាំងនេះទាមទារឱ្យមានការធ្វើផែនការ អន្តរាគមន៍គោលនយោបាយយ៉ាងប្រុងប្រយ័ត្ន និងការសម្របសម្រួលនៅក្នុងចំណោមតួអង្គពាក់ព័ន្ធ រួមមានរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ។ ចំណុចសំខាន់គឺការស្វែងរកដំណោះស្រាយប្រកបដោយនិរន្តរភាព ដើម្បីធានាថាប្រជាជនដែលមានចំនួនកើនឡើងជាលំដាប់ អាចរស់នៅនិងប្រកបមុខរបរដោយមិនប៉ះពាល់ដល់គុណភាពជីវិត និរន្តរភាពបរិស្ថាន និងសុខុមាលភាពសង្គម។




រូបភាពទី ២៖ កំណើន ផ.ស.ស របស់កម្ពុជា (ប្រចាំឆ្នាំ%)

## ២.១ បញ្ហាសង្គម

នៅប្រទេសកម្ពុជា ការអភិវឌ្ឍប្រកបដោយនិរន្តរភាពតែងតែជួបឧបសគ្គ ដោយសារភាពក្រីក្រ និងវិសមភាព។ ការកាត់បន្ថយភាពក្រីក្រ និងការដោះស្រាយវិសមភាពប្រាក់ចំណូល គឺជាកត្តាសំខាន់សម្រាប់កំណើនប្រកបដោយ។ លទ្ធភាពតិចតួចសម្រាប់ទទួលបានការអប់រំប្រកបដោយគុណភាព ជាពិសេសនៅតំបន់ជនបទ បង្កឱ្យមានវិសមភាពសង្គម។ ការបង្កើនឱកាសសិក្សាសម្រាប់សហគមន៍ងាយរងគ្រោះ ឬប្រឈមមុខចំពោះហានិភ័យ គឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមនុស្សប្រកបដោយនិរន្តរភាព។ ទោះបីជាមានការប្រឹងប្រែងច្រើនក្នុងកែលម្អមូលដ្ឋានសុខភាពសាធារណៈក៏ដោយ លទ្ធភាពទទួលបានសេវាថែទាំសុខភាពប្រកបដោយគុណភាពនៅតែជាកង្វល់នៅឡើយ។ ការធានាឱ្យមានលទ្ធភាពទទួលបានដោយសមធម៌, ការពង្រឹក

1 World Bank, National Accounts Data: https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?locations=KH accessed 28.12.2023

2 World Bank, National Accounts Data: https://data.worldbank.org/indicator/NY.GDP.PCAP.CD?locations=KH accessed 28.12.2023

3 World Bank, National Population Data: https://data.worldbank.org/indicator/SP.POP.TOTL?locations=KH&view=chart accessed 28.12.2023

ហេដ្ឋារចនាសម្ព័ន្ធ និងការដោះស្រាយការខ្វះខាតក្នុងប្រព័ន្ធសុខាភិបាលជាតិដោយធ្វើឱ្យវាមាននិរន្តរភាព និងភាពធន់ គឺមានសារៈសំខាន់សម្រាប់សុខុមាលភាព និងការកាត់បន្ថយភាពក្រីក្រ។ វិសមភាពយេនឌ័រនៅតែមាន ដោយបន្តរឹតត្បិតឱកាសរបស់ស្ត្រីក្នុងការទទួលបានអប់រំ ការងារ និងក្នុងការធ្វើសេចក្តីសម្រេច។ ការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាចស្ត្រី និងការប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកយេនឌ័រ គឺមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងប្រកបដោយបរិយាបន្ន។

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដោះស្រាយបញ្ហាសង្គម តាមរយៈការអនុវត្តកម្មវិធី និងគំនិតផ្តួចផ្តើមដូចខាងក្រោម៖

- រាជរដ្ឋាភិបាលបានបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម រួមមានកម្មវិធី ID-Poor ក្នុងនោះផងដែរ។ កម្មវិធីនេះកំណត់អត្តសញ្ញាណ និងផ្តល់ជំនួយសង្គមតាមគោលដៅដល់គ្រួសារជនងាយរងគ្រោះ តាមរយៈការផ្ទេរសាច់ប្រាក់ និងលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន។

- ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីគាំទ្រវិស័យអប់រំ។ កម្មវិធីនេះផ្តោតលើការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព ជាពិសេសនៅតាមតំបន់ជនបទ ក្នុងនោះមានសកម្មភាព ដូចជាការសាងសង់សាលារៀន ការបណ្តុះបណ្តាលគ្រូ និងអាហារូបករណ៍សម្រាប់សិស្សដែលមកពីគ្រួសារក្រីក្រ និងគ្រួសារជួបការលំបាកផ្សេងៗ។

- ដើម្បីធានាបាននូវលទ្ធភាពទទួលបានសេវាថែទាំសុខភាពសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ជាពិសេសស្ត្រីមានផ្ទៃពោះ រាជរដ្ឋាភិបាលបានបង្កើតមូលនិធិសមធម៌សុខាភិបាល (HEF) ដែលផ្តល់ហិរញ្ញវត្ថុគាំទ្រដល់មូលដ្ឋានសុខាភិបាលនៅទូទាំងប្រទេស ដើម្បីឱ្យគេអាចផ្តល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃ ជូនពលរដ្ឋក្រីក្រ។

- រាជរដ្ឋាភិបាលបានផ្តល់អាទិភាពដល់កម្មវិធីបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ នៅក្នុងកម្មវិធីនោះមានគោលដៅកាត់បន្ថយភាពក្រីក្រ និងធានាស្ថិរភាពសង្គម តាមរយៈការផ្តល់ដីធ្លីដល់គ្រួសារក្រីក្រដែលគ្មានដីធ្លី និងងាយរងគ្រោះ សម្រាប់ស្នាក់នៅនិងប្រកបរបរចិញ្ចឹមជីវិត។

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានដំណើរការអស់ជាងពីរទសវត្សរ៍មកហើយ ដើម្បីពង្រឹងអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងដំណើរការវិមជ្ឈការ។ តាមរយៈកម្មវិធីនេះ អាជ្ញាធរមូលដ្ឋានទទួលបានការផ្តល់សិទ្ធិអំណាច ដើម្បីដោះស្រាយអាទិភាពអភិវឌ្ឍន៍នៅមូលដ្ឋាន ក្នុងនោះមានបញ្ហាសង្គមផងដែរ តាមរយៈការសម្រេចចិត្ត និងការបែងចែកធនធានតាមបែបចូលរួម។

## ២.២ បញ្ហាបរិស្ថាន

យោងតាមនិយមន័យរបស់គណៈកម្មការពិភពលោកសម្រាប់បរិស្ថាន និងការអភិវឌ្ឍ "ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាសមត្ថភាពរបស់មនុស្សជាតិក្នុងការអភិវឌ្ឍ ដើម្បីធានាថាវាឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ន ដោយមិនធ្វើឱ្យខូចប្រយោជន៍ដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយ ក្នុងការបំពេញតម្រូវការរបស់ពួកគេ នាពេលអនាគត" ។ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ បណ្តាប្រទេសកំពុងអភិវឌ្ឍបានប្រឈមមុខនឹងបញ្ហាបរិស្ថានច្រើន ដែលជះផលវិបាកគំរាមកំហែងដល់អាយុជីវិតរបស់មនុស្ស។ តំបន់ជនបទត្រូវរងសម្ពាធកាន់តែខ្លាំង ដោយសារតែចំនួនកសិករ និងបុគ្គលគ្មានដីធ្លីកើនឡើង ខណៈដែលទីក្រុងកាន់តែមានភាពណែនណាន់តាន់តាប់ដោយមនុស្ស យានយន្ត និងរោងចក្រ។ យ៉ាងណាក្តី ប្រទេសកំពុងអភិវឌ្ឍត្រូវបន្តរុលដំណើរទៅមុខនៅក្នុងទិដ្ឋភាពដ៏ស្មុគ្រស្មាញនេះ ខណៈដែលវិសមភាពធនធានរវាងពួកគេ និងប្រទេសឧស្សាហកម្មជឿនលឿន កាន់តែរីកធំទៅៗ។ ជាងនេះទៅទៀត អង្គការអន្តរជាតិសំខាន់ៗតែងផ្តល់អាទិភាពដល់ផលប្រយោជន៍ និងគោលនយោបាយនៃបណ្តាប្រទេសឧស្សាហកម្មជឿនលឿន ក្រោយពីពិភពឧស្សាហកម្មបានបំផ្លាញធនធានអេកូឡូស៊ីអស់ជាច្រើននៅលើភពផែនដីរួចទៅហើយ។ វិសមភាពនេះឆ្លុះបញ្ចាំងឱ្យឃើញអំពី "បញ្ហាចម្បងផ្នែកបរិស្ថាន" របស់ភពផែនដី ហើយវាក៏ជា "បញ្ហាចម្បងសម្រាប់ការអភិវឌ្ឍ" ផងដែរ។[4]

ប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាបរិស្ថានធំៗ ដែលចាំបាច់ត្រូវឱ្យមានការយកចិត្តទុកច្រើនឡើងថែមទៀត។ ទីមួយ កម្ពុជាបានរងការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលដីយ៉ាងធ្ងន់ធ្ងរ ដែលជាចម្បងបណ្តាលមកពីការកាប់ឈើខុសច្បាប់ កសិកម្ម និង

4 One Common Future Report of the World Commission on Environment and Development (p.14)

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ ប្រការនេះបាននាំឱ្យបាត់បង់ទីជម្រកធម្មជាតិសំខាន់ៗ ការថយចុះនៃជីវៈចម្រុះ និងបង្កើនភាពងាយរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ។ ទីពីរ ទម្លាប់អនុវត្តក្នុងការគ្រប់គ្រងដីធ្លីគ្មាននិរន្តរភាព និងការកាប់បំផ្លាញព្រៃឈើកំពុងប៉ះពាល់ដល់ផលិតភាពកសិកម្ម បង្កការគំរាមកំហែងដល់សន្តិសុខស្បៀង។ ទីបី ការបំពុលពីការហូរច្រោះសារធាតុពុលពីផ្នែកកសិកម្ម ការបង្ហូរទឹកកខ្វក់ចេញពីឧស្សាហកម្ម និងការគ្រប់គ្រងទឹកសំណល់មិនបានល្អ កំពុងតែបំពុលប្រភពទឹកដែលជះឥទ្ធិពលអវិជ្ជមានដល់គុណភាពទឹក ប្រព័ន្ធអេកូឡូស៊ីក្នុងទឹក និងសុខភាពសាធារណៈ។ ទីបួន ការបំផ្លិចបំផ្លាញដែនជម្រកសត្វព្រៃ ការជួញដូរសត្វព្រៃ និងទម្លាប់អនុវត្តនេសាទគ្មាននិរន្តរភាព បង្កហានិភ័យយ៉ាងខ្លាំងដល់ជាតុចម្រុះនៃជីវៈចម្រុះ និងប្រភេទសត្វជិតផុតពូជនៅកម្ពុជា។ ចុងក្រោយ កម្ពុជាជាប្រទេសមួយងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដែលបានបង្កើតព្រឹត្តិការណ៍ធាតុអាកាសកាន់តែអាក្រក់ៗ ការកើនឡើងនៃកម្រិតទឹកសមុទ្រ និងការផ្លាស់ប្តូរលំនាំទឹកភ្លៀងដែលធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្ម ធនធានទឹក និងតំបន់ឆ្នេរ។ ការដោះស្រាយបញ្ហាប្រឈមបរិស្ថានទាំងនេះទាមទារឱ្យមានកិច្ចខិតខំរួមគ្នា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវអនាគតប្រកបដោយនិរន្តរភាព និងមានភាពធន់សម្រាប់កម្ពុជានៅពេលខាងមុខ។

លទ្ធកម្មបែបប្រពៃណីផ្តោតលើការគិតគូរអំពីតម្លៃជាប្រាក់។ ផ្ទុយទៅវិញ គោលដៅ និង បញ្ហាប្រឈមរបស់លទ្ធកម្មប្រកបដោយនិរន្តរភាព គឺដើម្បីបញ្ចូលការខ្វល់ខ្វាយគិតគូរអំពីបរិស្ថាន និងសង្គម ទៅក្នុងដំណើរការលទ្ធកម្ម សំដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព ស្ថានភាពសង្គម និងបរិស្ថាន ហើយតាមរយៈនេះសំចៃបាននូវការចំណាយដ៏មានតម្លៃសម្រាប់អង្គការ និងសហគមន៍ទាំងមូល។ លទ្ធកម្មប្រកបដោយនិរន្តរភាពជាផ្នែកគន្លឹះមួយនៃការជំរុញឱ្យមានការធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ពីសំណាក់រដ្ឋាភិបាល និងស្ថាប័នសាធារណៈ។

ប្រភព៖ UNDP’s Environmental Procurement ( Practical Guide Volume 1 )

## ២.៣ ការប្រើប្រាស់គ្មាននិរន្តរភាព

កំណើនសេដ្ឋកិច្ច និងចំនួនប្រជាជនក្នុងប្រទេសកម្ពុជា បាននាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនូវតម្រូវការប្រើប្រាស់ថាមពល និងសម្ភារ និងកំណើនកាកសំណល់ដែរ។ ប្រការនេះបានដាក់សម្ពាធយ៉ាងខ្លាំងទៅលើធនធានធម្មជាតិដ៏មានតម្លៃដែលនៅសេសសល់ រួមទាំងបរិស្ថានជារួមរបស់ប្រទេសមួយនេះ។

រវាងឆ្នាំ ២០១០ និង ២០១៥ ការប្រើប្រាស់ថាមពលសរុបនៅកម្ពុជា មានកំណើនជាមធ្យម ៦,៩% ក្នុងមួយឆ្នាំ។ ការបំពេញតម្រូវការដែលកើនឡើងឥតឈប់ឈរនេះ គឺបានមកពីប្រភពផ្សេងៗគ្នា ក្នុងនោះមានផលិតផលឥន្ធនៈ ៥០,៥%, ជីវម៉ាស ៣៦%, អគ្គិសនី ១៣,១% និងធ្យូងថ្ម ០,៤%។ វិស័យដឹកជញ្ជូន ដែលពឹងផ្អែកខ្លាំងលើប្រេងឥន្ធនៈ មានចំណែកដល់ ៤៦% នៃការប្រើប្រាស់ថាមពលសរុប។ វារីអគ្គិសនី និងធ្យូងថ្ម គឺជាប្រភពចម្បងសម្រាប់ការផលិតថាមពលអគ្គិសនី។ ដោយទទួលស្គាល់សារៈសំខាន់នៃថាមពលដែលអាចប្រើប្រាស់បាន និងមានតម្លៃសមរម្យសម្រាប់សង្គម និងវឌ្ឍនភាពសេដ្ឋកិច្ច រដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ ដោយផ្តល់អាទិភាពលើការអភិវឌ្ឍថាមពលប្រកបដោយនិរន្តរភាព និងតម្លៃសមរម្យ ដែលតាមរយៈនោះជួយកាត់បន្ថយបាននូវផលប៉ះពាល់លើបរិស្ថាន និងសង្គម ដែរ។ នៅក្នុងបរិការណ៍មួយដែលចំនួនប្រជាជនកម្ពុជា សេដ្ឋកិច្ច និងនគរូបនីយកម្មបន្តកើនឡើង ធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករថាតម្រូវការថាមពលរបស់ប្រទេសនឹងកើនឡើងទ្វេដងនៅឆ្នាំ២០៣០។ ថ្វីត្បិតតែវារីអគ្គិសនី និងថាមពលកកើតឡើងវិញកំពុងដើរតួជំនួសប្រេងឥន្ធនៈនៅក្នុងការផលិតអគ្គិសនីក៏ដោយ ការប្រើប្រាស់ផលិតផលប្រេងឥន្ធនៈត្រូវបានគេរំពឹងថានឹងនៅតែកើនឡើងដដែល ដោយសារតែតម្រូវការកើនឡើងក្នុងវិស័យដឹកជញ្ជូន ឧស្សាហកម្ម និងលំនៅដ្ឋាន[5]។

ឧស្សាហកម្មវិស័យឯកជនក៏មានការប្រើប្រាស់ធនធាន និងការបង្កើតកាកសំណល់ច្រើនដែរ នៅកម្ពុជា។ ឧស្សាហកម្មពឹងផ្អែកខ្លាំងលើធនធានធម្មជាតិ និងធាតុចូលរបស់ថាមពល ដែលតែងតែបន្សល់ទុកនូវកាកសំណល់ ភាគច្រើនជាកាកសំណល់តាមផ្ទះក្រោយពីវាត្រូវបានផលិតចេញ និងប្រើប្រាស់រួច។ និយាយឱ្យចំ គឺវិស័យកាត់ដេរតែម្តង ដែលជាវិស័យធំទីពីរនៅក្នុងប្រទេសដែលប្រើប្រាស់អុសជាប្រភពថាមពលចម្បងនៅក្នុងប្រតិបត្តិការផលិត ហើយក៏ជាប្រភពបង្កើតសំណល់វាយនភ័ណ្ឌច្រើនដែរ។ វិស័យអាជីវកម្មលក់ដុំ និងរាយ ប្រើប្រាស់កេសក្រដាសកាតុង និងបន្ទះផ្លាស្ទិកក្នុងបរិមាណច្រើនដែរសម្រាប់វេចខ្ចប់ទំនិញ ដែលទីបំផុត

5 5ADB (2018) CAMBODIA Energy Sector Assessment Strategy and Road Maphttps://www.adb.org/sites/default/files/institutional-document/479941/cambodia-energy-assessment-road-map.pdf

ភាគច្រើនត្រូវបានគេចោលនៅតាមគំនរសំរាម ឬទីលានចាក់សំរាម។ វិស័យកន្លែងស្នាក់នៅ និងសេវាកម្មអាហារ ក៏ពឹងផ្អែកខ្លាំងដែរលើសម្ភារប្រើប្រាស់តែមួយដង ដូចជា បំពង់បឺតប្លាស្ទិក ដប ប្រអប់អាហារ និងថង់ ដែលអ្នកប្រើប្រាស់តែងតែបោះចោលពេលប្រើប្រាស់រួច។ នៅក្នុងវិស័យសំណង់ សំណល់មួយចំនួនមិនត្រូវបានគេដាក់ទៅក្នុងប្រព័ន្ធគ្រប់គ្រងកាកសំណល់ផ្លូវការទេ ហើយត្រូវបានគេយកមកប្រើប្រាស់ឡើងវិញ ប៉ុន្តែនៅមានកាកសំណល់ច្រើនប្រភេទដែលទាមទារឱ្យមានទុកដាក់ការចោលឱ្យបានត្រឹមត្រូវ។ ការផលិតឥដ្ឋ និងស៊ីម៉ងត៍ ទាមទារធាតុចូលថាមពលខ្ពស់ ដែលភាគច្រើនបានបានមកពីអុស និងធ្យូងថ្ម[6]។

## ២.៤ ទិដ្ឋភាពសេដ្ឋកិច្ចសង្គមក្នុងវិស័យកសិ-ស្បៀងអាហារនៅកម្ពុជា

ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន និងកាត់បន្ថយភាពក្រីក្រ នាពេលទសវត្សរ៍កន្លងមក។ ក្នុងទសវត្សរ៍ឆ្នាំ២០១០ ប្រាក់ចំណូលគ្រួសារសម្រាប់ការប្រើប្រាស់ និងការចាយវាយនានា បានកើនគួរឱ្យកត់សម្គាល់ ក្នុងនោះប្រាក់ចំណូលគ្រួសារជាមធ្យមបានកើនពី ១១៧,៧០ដុល្លារអាមេរិកក្នុងមួយខែ ក្នុងឆ្នាំ២០១២ ដល់ ២៦៣,២០ដុល្លារក្នុងមួយខែ ក្នុងឆ្នាំ២០១៩។ ការផ្លាស់ប្តូរនេះបាននាំមកជាមួយនូវការផ្លាស់ប្តូរបែបផែនកម្លាំងពលកម្មពីការងារគ្រួសារ ទៅជាការងារមានប្រាក់ឈ្នួល និងប្រាក់ខែត្រឹមត្រូវ តាមជម្រើសរបស់ម្នាក់ៗ។ ប៉ុន្តែ ជំងឺកូវីដ-១៩ បានប៉ះទង្គិចខ្លាំងដល់ទីផ្សារការងារនៅកម្ពុជា ធ្វើឱ្យភាពគ្មានការងារធ្វើកើនឡើង ៤.៣% ក្នុងឆ្នាំ២០២០ ក្នុងនោះកម្មករិនីរងផលប៉ះទង្គិចខ្លាំងជាងគេ (UNDP, 2022)។

ជាទូទៅ ការងារក្រៅប្រព័ន្ធនៅកម្ពុជាកំពុងមាននិន្នាការធ្លាក់ចុះ ដោយក្នុងនោះចំនួនពលករក្រៅប្រព័ន្ធមាន ៨៨% នៃកម្លាំងពលកម្មក្រៅប្រព័ន្ធសរុប ក្នុងឆ្នាំ២០១៩ គឺធ្លាក់ចុះពី ៩៣% ក្នុងឆ្នាំ ២០១២។ ទោះជាយ៉ាងណាក៏ដោយ ការងារក្រៅប្រព័ន្ធនៅតែមាននៅក្នុងប្រទេសកម្ពុជា។ វិស័យឯកជនមានការរីកចម្រើនយ៉ាងខ្លាំងនៅក្នុងទសវត្សរ៍ចុងក្រោយនេះ ដោយមានសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) កំពុងដើរតួនាទីសេដ្ឋកិច្ចកាន់តែសំខាន់។ យោងតាមជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ កម្ពុជាមានអង្គភាពអាជីវកម្មមិនមែនកសិកម្មសរុបចំនួន ៧៣៥ ៤៥៦អង្គភាព ដែលក្នុងចំណោមនោះ ៩៩% ជា MSMEs។ ទោះយ៉ាងណាក៏ដោយ សហគ្រាសជាច្រើននៅក្រៅប្រព័ន្ធផ្លូវការ ក្នុងនោះ ៨៦.៦% មិនបានចុះបញ្ជីផ្លូវការទេ។ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ MSMEs ក្រៅផ្លូវការ និងផ្លូវការ រងការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ ដោយសារបាត់បង់តម្រូវការអ្នកប្រើប្រាស់ និងប្រាក់ចំណេញ ហើយលទ្ធភាពរកបានប្រាក់កម្ចីកាន់តែលំបាកសម្រាប់ MSMEs ក្រៅផ្លូវការ (៥៦%) ធៀបទៅនឹង MSMEs ផ្លូវការ (១៩%)។

លើសពីនេះ កម្ពុជាបានក្លាយជាប្រទេសនាំចេញកសិផលដ៏ច្រើនសន្ធឹកសន្ធាប់ ដោយនាំចេញបាន ៨,៦លានតោន ទៅកាន់ទីផ្សារចំនួន ៧៤គោលដៅ ក្នុងឆ្នាំកន្លងទៅ ដែលរួមចំណែកយ៉ាងច្រើនដល់ ផ.ស.ស (FAO 2023)។ ប៉ុន្តែ ផ្ទុយទៅនឹងការរីកចម្រើនជាវិជ្ជមានផ្នែកសេដ្ឋកិច្ចនេះ កម្ពុជាក៏មានអតុល្យភាពពាណិជ្ជកម្មធំដែរ។ កម្ពុជាជាអ្នកនាំចូលសុទ្ធអស់ជាយូរឆ្នាំមកហើយ ដែលនាំឱ្យមានឱនភាព ទាំងនៅក្នុងការធ្វើពាណិជ្ជកម្មរួម និងក្នុងការធ្វើពាណិជ្ជកម្មផ្នែកកសិ-ម្ហូបអាហារ។ ក្នុងឆ្នាំ២០១៨ តម្លៃសរុបនៃការនាំចេញកសិផលមានចំនួនត្រឹមតែ ០,៧៦ប៊ីលានដុល្លារអាមេរិកប៉ុណ្ណោះ ធៀបទៅនឹងតម្លៃសរុបនៃការនាំចូលជិត ១,៩ប៊ីលានដុល្លារអាមេរិក ដែលសរុបមកមានឱនភាពដល់ទៅ ១,២៦ប៊ីលានដុល្លារអាមេរិក (Sok et al., 2021)។ កសិផលសំខាន់ជាងគេសម្រាប់ការនាំចេញ រួមមាន ដំឡូងមី អង្ករ កៅស៊ូ គ្រាប់ធញ្ញជាតិ និងចំណីសត្វ (CAS 2021)។ រវាងឆ្នាំ២០១៥-២០២២ ការនាំចេញដំឡូងមីនាំមុខគេ គឺមានតម្លៃជាមធ្យម 369,393.76 thousand USD ក្នុងចន្លោះឆ្នាំ ២០១៤-២០១៨ ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពីតម្លៃ 134.26 thousand USD ក្នុងឆ្នាំ២០០០-២០០៤។

## ២.៥ បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា

ដូចដែលបានលើកឡើងនៅខាងលើ បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាច្រើនមុខព្រួញ មានដូចជា វិសមភាព និងភាពក្រីក្រ ការកើនឡើងនៃតម្រូវការប្រើប្រាស់ ធនធានមានកម្រិត និងបញ្ហាបរិស្ថាន (ការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវៈចម្រុះនិងការបំពុល)។ល។ នៅក្នុងស្ថានភាពដ៏លំបាកដូច្នេះ ការប្រើប្រាស់ធនធានកាន់តែខ្ពស់ដើម្បីបំពេញតម្រូវការប្រើប្រាស់កាន់តែច្រើនរបស់ប្រជាពលរដ្ឋ នឹងមិនមាននិរន្តរភាពនោះទេ ប្រសិនបើគ្មានការផ្លាស់ប្តូរបែបផែនផលិតកម្មទៅនៅលើគន្លងមួយដែលមានប្រសិទ្ធផលធនធាន ហើយស្របគ្នានោះ ត្រូវមានវិធានការដាក់ឱ្យអ្នកផលិតទទួលខុសត្រូវចំពោះផលប៉ះពាល់បរិស្ថានពីសំណាក់ផលិតផល និងសេវាកម្មពេញមួយវដ្តជីវិតរបស់វា។ ជាទូទៅ វាអាស្រ័យលើជម្រើសគោលនយោបាយដែលរដ្ឋាភិបាលអនុវត្ត តាមរយៈការតម្រង់ការវិនិយោគឱ្យទៅរកវិស័យដែលយកចិត្តទុកដាក់ចំពោះនិរន្តរភាពបរិស្ថាន ភាពសុខដុមរមនាក្នុង

6 Cambodia's Circular Economy Strategy and Action Plan (2021)

សង្គម និងសុខុមាលភាពរបស់ប្រជាជន។ ក្រៅពីការផ្លាស់ប្តូរនៅក្នុងក្របខ័ណ្ឌគោលនយោបាយដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅមានការផ្លាស់ប្តូរដ៏សំខាន់មួយទៀត គឺភាពចាំបាច់ត្រូវផ្លាស់ប្តូរផ្នត់គំនិតបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ និងអ្នកបង្កើតគោលនយោបាយ ដោយចាត់ទុកការរេចរឹលបរិស្ថាន និងការបាត់បង់ជីវៈចម្រុះ ថាជាការខាតបង់ធំធេងក្រៃលែងដែលប្រទេសកម្ពុជាត្រូវធ្វើជាថ្នូរជាមួយឧស្សាហូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច។ ការពង្រឹងប្រព័ន្ធលទ្ធកម្មសាធារណៈនឹងមានសារៈសំខាន់នៅក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ បើគិតអំពីទំហំរបស់លទ្ធកម្មសាធារណៈ និងតួនាទីរបស់វាក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ចឯកជន និងការកៀរគរវិនិយោគឯកជនបន្ថែមទៀត។

តាមរយៈការតម្រូវឱ្យមានផលិតផល ការងារ និងសេវាកម្មប្រកបដោយនិរន្តរភាពរាជរដ្ឋាភិបាលអាចបញ្ជ្រាបគោលដៅសម្រេចផលនិរន្តរភាពផ្នែកសង្គម និងបរិស្ថាន - ដែលជាស្នូលក្នុងការសម្រេចឱ្យបាន "តម្លៃជាប្រាក់" - ទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ ហើយតាមរយៈនោះរាជរដ្ឋាភិបាលអាចបញ្ជូនសញ្ញាទៀងទាត់ច្បាស់លាស់មួយទៅឱ្យទីផ្សារ ដើម្បីឱ្យចាប់ផ្តើមប្រកាន់យកទម្លាប់អនុវត្តផលិតកម្មប្រកបដោយនិរន្តរភាព ដែលខ្វល់ខ្វាយចំពោះបរិស្ថាន និងបរិយាបន្នសង្គម។ គោលនយោបាយ SPP អាចជាជម្រើសដ៏ល្អមួយក្នុងការរួមចំណែកជាមួយវិធានការគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយគុណភាពផ្នែកអេកូឡូស៊ី បញ្ចេញកាបូនតិច និងមានបរិយាបន្នសង្គម។ ហេតុនេះ កិច្ចលទ្ធកម្មប្រកបដោយនិរន្តរភាពអាចជួយឱ្យថ្នាក់ដឹកនាំ មន្ត្រីលទ្ធកម្មនៃក្រសួង-ស្ថាប័ន និងតួអង្គទីផ្សារនានា មានការយល់ដឹង និងទស្សនៈកាន់តែទូលំទូលាយ ដូច្នេះ វាគឺជាឧបករណ៍មួយមានប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាប្រឈមរបស់និរន្តរភាព ទាំងផ្នែកប្រើប្រាស់ និងផ្នែកផលិតកម្ម បើកាលណាគេយកវាមកធ្វើជាស្នូលនៃការសម្រេចចិត្តធ្វើលទ្ធកម្ម។

# ជំពូក ៣. ទិដ្ឋភាពរួមផ្នែកគោលនយោបាយ និងការវិភាគ

## ៣.១ ក្របខ័ណ្ឌគោលនយោបាយសម្រាប់ SPP

តួនាទី និងសារៈសំខាន់នៃការអភិវឌ្ឍដោយចីរភាពនៅក្នុងសេដ្ឋកិច្ចកម្ពុជាកំពុងមានសន្ទុះឈានឡើង។ លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) មានតួនាទីយ៉ាងសំខាន់ នៅក្នុងបរិការណ៍មួយដែលគម្រោងអភិវឌ្ឍន៍ជាតិកំពុងងាកទៅប្រកាន់យកនិរន្តរភាពនៅតាមវិស័យផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គម។ ចំណុចនេះត្រូវបានសបញ្ជាក់ដោយ "កម្មវិធីនយោបាយ"[7] ដែលរាជរដ្ឋាភិបាលអាណត្តិទីប្រាំពីរទើបនឹងអនុម័តរួច អមជាមួយ "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" (PS-PI)។ លាតសន្ធឹងរយៈពេល ២៥ឆ្នាំនៃដំណើរអភិវឌ្ឍន៍ រហូតដល់ឆ្នាំ២០៥០ កម្មវិធីនេះដាក់ចេញក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបង្ហាញពីអភិក្រមដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល នៅក្នុងការធ្វើបរិវត្តកម្មនៃសេដ្ឋកិច្ច-សង្គម។ គោលបំណងគឺដើម្បីពង្រឹងសង្គមកម្ពុជាឱ្យមានសមត្ថភាពដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជានានាដែលបង្កឡើងដោយបញ្ហាសកលការូបនីយកម្ម និរន្តរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។




គំនូសតាងទី៣៖ ដ្យាក្រាមយុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១
(ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ច ជាស្នូលនៃបញ្ចកោណ៤)

7 ចំណងជើងផ្លូវការគឺ "កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨"; https://mfaic.gov.kh /files/uploads/1XK1LW4MCTK9/EN%20PENTAGONAL%20 STR A TEGY%20-%20PHASE%20I.pdf

សំខាន់ជាងនេះទៅទៀត "ការពង្រឹងអភិបាលកិច្ច និងកំណែទម្រង់" គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១ ដែលផ្តល់អាទិភាពដល់ការធ្វើទំនើបកម្ម សមត្ថភាព កម្លាំង ភាពវៃឆ្លាត និងសុចរិតភាពនៃស្ថាប័នរដ្ឋ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តអំណាចផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល។ ផ្នែកស្នូលរបស់ PS-PI គឺមាន៖ (១) ការកែទម្រង់ និងការពង្រឹងស្ថាប័ន, (២) ការកែលម្អធនធានមនុស្ស និងប្រសិទ្ធភាពការងារ, (៣) ការពង្រីក និងការពង្រឹងគណនេយ្យភាព និងសុចរិតភាពក្នុងរដ្ឋបាលសាធារណៈ, (៤) ការពង្រឹងនិងការពង្រឹងអំពីប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌, និង (៥) ការពង្រឹងអភិបាលកិច្ចនៃវិស័យឯកជន និងធុរកិច្ច។ ទិដ្ឋភាពទាំងនេះបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១សំដៅជំរុញអភិបាលកិច្ច និងទំនើបកម្មស្ថាប័នឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា។

## គោលនយោបាយជាតិស្តីពីធនធានរ៉ែ ២០១៨ - ២០២៨

ក្របខ័ណ្ឌច្បាប់នៃវិស័យឧស្សាហកម្មរ៉ែរបស់កម្ពុជា - មានន័យសំដៅច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ - កំពុងស្ថិតក្នុងដំណាក់កាលប៉ិចពន្លកនៅឡើយ ហើយមិនទាន់គ្រប់គ្រាន់ទេ ដើម្បីឆ្លើយតបទៅនឹងភាពស្មុគស្មាញ តម្រូវការ ភាពចាំបាច់ និងលក្ខខណ្ឌតម្រូវដែលចេះតែកើនឡើង និងដើម្បីកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពច្រើនបែបយ៉ាង ដែលមានសក្តានុពលបង្កហានិភ័យដល់បរិស្ថាន និងសង្គម ជាពិសេសពាក់ព័ន្ធនឹងវិស័យជីករ៉ែ។ លើសពីនេះ នៅមានទិដ្ឋភាពពាក់ព័ន្ធច្រើនទៀត ដែលជះឥទ្ធិពលទៅលើ និងរងផលប៉ះពាល់ពីសកម្មភាពការជីកយករ៉ែ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់ផ្សេងទៀតដូចជា៖

**តារាងទី១៖ តួអង្គរដ្ឋដែលមានតួនាទី/ទំនួលខុសត្រូវដែលមានឥទ្ធិពលលើឧស្សាហកម្មនិស្សារណកម្ម**

| តួអង្គរដ្ឋនាំមុខគេ | ទទួលខុសត្រូវ(ជាទ្រឹស្តី)ចំពោះ |
|---|---|
| ក្រសួងបរិស្ថាន | • ការវាយតម្លៃ ការអនុម័ត និងការតាមដានការវាយតម្លៃបរិស្ថានលើសកម្មភាពពាក់ព័ន្ធនិងការជីកយករ៉ែ ដែលបានគ្រោងធ្វើ ឬកំពុងដំណើរការ<br>• ការត្រួតពិនិត្យការបំពុលបរិយាកាស<br>• ផលប៉ះពាល់ទៅលើតំបន់ការពារ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | • សិទ្ធិការងារ និងកិច្ចការពារ<br>• បញ្ហាសុវត្ថិភាពការងារ និងសុខភាព |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | • ការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានលើព្រៃឈើបម្រុងរបស់រដ្ឋនៅតាមតំបន់ដែលមានសម្បទានរ៉ែ |
| ក្រសួងធនធានទឹក និងឧតុនិយម | • ត្រួតពិនិត្យលើធនធានទឹកប្រទេសកម្ពុជា |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | • ការបោះបង្គោលព្រំដីសាធារណៈ ដីឯកជន និងដីសមូហភាព បន្ទាប់មកធ្វើការបែងចែក (ដោយមានកំណត់) ដីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច សម្រាប់កាន់កាប់ប្រើប្រាស់ជាសមូហភាព។<br>• ទ្រព្យសម្បត្តិរដ្ឋ និងបញ្ហាទាក់ទងនឹងវិវាទដីធ្លី |
| ក្រសួងអភិវឌ្ឍន៍ជនបទ | • ទទួលខុសត្រូវលើការអភិវឌ្ឍរបស់ជនជាតិដើមភាគតិច |
| ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | • ដឹកនាំលើគ្រប់ទិដ្ឋភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ, ការងារវិមជ្ឈការ និងសហវិមជ្ឈការ ដែលហៅជាទូទៅថាជាកំណែទម្រង់ "ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ" និងគណនេយ្យភាពសង្គមពាក់ព័ន្ធនឹងការផ្តល់សេវាកម្មរបស់រាជរដ្ឋាភិបាល។ |

នៅខែឧសភា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ធនធានរ៉ែ ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងវិស័យរ៉ែ ក្នុងនោះមាន៖ (១) ការគ្រប់គ្រងខ្វះប្រសិទ្ធផលលើធនធានរ៉ែ និងការប្រមូលចំណូល និង (២) សកម្មភាពអភិវឌ្ឍន៍ដែលប៉ះពាល់ដល់បរិស្ថាន និងសហគមន៍មូលដ្ឋាន។ គោលនយោបាយនេះឆ្លុះបញ្ចាំងចក្ខុវិស័យ គោលបំណង គោលដៅ និងតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានរ៉ែមានតម្លៃ។ គោលនយោបាយនេះដាក់ចេញយុទ្ធសាស្ត្រ និងក្របខ័ណ្ឌសកម្មភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលនយោបាយនេះកំពុងស្ថិតក្រោមការពិនិត្យពាក់កណ្តាលអាណត្តិឡើងវិញ ដោយក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តរបស់វា។

**តារាងទី២៖ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ធនធានរ៉ែ (២០១៨)**

| | | | | | |
|---|---|---|---|---|---|
| ចក្ខុវិស័យ | អភិវឌ្ឍធនធានរ៉ែ ដើម្បីជាប្រយោជន៍ដល់សេដ្ឋកិច្ច និងសង្គម ដោយគិតគូរពី អភិបាលកិច្ចល្អ និងការទទួលខុសត្រូវបរិស្ថាន។ | | | | |
| គោលដៅ | ១) គ្រប់គ្រងនិងអភិវឌ្ឍធនធានរ៉ែប្រកបដោយនិរន្តរភាព។<br>២) នាំមកនូវផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។<br>៣) ផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសំណង់។<br>៤) បង្កើតប្រភពចំណូលថ្មីសម្រាប់ថវិកាជាតិ។ | | | | |
| គោលបំណង | ១<br>ការពង្រឹងស្ថាប័នសាធារណៈក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានរ៉ែ | ២<br>លើកកម្ពស់និរន្តរភាពនិងការទទួលខុសត្រូវលើប្រតិបត្តិការរុករករ៉ែ | ៣<br>អភិវឌ្ឍធនធានរ៉ែ និង សហគមន៍ | ៤<br>អភិវឌ្ឍសិប្បករនិងការជីកយករ៉ែខ្នាតតូច | ៥<br>ធនធានរ៉ែនិងការនាំចេញ |
| យុទ្ធសាស្ត្រ | ១. ច្បាប់និង បទប្បញ្ញត្តិ<br>២. ការកសាងសមត្ថភាពសម្រាប់ មន្ត្រី និងអភិវឌ្ឍ ន៍ធនធានមនុស្ស<br>៣. ការបង្កើតបញ្ជីសារពើភ័ណ្ឌធនធានរ៉ែ<br>៤. អភិបាលកិច្ច និងការគ្រប់គ្រងល្អ អមដោយ គណនេយ្យភាពនិង តម្លាភាព<br>៥. ការជម្រុញការវិនិយោគ | ១. ការអនុវត្តវិធីសាស្ត្រការអភិវឌ្ឍប្រកបដោយចីរភាព<br>២. គ្រប់គ្រងបរិស្ថាន<br>៣. ការធានាសុវត្ថិភាពរ៉ែ<br>៤. ការធ្វើឱ្យ ប្រសើរផលិតផលរ៉ែ<br>៥. ការអភិវឌ្ឍនៃធនធានរ៉ែ និងតំបន់ការពារធម្មជាតិ | ១. ការអភិវឌ្ឍសហគមន៍<br>២. ការប្រើប្រាស់ពលកម្មក្នុងស្រុកនិងការងារយេនឌ័រ<br>៣. ជនជាតិដើមភាគតិចនិងប្រតិបត្តិការរ៉ែ | ១. សិប្បករនិងការជីកយករ៉ែខ្នាតតូច<br>២. វិធានការនិងដំណោះស្រាយលើការជីកយករ៉ែមិនមានការអនុញ្ញាត | ១.គោលនយោបាយនាំចេញ<br>២. ការនាំចេញផលិតផលរ៉ែ និងតម្រូវការតម្លៃបន្ថែមខ្ពស់<br>៣. ការសម្របសម្រួលពាណិជ្ជកម្ម |

## វិស័យទេសចរណ៍និងអត្ថប្រយោជន៍

វិស័យទេសចរណ៍[8] គឺជាក្បាលម៉ាស៊ីនដ៏សំខាន់មួយសម្រាប់កំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ប៉ុន្តែ ពេលនេះជាការចាំបាច់មួយដែលកម្ពុជាគួរចាប់យកទម្លាប់អនុវត្តទេសចរណ៍ប្រកបដោយនិរន្តរភាព ធ្វើពិពិធកម្មជម្រើសទេសចរណ៍របស់ខ្លួន និងធានាឱ្យមានការចែកចាយប្រកបដោយសមធម៌នូវអត្ថប្រយោជន៍ ដើម្បីបង្កើនសក្តានុពលរបស់វិស័យនេះសម្រាប់ការអភិវឌ្ឍយូរអង្វែង។ តាមការរំពឹងទុក ការរីកចម្រើននៃឧស្សាហកម្មទេសចរណ៍នឹងមានឥទ្ធិពលវិជ្ជមានទៅលើវិស័យផ្សេងទៀត ដូចជា ផ្នែកបដិសណ្ឋារកិច្ច អាជីវកម្មលក់ដុំ និងលក់រាយ ការដឹកជញ្ជូន និងផ្នែកប្រាស្រ័យទាក់ទង។ ការពឹងពាក់គ្នាទៅវិញទៅមកនេះបង្កើតឱ្យមានឱកាស

8 https://www.adb.org/sites/default/files/linked-documents/46293-004-ea.pdf

អាជីវកម្មបន្ថែមទៀត ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងឧស្សាហកម្មពាក់ព័ន្ធពាក់ព័ន្ធដែរ។ ជាក់ស្តែង ការចូលរួមចំណែកផ្ទាល់របស់ឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ ដល់ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់កម្ពុជា គឺមានច្រើនគួរសមគឺ ១១,៥% នៃផ.ស.ស ហើយនៅក្នុងនោះ ចំណូលពីទេសចរណ៍ដែលសមមូលនឹង ២,២ប៊ីលានដុល្លារអាមេរិក កាន់តែបង្ហាញច្បាស់ថែមទៀតអំពីសារៈសំខាន់សេដ្ឋកិច្ចរបស់វិស័យនេះ។ វិស័យទេសចរណ៍ គឺជាប្រភពការងារដ៏សំខាន់ ដោយផ្តល់ការងារចំនួន ៧៨២ ៥០០កន្លែង ដែលស្មើនឹង ១២,៤% នៃការងារសរុបនៅកម្ពុជា។ ត្រង់នេះបង្ហាញពីផលជះវិជ្ជមានទៅលើសេដ្ឋកិច្ចសង្គម ព្រោះវារួមចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាផ្តល់ឱកាសដល់ក្រុមជនក្រីក្រ ងាយរងគ្រោះ និងស្ត្រីផងដែរ។

## ក្រមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ២០២៣

ចាប់តាំងពីឆ្នាំ ២០១៥ មក រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់នូវភាពចាំបាច់ឱ្យមានកិច្ចប្រឹងប្រែងកាន់តែច្រើនឡើង នៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងបានធ្វើការប្តេជ្ញាចិត្តផ្នែកនយោបាយ ចំពោះការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តនេះ រាជរដ្ឋាភិបាលបានអនុម័តក្រមបរិស្ថាន និងធនធានធម្មជាតិ នៅខែមិថុនា ឆ្នាំ២០២៣។ ក្រមនេះមានគោលបំណងយុទ្ធសាស្ត្រច្រើនផ្នែក រួមមានការធានាឱ្យបាននូវការអភិវឌ្ឍ និងនិរន្តរភាព។ ក្រមនេះផ្តល់ទិសដៅយុទ្ធសាស្ត្ររួមមួយសម្រាប់កិច្ចគាំពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ដើម្បីជាមូលដ្ឋានសម្រាប់ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ។ គោលដៅសំខាន់មួយនៃក្រមនេះ គឺសំដៅពង្រឹង និងពង្រីកសមត្ថភាពរបស់ក្រសួង ស្ថាប័នទាំងអស់ ដើម្បីចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ។

ក្រមនេះ ដែលគ្រប់គ្រងរួមគ្នាដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចែងមាត្រាស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព (SPP) នៅកម្ពុជា។ កាតព្វកិច្ចនៅក្រោមមាត្រាទាំងនេះមាន៖

### សម្រង់អត្ថបទក្រមបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធជាមួយក្រសួងសំខាន់ៗសម្រាប់បង្កើត SPP នៅកម្ពុជា

**មាត្រា៩១នៃក្រមចែងអំពីគោលបំណងសំខាន់នៃលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ដូចតទៅ៖**

ក) ជំរុញការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។

ខ) កំណត់ប្រភេទ និងចំណាត់ថ្នាក់អាទិភាពនៃផលិតផល និងសេវាកម្មដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានបង្កើតឡើងដូចជាបច្ចេកវិទ្យាដែលមានមេត្រីបរិស្ថាន មានសុវត្ថិភាព និរន្តរភាព និងហិរញ្ញវត្ថុបៃតង ដើម្បីកំណត់ប្រភេទ និងចំណាត់ថ្នាក់អាទិភាពនៃផលិតផល និងសេវាកម្មនៅក្នុងលទ្ធកម្ម។

គ) ការកំណត់លក្ខណៈវិនិច្ឆ័យបរិស្ថានអប្បបរមា និងលក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិការ។

ឃ) ការបង្កើតលក្ខខណ្ឌតម្រូវរាយការណ៍សម្រាប់ការរៀបចំរបាយការណ៍ អំពីប្រភេទផលិតផល និងសេវាកម្មដែលបានធ្វើលទ្ធកម្ម និងកម្រិតលទ្ធកម្ម។

ង) ផ្តល់ការណែនាំបច្ចេកទេសដើម្បីគាំទ្រដល់ដំណើរការធ្វើការសម្រេចចិត្ត ដែលរក្សាតុល្យភាពរវាងលក្ខណៈវិនិច្ឆ័យបរិស្ថាន និងការពិចារណាលើការបញ្ហាទិញនានា មានដូចជា កត្តាសេដ្ឋកិច្ច ការចំណាយ គុណភាព តម្រូវការប្រតិបត្តិការ និងការគ្រប់គ្រងនាចុងបញ្ចប់នៃជីវិតរបស់ផលិតផល ឬសេវា។

ច) កំណត់ការពិន័យចំពោះការមិនអនុលោមតាមច្បាប់កំណត់យ៉ាងច្បាស់លាស់ ចំពោះបុគ្គល ឬអង្គភាពដែលបំពាន ឬរំលោភលើលក្ខខណ្ឌ និងលក្ខខណ្ឌតម្រូវទាក់ទងនឹងផលិតកម្ម និងប្រតិបត្តិការសេវាកម្មដែលមានមេត្រីបរិស្ថាន។

ឆ) អនុវត្តវិធានការគណនេយ្យភាព ដោយបង្កើតវិធានការសម្រាប់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវលើលទ្ធកម្ម ដើម្បីលើកទឹកចិត្ត និងគាំទ្រភាគីពាក់ព័ន្ធទាំងអស់ ឱ្យមានគណនេយ្យភាពនៅក្នុងអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរ/លទ្ធកម្មសាធារណៈបៃតង។

មាត្រា ៩២ ចែងថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយ ក្រសួងទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបង្កើតនីតិវិធី និងដំណើរការសម្រាប់ SPP។

ក្រមនេះបានចូលជាធរមានហើយក្រោយពីត្រូវបានអនុម័តនៅឆ្នាំ២០២៣ ប៉ុន្តែ វាត្រូវបានក្រសួងទទួលខុសត្រូវ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ចាត់ទុកថានៅជាឯកសារច្បាប់ទូទៅសម្រាប់ SPP នៅឡើយ។ ត្រង់នេះសបញ្ជាក់អំពីតម្រូវការបន្ទាន់ឱ្យមានការរៀបចំអភិក្រមគ្រប់ជ្រុងជ្រោយមួយ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយបច្ចុប្បន្ន។ ក្រសួងទទួលខុសត្រូវផ្ទាល់ មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន គួរដើរតួដឹកនាំរៀបចំអភិក្រមស្តីពី SPP នេះ ដោយមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍។ ក្របខ័ណ្ឌនៃអភិក្រមនេះគួរតែផ្តោតលើការលើកកម្ពស់ការយល់ដឹង ពង្រឹងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដ៏រឹងមាំ និងការពង្រឹងយន្តការអនុវត្តច្បាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ការផ្តល់ធនធាន និងជំនាញគ្រប់គ្រាន់ លើកកម្ពស់វប្បធម៌និរន្តរភាព និងបង្កើតបរិយាកាសអំណោយផលសម្រាប់ការចូលរួមរបស់ក្រុមហ៊ុនឯកជន គឺជាធាតុផ្សំដ៏សំខាន់សម្រាប់វិធីសាស្ត្រនេះ។




គំនូសតាងទី៤៖ការសម្រប SCP និង SPP ជាមួយគោលនយោបាយ និងក្របខ័ណ្ឌច្បាប់របស់កម្ពុជា

ក្រមបរិស្ថានឆ្នាំ២០២៣ នេះ គឺជាច្បាប់បរិស្ថានគ្រប់ជ្រុងជ្រោយមួយរបស់កម្ពុជា ដែលរួមមាន ១២ជំពូក និង ៨៦៥មាត្រា។ វាជាសមិទ្ធផលដ៏សំខាន់មួយនៅក្នុងការគ្រប់គ្រងបរិស្ថាន និងផ្តល់ឱកាសដ៏មានតម្លៃមួយសម្រាប់ក្រុមការងារអន្តរក្រសួងស្តីពី SCP ដែលដឹកនាំដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង ក្រសួងបរិស្ថាន ក្នុងការបង្កើត និងលើកកម្ពស់ការអភិវឌ្ឍបៃតងតាមរយៈការអនុវត្ត SCP និង SPP នៅកម្ពុជា។

## ច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០២៣

កម្ពុជាបានទទួលស្គាល់សារៈសំខាន់នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព និងបានចាត់វិធានការដើម្បីបញ្ចូលវាទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ខ្លួន។ ការអនុម័តច្បាប់លទ្ធកម្មសាធារណៈកាលពីខែឧសភា ឆ្នាំ២០២៣ គឺជាសក្ខីកម្មនៃការប្តេជ្ញាចិត្ត ក្នុងការដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីគោលការណ៍និរន្តរភាពទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថានភាពជុំវិញលទ្ធកម្មសាធារណៈបៃតងអាចមានការវិវឌ្ឍប្រែប្រួល ហេតុនេះ ទំងជាមានកិច្ចខិតខំរៀបចំ SPP នឹងគិតគូរស៊ីជម្រៅ ដើម្បីធ្វើឱ្យសុខដុមនីយកម្មក្នុងការអនុវត្តកិច្ចលទ្ធកម្មដោយប្រសិទ្ធភាព ជាមួយនឹងការធានាចំណាយដោយប្រសិទ្ធផល។ ការសង្កត់ធ្ងន់របស់រាជរដ្ឋាភិបាលលើការគិតគូរពីនិរន្តរភាពនៅក្នុងការអភិវឌ្ឍ និងបរិស្ថាន តាមរយៈគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងកម្មវិធីនយោបាយ ជាតម្រុយមួយដឹងថាការរៀបចំឱ្យមានបរិយាកាសអំណោយផលមួយ សម្រាប់ការរួមបញ្ចូលទម្លាប់អនុវត្តន៍លទ្ធកម្មបៃតងទៅក្នុងសាធារណៈក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុ នឹងក្លាយជាចំណុចផ្តោតយកចិត្តទុកដាក់នាពេលឆាប់ៗខាងមុខនេះ។

ជាការឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជំរុញអនុវត្ត SPP នៅកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចខិតខំប្រឹងប្រែងសំខាន់ៗជំនួសមុខឱ្យរាជរដ្ឋាភិបាល ក្នុងការអនុម័តច្បាប់វិសោធនកម្មច្បាប់លទ្ធកម្មសាធារណៈ នៅខែឧសភា

ឆ្នាំ២០២៣។ ច្បាប់នេះត្រូវបានដៃគូអភិវឌ្ឍន៍សំខាន់ៗ វិស័យឯកជន អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត ទទួលស្គាល់ថាជាជំហានគួរឱ្យកត់សម្គាល់ឆ្ពោះទៅរកការលើកកម្ពស់ SCP និង SPP នៅកម្ពុជា។ អ្វីដែលជាសារៈសំខាន់ពិសេសនោះ គឺមាត្រា ៥៦ នៃច្បាប់ ដែលចែងថា "ការអនុវត្តលទ្ធកម្មសាធារណៈត្រូវអនុលោមតាមបរិបទនៃលទ្ធកម្មប្រកបដោយនិរន្តរភាព។ លទ្ធកម្មប្រកបដោយនិរន្តរភាពទាមទារឱ្យមានការបញ្ជាក់លក្ខណៈបច្ចេកទេស លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យជាក់លាក់ច្បាស់លាស់ ដែលផ្តល់អាទិភាពដល់ការការពារ និងការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន ទៅលើសេដ្ឋកិច្ច និងសង្គម។ លក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព ត្រូវកំណត់ដោយអនុក្រឹត្យ"។

ការដាក់បញ្ចូលមាត្រា ៥៦ ទៅក្នុងច្បាប់លទ្ធកម្មសាធារណៈ បង្កើតបានជាមូលដ្ឋានគ្រឹះមួយសម្រាប់ប្រទេសកម្ពុជា និងដៃគូរបស់ខ្លួន សម្រាប់ការបន្តជំរុញ SPP និងរួមចំណែកដល់គោលដៅទូលំទូលាយនៃការលើកកម្ពស់ SCP នៅទូទាំងប្រទេស។

ដូចត្រូវបានលើកឡើងនៅខាងលើ ច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០២៣នេះ តម្រូវឱ្យមានអនុក្រឹត្យស្តីពី SPP ក្នុងគោលដៅប្រែក្លាយមហិច្ឆតា SPP នៅក្នុងច្បាប់លទ្ធកម្មសាធារណៈ ឱ្យទៅជាក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងមុខងារ រចនាសម្ព័ន្ធ តួនាទីទំនួលខុសត្រូវ និងគណនេយ្យភាពរបស់ស្ថាប័ននានាសម្រាប់អនុវត្ត SPP ឱ្យមានប្រសិទ្ធភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លើសពីនេះ វាចាំបាច់ណាស់ក្នុងការរៀបចំឡើងនូវបទប្បញ្ញត្តិជាក់លាក់ រួមដោយម៉ូឌុល និង/ឬគោលការណ៍ណែនាំលម្អិតសម្រាប់អនុវត្តអនុក្រឹត្យស្តីពី SPP ដែលនឹងត្រូវបង្កើតឡើងឱ្យមានប្រសិទ្ធភាព។ បន្ថែមលើនេះ ការគាំទ្រដល់ការកសាងសមត្ថភាព និងចែករំលែកចំណេះដឹងដល់មន្ត្រីរដ្ឋាភិបាលដែលធ្វើការនៅក្នុងក្រសួងថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាកិច្ចការសំខាន់មួយដែរដែលត្រូវធ្វើ។ តាមរយៈលក្ខខណ្ឌតម្រូវទាំងនេះ ដៃគូអភិវឌ្ឍន៍សំខាន់ៗនឹងត្រៀមខ្លួនចូលរួមធ្វើការពិភាក្សាផ្លូវការជាមួយក្រសួងជំនាញមានអាណត្តិកិច្ច ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ដើម្បីបន្តស្វែងរកមើលឱកាសសម្រាប់ធ្វើការឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។ អភិក្រមបែបសហការគ្នានេះ នឹងជួយធានាឱ្យមានការអនុវត្តដោយជោគជ័យនូវ SPP នៅកម្ពុជា និងជំរុញឱ្យមានការគាំទ្រ និងធនធានចាំបាច់ ដល់មន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ។

ដូចមានចែងនៅក្នុងបទប្បញ្ញត្តិទូទៅនៃច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០២៣ មាត្រា ២ បានគូសបញ្ជាក់យ៉ាងច្បាស់ពីវិសាលភាពរបស់ច្បាប់ ដែលគ្របដណ្តប់លើលទ្ធកម្មសាធារណៈទាំងអស់ក្នុងប្រទេស ដោយមិនគិតពីប្រភពនៃមូលនិធិ លើកលែងតែករណីមួយចំនួននៅខាងក្រោម៖

- លទ្ធកម្មក្រោមគម្រោងមានហិរញ្ញប្បទានពីក្រៅប្រទេស ដែលគាំទ្រដោយម្ចាស់ជំនួយផ្សេងៗ ត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំ និងនីតិវិធីដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទានរបស់គម្រោងនោះ។ ក្នុងករណីដែលកិច្ចព្រមព្រៀងមិនបានកំណត់គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់គម្រោងទេ ដំណើរការលទ្ធកម្មត្រូវតែអនុវត្តដោយអនុលោមតាមច្បាប់លទ្ធកម្មសាធារណៈ។
- លទ្ធកម្មដែលស្ថិតនៅក្រោមច្បាប់ស្តីពីភាពជាដៃគូសាធារណៈ និងឯកជន (PPP Law) ត្រូវតែអនុវត្តតាមប្រការ និងបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាក់លាក់នោះ។
- លទ្ធកម្មទាក់ទងនឹងបញ្ហាសម្ងាត់ក្នុងវិស័យការពារជាតិ និងសន្តិសុខសាធារណៈ ត្រូវមានការឯកភាពពីនាយករដ្ឋមន្ត្រី។

ករណីលើកលែងទាំងនេះ បានគូសបញ្ជាក់ពីកាលៈទេសៈជាក់លាក់ដែលដំណើរការលទ្ធកម្មអាចធ្វើទៅបាននៅក្រៅបទប្បញ្ញត្តិទូទៅនៃច្បាប់លទ្ធកម្មសាធារណៈ។ វារំលេចឱ្យឃើញពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវកិច្ចព្រមព្រៀងហិរញ្ញវត្ថុ បទប្បញ្ញត្តិនៃច្បាប់ស្តីពីភាពជាដៃគូសាធារណៈ និងឯកជន និងការគិតគូរអំពីសន្តិសុខជាតិ ស្របគ្នាជាមួយការទទួលស្គាល់ការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ ក្នុងករណីដែលគោលការណ៍ណែនាំ និងនីតិវិធីជាក់លាក់មិនត្រូវបានកំណត់។

ដោយមើលឃើញពីស្ថានភាពនេះ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងសកម្មភាព SCP និង SPP គួរតែមានការប្រុងប្រយ័ត្នដែរនៅក្នុងបន្តជំរុញឱ្យមានសហកម្ម និងធ្វើកិច្ចពិភាក្សាជាមួយក្រសួងសំខាន់ៗ ជាពិសេសជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។ គោលដៅគួរតែមានការព្រមព្រៀងមួយស្តីពីផែនទីចង្អុលផ្លូវជាតិសម្រាប់ SPP ក្នុងបរិបទនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ លើសពីនេះ គួរតែមានកិច្ចខិតខំប្រឹងប្រែងដែរដើម្បីសម្របការគាំទ្ររបស់ពួកគេជាមួយតម្រូវការអាទិភាព បញ្ហាប្រឈម និងពេលវេលារបស់រដ្ឋាភិបាល សម្រាប់រៀបចំបង្កើតបទប្បញ្ញត្តិ គម្រោងសាកល្បង និងការអនុវត្តនៃបទប្បញ្ញត្តិ និងការណែនាំ។

កង្វះការយល់ដឹង និងសមត្ថភាពទាក់ទងនឹង SPP នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ក៏ជាបញ្ហាប្រឈមមួយដែរចំពោះការអនុវត្ត SPP នៅកម្ពុជា។ ជាការឆ្លើយតបទៅនឹងបញ្ហានេះ សំខាន់គួរពិចារណាលើការដាក់បញ្ចូល

បទប្បញ្ញត្តិស្តីពី SPP ទៅក្នុងអនុក្រឹត្យ អមជាមួយនឹងបង្កើតបទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ SPP ដែរ។ វិធានការទាំងនេះនឹងជួយលើកទឹកចិត្តដល់ការពង្រឹងស្ថាប័ន និងដល់កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព សំដៅសម្របសម្រួលការអនុវត្តការអនុវត្ត SPP នៅកម្ពុជា ឱ្យសម្រេចបានជោគជ័យ។




**គំនូសតាងទី៥៖ រចនាសម្ព័ន្ធច្បាប់ និងស្ថាប័ននៃលទ្ធកម្មសាធារណៈ ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

## ៣.២ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌច្បាប់ជាតិ

### ការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកលឱ្យទៅជាក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)

នៅខែកញ្ញា ឆ្នាំ២០១៥ កម្ពុជា រួមជាមួយរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិទាំងអស់ បានធ្វើការអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលរបៀបវារៈប្រកបដោយមហិច្ឆតាជាងមុន សម្រាប់រយៈពេលឆ្នាំ២០១៦-២០៣០។ ដោយយល់ឃើញពីសារៈសំខាន់នៃការសម្របគោលដៅសកលទាំងនេះទៅនឹងបរិការណ៍ជាតិ រាជរដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌ SDGs របស់កម្ពុជា (CSDGs) នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ។ ក្របខ័ណ្ឌ CSDGs ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាតិនៅតាមវិស័យ។ កម្ពុជាបានជ្រើសរើសយក SDGs ទាំង ១៧ ដោយបន្ថែមគោលដៅអភិវឌ្ឍន៍មួយទៀតទាក់ទងនឹងការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលឆ្លុះបញ្ចាំងពីអាទិភាពរបស់ប្រទេស។

ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល CSDGs ត្រូវបានច្របាច់ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (RS-IV) និងទៅក្នុងចក្ខុវិស័យរបស់កម្ពុជា ក្នុងការឈានទៅក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០៣០ និងដែលមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៥០។ ឯកសារយុទ្ធសាស្ត្រទាំងនេះបង្កើតជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣។ NSDP បង្ហាញពីការប្ដេជ្ញាចិត្តឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម លើកកម្ពស់និរន្តរភាព និងរួមចំណែកយ៉ាងសកម្មដល់កិច្ចខិតខំប្រឹងប្រែងជាសកល ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ ការប្ដេជ្ញាចិត្តនេះ ត្រូវបានធ្វើការសង្កត់ធ្ងន់បន្ថែមទៀតនៅក្នុងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) សម្រាប់ឆ្នាំ២០១៤-២០២៣។ តាមរយៈផែនការទាំងនេះ រាជរដ្ឋាភិបាលមានគោលដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាព លើកកម្ពស់កំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហាប្រឈមដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។

ក្របខ័ណ្ឌ CSDG របស់កម្ពុជា ត្រូវបានរៀបចំឡើងដោយស្របតាមផលប្រយោជន៍ និងអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា។ ជាលទ្ធផល CSDGs មាន ១៨គោលដៅ, ៨៨ចំណុចដៅ និង ១៤៨សូចនាករ ដែលបានកំណត់ជាសកល និងក្នុងស្រុក ហើយក្នុង

នោះ ៩៦ ត្រូវកំណត់ថាជាសូចនាករជាតិ។ គោលដៅគួរឱ្យកត់សម្គាល់នៅក្នុង CSDGs គឺគោលដៅទី ១២ ដែលផ្តោតលើការធានាឱ្យមានលំនាំនៃការប្រើប្រាស់ និងបែបផែនផលិតកម្មប្រកបដោយនិរន្តរភាព។ គោលដៅនេះតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីក្រសួងសំខាន់ៗ មាន ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាក្រសួងនាំមុខគេ។ ក្រសួងពាក់ព័ន្ធដទៃទៀតដែលទទួលខុសត្រូវលើវិស័យឧស្សាហកម្ម, កសិកម្ម, ពាណិជ្ជកម្ម, សុខាភិបាល និងការងារសាធារណៈ ត្រូវចូលរួមសហការគ្នាដើម្បីសម្រេចបាននូវការប្តេជ្ញាចិត្តនេះ។ ការដាក់បញ្ចូលសូចនាករជាក់លាក់ និងកិច្ចសហការក្នុងចំណោមក្រសួងនានា បង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ទម្លាប់អនុវត្តប្រកបដោយនិរន្តរភាព និងជំរុញការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវ នៅកម្ពុជា។




គំនូសតាងទី៦៖ ស្ថាប័ននិងភ្នាក់ងារមានសមត្ថកិច្ចសម្រាប់សហការនិងសម្របសម្រួល CSDG 12

## យុទ្ធសាស្រ្តបញ្ចកោណ - ដំណាក់កាលទី១

ថ្មីៗនេះ រាជរដ្ឋាភិបាលនីតិកាលទីប្រាំពីរនៃរដ្ឋសភា បានដាក់ចេញយុទ្ធសាស្រ្តបញ្ចកោណ - ដំណាក់កាលទី ១ (២០២៣-២០២៨) ស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ យុទ្ធសាស្ត្រនេះផ្តោតលើការធ្វើឱ្យមាននូវកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងនិរន្តរភាព។ បញ្ចកោណ ៤ ត្រូវបានកំណត់ថាជាយុទ្ធសាស្រ្តមួយក្នុងចំណោមយុទ្ធសាស្រ្តបញ្ចកោណទាំងប្រាំដែលរួមចំណែកដល់ "ការអភិវឌ្ឍប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន" នៅកម្ពុជា។ វិធីសាស្រ្តគ្រប់ជ្រុងជ្រោយនេះមានគោលដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ដូចជាសកលភាវូបនីយកម្ម និរន្តរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្រ្តនេះជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំផែនការជាតិអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ២០២៤-២០២៨ ដែលនឹងនាំផ្លូវកម្ពុជាក្នុងការធ្វើអន្តរកម្មពីស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួច និងពន្លឿនការសម្រេចបាន CSDGs នៅឆ្នាំ២០៣០។

ដូចដែលបានបញ្ជាក់រួចមកហើយ យុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី ១ រួមជាមួយចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត មាន ក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ២០២៣ នឹងក្លាយជាមូលដ្ឋានគ្រឹះនៃការបង្កើតផែនការជាតិអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០២៣-២០២៨ ។ ផែនការនេះមានគោលដៅធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនូវផែនការអភិវឌ្ឍន៍ជាតិ និងតាមវិស័យ ការរៀបចំថវិកា និងការត្រួតពិនិត្យ និងតាមដានមើលយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលដែលទើបនឹងបង្កើតថ្មី។ តាមរយៈក្របខ័ណ្ឌយុទ្ធសាស្រ្តទាំងនេះ កម្ពុជាអាចចាក់គ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងបរិយាបន្ន ដោយតម្រង់គោលនយោបាយ និងធនធានឆ្ពោះទៅរកការសម្រេចគោលដៅរយៈពេលវែងរបស់ខ្លួន។

## គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង

ដោយទទួលស្គាល់ផលប៉ះពាល់ចម្រុះពីការប្រែប្រួលអាកាសធាតុទៅលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច បរិស្ថាន និងជីវភាពរបស់ប្រជាជន រដ្ឋាភិបាលបានបង្កើតគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ដោយមានកិច្ចសហការរបស់ក្រសួងបរិស្ថាន ក្រសួងពាក់ព័ន្ធ គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) ក្រុមសង្គមស៊ីវិល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍។ គោលនយោបាយនេះជាក្របខ័ណ្ឌយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយមួយ សំដៅលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព ការពារបរិស្ថាន ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកំពស់សុខុមាលភាពរបស់ប្រជាជន។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង មានចក្ខុវិស័យឈានទៅធ្វើឱ្យមាន "តុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថាន" និងការលើកកម្ពស់ "កំណើនបៃតងបញ្ចេញកាបូនទាប"។ គោលការណ៍ណែនាំទាំងនេះមានគោលដៅប្រែក្លាយបញ្ហាប្រឈមអាកាសធាតុទៅជាឱកាស និងរួមចំណែកដល់ការសម្រេចបាននូវ CSDGs។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងសង្កត់ធ្ងន់ច្រើនលើការដោះស្រាយបញ្ហាប្រឈមបរិស្ថាន ការលើកកម្ពស់និរន្តរភាព និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ តាមរយៈការអនុវត្តគោលនយោបាយនេះ កម្ពុជាអាចបើកសក្តានុពលសម្រាប់នាំមកនូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងដោយបរិយាបន្ន តាមរយៈបច្ចេកវិទ្យាបៃតង ឧស្សាហកម្មប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធផល។ ការបញ្ចូលការគិតគូរអំពីបរិស្ថានទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច នឹងធ្វើឱ្យសេដ្ឋកិច្ចកាន់តែរីកចម្រើន និងកាន់តែមានភាពធន់ ជាប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត ថែរក្សាបរិស្ថានធម្មជាតិឱ្យបានគង់វង់យូរទៀតផង។

## យុទ្ធសាស្ត្រ និងផែនការសកម្មភាពសេដ្ឋកិច្ចចក្រា (២០២១)

ប្រទេសកម្ពុជាបានធ្វើការប្តេជ្ញាចិត្តចំពោះសេដ្ឋកិច្ចចក្រា (CE) ជាផ្នែកមួយនៃកិច្ចខិតខំអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ខ្លួន នៅក្រោមហេតុផលជាច្រើន ក្នុងនោះហេតុផលមួយ គឺថា CE នឹងបង្កលក្ខណៈសម្រាប់ការកែលម្អទិដ្ឋភាពជាច្រើននៃសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស។



**គំនូសតាងទី៧៖ការពិពណ៌នាអំពីខ្សែចង្វាក់នៅក្នុងសេដ្ឋកិច្ចចក្រា**

សេដ្ឋកិច្ចចក្រាត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជា វិធីសាស្ត្រមានប្រសិទ្ធភាពមួយសម្រាប់គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ CSDG និងរួមចំណែកដល់គោលដៅ SDGs ដែលពាក់ព័ន្ធ។ នៅក្នុងនោះ មានគោលដៅ SDG 1 (គ្មានភាពក្រីក្រ), SDG 3 (សុខភាពល្អ និងសុខុមាលភាព), SDG 4 (ការអប់រំប្រកបដោយគុណភាព), SDG 5 (សមភាពយេនឌ័រ), SDG 6 (ទឹកស្អាត និងអនាម័យ), SDG 7 (ថាមពលមានតម្លៃសមរម្យ និងស្អាត), SDG 8 (ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច), SDG 9 (នវានុវត្តន៍ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ), SDG 11 (ទីក្រុង និងសហគមន៍មាននិរន្តរភាព), SDG 12 (ការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវ), SDG 13 (សកម្មភាពអាកាសធាតុ), SDG 14 (ជីវិតខាងក្រោមទឹក), SDG 15 (ជីវិតនៅលើដី) និង SDG 17 (ភាពជាដៃគូសម្រាប់គោលដៅ)។

ជាមូលដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហការជាមួយតួអង្គនៅតាមវិស័យនានា រួមមានស្ថាប័នសាធារណៈ ទីក្រុងធំៗ ដៃគូអភិវឌ្ឍន៍ អ្នកគ្រប់គ្រងកាកសំណល់ ស្ថាប័នសិក្សា អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកប្រើប្រាស់។ អភិក្រមសេដ្ឋកិច្ចចក្រា ទទួលស្គាល់តម្រូវការបន្ទាន់សម្រាប់ធ្វើការពាក់ព័ន្ធយ៉ាងសកម្ម និងលើកទឹកចិត្តដល់វិស័យឯកជន នៅក្នុងការជំរុញនវានុវត្តន៍ កៀរគរការវិនិយោគបន្ថែម និងចាប់យកបែបផែនធុរកិច្ចសេដ្ឋកិច្ចចក្រា ដើម្បីលើកកម្ពស់ផលិតកម្ម និងធុរកិច្ចប្រកបដោយនិរន្តរភាព។

# ជំពូកទី៤៖ ឧត្តមានុវត្តន៍ និងមេរៀនដកបទពិសោធន៍

## ៤.១ ការពិភាក្សាអំពីគំហើញ

### ផ្នែកសំខាន់ទី១៖ ក្របខ័ណ្ឌស្ថាប័ននិងសមត្ថភាពគ្រប់គ្រង

ការពិភាក្សាថ្មីជាមួយដៃគូសំខាន់ៗ រួមមាន GIZ, ធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ក្រោមការសម្របសម្រួលដោយប្រតិភូសហភាពអឺរ៉ុបនៅកម្ពុជា បានរំលេចឱ្យឃើញថា ការកសាងសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន ជាទិដ្ឋភាពសំខាន់មិនត្រឹមតែសម្រាប់ SCP និង SPP ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់របៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ពាក់ព័ន្ធផងដែរជាមួយការបញ្ចូលបច្ចេកវិទ្យាច្នៃនវានុវត្តន៍ មានដូចជាលទ្ធកម្មអេឡិចត្រូនិច ទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈដែល និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដើម្បីធានាបានប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន កិច្ចការជាបន្ទាន់មួយដែលត្រូវធ្វើ គឺការវាយតម្លៃលម្អិតអំពីតម្រូវការបណ្តុះបណ្តាលសម្រាប់ការអនុវត្តប្រព័ន្ធលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។ ការវាយតម្លៃនេះនឹងជួយកំណត់អំពីតម្រូវការ និងបញ្ហាប្រឈមជាក់លាក់ ដែលអាចប្រើជាមូលដ្ឋានសម្រាប់បង្កើតគំរូសម្រាប់ការអនុវត្ត SPP នៅកម្ពុជា។ ជាគោលដៅ គួរតែប្រែក្លាយមុខងារលទ្ធកម្មឱ្យទៅជាជំនាញវិជ្ជាជីវៈមួយ ដើម្បីឱ្យអ្នកលទ្ធកម្មអាចកំណត់ហានិភ័យ និងឱកាសនិរន្តរភាព នៅក្នុងដំណាក់កាលធ្វើផែនការ និងចេះចាត់វិធានការសមស្រប ដើម្បីបង្កើនផលនិរន្តរភាពឱ្យបានជាអតិបរមា។ វេទិកាចែករំលែកចំណេះដឹងនៅថ្នាក់ជាតិ តំបន់ និងកម្រិតសកល ជាឧបករណ៍ដ៏មានតម្លៃសម្រាប់ជួយសម្រួលដល់ដំណើរការនេះ។

ដៃគូ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក បានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ នៅក្នុងកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបង្កើត វិធីសាស្ត្រសម្រាប់ការវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ (MAPS)។ លើសពីនេះទៀត ធនាគារពិភពលោកបានបន្តផ្តោតលើលទ្ធកម្មអេឡិចត្រូនិច និងធ្វើការវាយតម្លៃការត្រៀមខ្លួនរបស់ប្រទេស។ ការវាយតម្លៃបច្ចុប្បន្នពិនិត្យមើលការត្រៀមខ្លួននៃប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិច សម្រាប់សម្រួលការបញ្ចូលនិរន្តរភាពទៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលទ្ធកម្ម និងការតាមដានវឌ្ឍនភាពរបស់ SPP លើ KPIs ដែលបានឯកភាពគ្នារួច សម្រាប់ចំណែកបន្ថែមដល់ការអភិវឌ្ឍការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព។

អាស្រ័យហេតុនេះ ជារឿងមួយសំខាន់ណាស់ក្នុងការយល់ដឹងអំពីតម្រូវការរបស់រាជរដ្ឋាភិបាល និងកង្វះខាតផ្នែកសមត្ថភាពទាក់ទងនឹងគោលនយោបាយ ច្បាប់ និងគោលការណ៍ណែនាំ និងនីតិវិធីលម្អិតនៅក្នុង SPP។ កិច្ចប្រឹងប្រែងទាំងនេះគួរតែសម្របតាមកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលវែង, គោលដៅ CSDGs នៅតាមវិស័យឆ្ពោះទៅឆ្នាំ២០៣០ និងស្របតាមចក្ខុវិស័យកម្ពុជាសម្រាប់ឆ្នាំ២០៥០។

សរុបមក ការពិភាក្សាជាមួយដៃគូសំខាន់ៗបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការកសាងសមត្ថភាព ការអភិវឌ្ឍស្ថាប័ន និងការបញ្ចូលបច្ចេកវិទ្យានវានុវត្តន៍ទៅក្នុង SPP។ ដំណើរការវាយតម្លៃលម្អិត ការបង្កើតវេទិកាចែករំលែកចំណេះដឹង និងការឆ្លើយតបទៅនឹងតម្រូវការគោលនយោបាយ និងនីតិបញ្ញត្តិ គឺជាជំហានសំខាន់សម្រាប់គាំទ្រដល់ការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាពនៅកម្ពុជា ហើយសម្របវាជាមួយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

### ផ្នែកសំខាន់ទី២៖ ការធ្វើសមាហរណកម្មគោលការណ៍លទ្ធកម្មដោយនិរន្តរភាព ទៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ទន្ទឹមនឹងការទទួលស្គាល់សារៈសំខាន់នៃទម្លាប់អនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព កម្ពុជាបានចាត់វិធានការដើម្បីបញ្ចូលទម្លាប់អនុវត្តទាំងនោះទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ខ្លួន។ ច្បាប់លទ្ធកម្មសាធារណៈ ដែលត្រូវបានអនុម័តក្នុងខែឧសភា ឆ្នាំ២០២៣ ដោយមានការតម្រឹមលទ្ធកម្មសាធារណៈជាមួយនឹងគោលការណ៍និរន្តរភាព ជាសក្ខីភាពនៃការប្តេជ្ញាចិត្តនេះ។ លទ្ធកម្មសាធារណៈដោយនិរន្តរភាពនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចនឹងមានការវិវឌ្ឍ

ប្រែប្រួល ប៉ុន្តែទន្ទឹមគ្នានោះក៏នឹងមានកិច្ចប្រឹងប្រែងថែមទៀតដើម្បីរៀបចំទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយប្រសិទ្ធភាព ឱ្យមានសុខដុមគ្នាជាមួយការចំណាយសាធារណៈប្រកបដោយប្រសិទ្ធផល ដែរ។ ការផ្តល់សារៈសំខាន់លើការគិតគូរអំពីនិរន្តរភាពរបស់ការអភិវឌ្ឍ និងបរិស្ថានតាមរយៈគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនយោបាយជាតិ ឆ្លុះបញ្ចាំងអំពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការបង្កើតឱ្យមានបរិយាកាសអំណោយផល សម្រាប់ច្របាច់បញ្ចូលគោលការណ៍លទ្ធកម្មដោយនិរន្តរភាព ទៅក្នុងក្របខណ្ឌកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ការបញ្ចូលលទ្ធកម្មសាធារណៈដោយនិរន្តរភាពទៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងជួយឆ្លើយតបចំពោះបញ្ហាប្រឈមនានា ដែលភ្នាក់ងារលទ្ធកម្មជួបប្រទះក្នុងការប្រើគោលការណ៍ចំណាយពេញមួយវដ្តនៃផលិតផល ឬសេវា សម្រាប់ការសម្រេចចិត្តផ្តល់កិច្ចសន្យាលទ្ធកម្ម ដោយសារតែគោលការណ៍នេះដូនកាលនាំឱ្យថ្លៃដើមរបស់ផលិតផល ការងារ និងសេវាកម្មប្រកបដោយនិរន្តរភាព ឡើងខ្ពស់។

ផែនទីចង្អុលផ្លូវជាតិរបស់ SPP ត្រូវបានក្រុមការងារ SCP បង្កើតឡើងក្រោមការគាំទ្រពីកម្មវិធី SCP ប្រចាំតំបន់របស់អង្គការ GIZ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ។ ផែនទីចង្អុលផ្លូវនេះ ត្រូវបានចាត់ទុកថាជាព្រឹត្តិការណ៍ដ៏សំខាន់មួយ និងរំពឹងថានឹងត្រូវបានរៀបចំចប់សម្រាប់ការពិគ្រោះយោបល់ថ្នាក់ជាតិ ដែលគ្រោងធ្វើនៅដើមឆ្នាំ២០២៤។ គោលបំណងនៃការពិគ្រោះយោបល់នេះ គឺដើម្បីផ្តល់វេទិកាមួយសម្រាប់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន រួមទាំងក្រសួងពាក់ព័ន្ធ និងដៃគូរបស់រាជរដ្ឋាភិបាល ចាប់ផ្តើមធ្វើការពិភាក្សា និងឈានទៅបង្កើតបទប្បញ្ញត្តិជាតិសម្រាប់ SPP, សម្របសម្រួលការចែករំលែកចំណេះដឹង និងការអភិវឌ្ឍសមត្ថភាព និងផ្តួចផ្តើមគម្រោងសាកល្បងស្របតាមក្របខណ្ឌ CSDG នៅត្រឹមឆ្នាំ២០២៣។ មិនបាច់សង្ស័យទេថា អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ដោយមានការគាំទ្រពីនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក្រសួងបរិស្ថាន - មានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការចាត់វិធានការសំខាន់ៗ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានខិតខំដើម្បីធានាឱ្យបាននូវសមិទ្ធិលទ្ធភាព និងភាពពាក់ព័ន្ធតាមដំណាក់កាលសំខាន់ៗ ដែលមានចែងនៅក្នុងសេចក្តីព្រាងផែនទីចង្អុលផ្លូវ SPP។ ការប្តេជ្ញាចិត្តនេះក៏មានដែរសម្រាប់សម្របសម្រួលការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងរង្វង់អាណត្តិ និងសមត្ថភាពរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងសម្រាប់ការចូលរួមពីភាគីពាក់ព័ន្ធ រួមទាំងវិស័យឯកជន។

## ផ្នែកសំខាន់ទី៣៖ ស្ថាប័នទទួលការចាត់តាំងឱ្យបង្កើត និងអនុវត្តលទ្ធកម្មសាធារណៈបៃតង

យោងតាមច្បាប់ដែលមានជាធរមាន - មានច្បាប់លទ្ធកម្មសាធារណៈ, ក្រមបរិស្ថាន និងធនធានធម្មជាតិ និងច្បាប់ស្តីពីភាពជាដៃគូសាធារណៈ និងវិស័យឯកជន ដែលត្រូវបានអនុម័តកាលពីពេលថ្មីៗនេះ - កម្ពុជាបានចាត់តាំងក្រសួង និងស្ថាប័នមានសមត្ថកិច្ចមួយចំនួន រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស ឱ្យទទួលខុសត្រូវក្នុងការលើកកម្ពស់ និងអនុវត្តសកម្មភាព SPP។

### ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

ក្រសួងនេះជាអាជ្ញាធរឈានមុខគេក្នុងប្រព័ន្ធទាំងមូលរបស់កម្ពុជា ហើយបំពេញតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងលទ្ធកម្មសាធារណៈដែរ។ ក្រសួងទទួលខុសត្រូវលើការបង្កើតគោលនយោបាយ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំជុំវិញការអនុវត្តលទ្ធកម្ម។ ជាផ្នែកមួយនៃក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពី SCP ដែលដឹកនាំដោយនាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃក្រសួងបរិស្ថាន អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការគ្នាដោយមានគាំទ្រពីគម្រោង SCP របស់ GIZ។ ដំបូងឡើយ ក្រុមការងារនេះត្រូវបានបង្កើតឡើងសម្រាប់អនុវត្តគម្រោង SCP របស់ GIZ ប៉ុន្តែក្រោយមកទៀតមានការពិភាក្សាក្រៅផ្លូវការដែលអាចឈានទៅដាល់ពង្រីកវិសាលភាពរបស់វា ដើម្បីបញ្ចូលបញ្ហាទាក់ទង SPP។ តាមរយៈនេះ ផែនទីចង្អុលផ្លូវ G/SPP ត្រូវបានបង្កើតឡើង និងបច្ចុប្បន្នកំពុងស្ថិតក្រោមការពិគ្រោះយោបល់ក្នុងចំណោមភាគីពាក់ព័ន្ធរហូតដល់ដើមឆ្នាំ២០២៤។ ដោយយល់ឃើញថា SPP មានចែងនៅក្នុងច្បាប់លទ្ធកម្មសាធារណៈដែរ ការពិភាក្សាមួយចំនួនត្រូវបានធ្វើឡើងនាពេលថ្មីៗនេះ ដោយផ្តោតលើការបង្កើតផែនទីចង្អុលផ្លូវសាមញ្ញមួយដែលក្រសោបសកម្មភាពសំខាន់ៗ។ អភិក្រមនេះមានគោលបំណងសម្រួលដល់ការអនុវត្ត SPP និងគាំទ្រដល់ការបង្កើតអនុក្រឹត្យ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំលម្អិត។ ការកសាងសមត្ថភាព និងការកសាងស្ថាប័នសម្រាប់ការរៀបចំគោលនយោបាយ ក៏ជាការចាំបាច់ត្រូវធ្វើផងដែរ ដើម្បីធានាឱ្យមានការអនុវត្តផែនទីចង្អុលផ្លូវប្រកបដោយប្រសិទ្ធភាព។ ត្រង់នេះបង្ហាញពីការប្តេជ្ញាចិត្តក្នុងការជំរុញឱ្យមានទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាពនៅកម្ពុជា និងមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត និងការត្រួតពិនិត្យជាផ្លូវការលើ SPP។

### ក្រសួងបរិស្ថាន៖

យោងតាមក្រមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ២០២៣ ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិឱ្យមាននិរន្តរភាព។ ក្នុងន័យនេះ ក្រសួងដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់និរន្តរភាពបរិស្ថាន នៅតាមវិស័យផ្សេងៗ។ នៅក្នុងបរិបទ

នៃ SCP និង SPP, ក្រសួងបរិស្ថាន ក៏ដូចជាក្រសួងមានសមត្ថកិច្ច និងស្ថាប័នផ្សេងទៀត អាចផ្តល់ជំនាញបច្ចេកទេស ការណែនាំ និងការគាំទ្រក្នុងការរៀបចំលក្ខណៈវិនិច្ឆ័យបរិស្ថាន និងស្តង់ដារ សម្រាប់ប្រព័ន្ធលទ្ធកម្មប្រកបដោយនិរន្តរភាព ដែលត្រូវបង្កើត និងអនុវត្ត។ ក្រសួងអាចសហការជាមួយក្រសួងផ្សេងទៀត ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជ្រាបការអនុវត្ត GPP ទៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ និងទៅក្នុងក្រសួងតាមវិស័យរៀងៗខ្លួន។

**ក្រសួងមានសមត្ថកិច្ចផ្សេងទៀត៖**

ក្រៅពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន នៅមានក្រសួងច្រើនទៀតដែលអាចមានតួនាទីសំខាន់ទាក់ទងនឹង SPP ក្រោមហេតុផលដូចតទៅ៖

- **ក្រសួងសាធារណការនិងដឹកជញ្ជូន** ទទួលខុសត្រូវលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសាងសង់។ តាមរយៈការបញ្ចូលទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព ទៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ក្រសួងអាចរួមចំណែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមេត្រីបរិស្ថាន និងមានប្រសិទ្ធផលថាមពលផងដែរ។
- **ក្រសួងពាណិជ្ជកម្ម** អាចរួមចំណែកដល់ការអនុវត្ត SPP តាមរយៈតួនាទីរបស់ខ្លួនក្នុងការសម្របសម្រួលពាណិជ្ជកម្ម និងបទប្បញ្ញត្តិទាក់ទងនឹងទីផ្សារ។ ក្រសួងអាចលើកកម្ពស់ភាពអាចមាន និងលទ្ធភាពអាចរកបាននូវផលិតផល និងសេវាកម្មប្រកបដោយនិរន្តរភាពនៅលើទីផ្សារអន្តរជាតិ និងក្នុងស្រុក, អនុវត្តលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ស្លាកអេកូ និងវិញ្ញាបនបត្រសម្រាប់ផលិតផល និងសេវាកម្មប្រកបដោយនិរន្តរភាព និងគាំទ្រគំនិតផ្តួចផ្តើមផ្អែកលើទីផ្សារ និងបែបផែនធុរកិច្ចដែលលើកទឹកចិត្ត SCP និង SPP សម្រាប់ដំណើរការយូរអង្វែង។ បច្ចុប្បន្ន ក្រសួងសំខាន់ៗដែលពាក់ព័ន្ធនៅក្នុងក្រុមការងារ SCP កំពុងចូលរួមយ៉ាងសកម្មក្នុងការរៀបចំបង្កើតអនុក្រឹត្យស្តីពីការដាក់ស្លាកអេកូ។ សេចក្តីព្រាងអនុក្រឹត្យកំពុងឆ្លងកាត់ការពិភាក្សាផ្ទៃក្នុងរវាងសំខាន់ៗ មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, និងក្រសួងពាណិជ្ជកម្ម និងជាមួយតួអង្គពាក់ព័ន្ធក្នុងវិស័យឯកជន មានសភាពាណិជ្ជកម្មជាដើម។ ជាការសំខាន់ដែលត្រូវកត់សម្គាល់ដែរថា វាត្រូវការពេលវេលាបន្តិចនៅក្នុងដំណើរការរៀបចំអនុក្រឹត្យនេះឱ្យបានចប់សព្វគ្រប់ មុននឹងគេអាចដាក់ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីធ្វើការពិនិត្យ និងអនុម័ត។ កិច្ចពិភាក្សា ការពិគ្រោះយោបល់ និងការសម្របសម្រួលក្នុងចំណោមក្រសួងសំខាន់ៗ និងអ្នកពាក់ព័ន្ធ គឺជាការចាំបាច់ដើម្បីធានាឱ្យអនុក្រឹត្យនេះស្របទៅនឹងអាទិភាពថ្នាក់ជាតិ ក្របខ័ណ្ឌច្បាប់ និងឧត្តមានុវត្តអន្តរជាតិ។ ជាថ្មីម្តងទៀត ការរៀបចំអនុក្រឹត្យមួយស្តីពីស្លាកអេកូ ឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ ចំពោះការលើកកម្ពស់ការទម្លាប់អនុវត្តនៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព។
- **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** អាចដើរតួនាទីយ៉ាងសំខាន់មួយដែរ ក្នុងការជំរុញឱ្យមានការច្របាច់បញ្ចូលបច្ចេកវិទ្យានវានុវត្តន៍ និងបែបមេត្រីបរិស្ថានទៅក្នុងដំណើរការលទ្ធកម្ម។ តាមរយៈវិទ្យាស្ថានស្តង់ដារកម្ពុជា (ISC) ក្រសួងអាចជួយដល់អន្តរកម្មទៅរកសេដ្ឋកិច្ចបៃតង និងរួមចំណែកដល់ការអភិវឌ្ឍឧស្សាហកម្មប្រកបដោយនិរន្តរភាព។ វិទ្យាស្ថាន ISC អាចផ្តោតលើការបង្កើតគោលការណ៍ណែនាំ និងស្តង់ដាជាតិ សម្រាប់ដំណោះស្រាយប្រកបដោយនិរន្តរភាព និងប្រកបដោយប្រសិទ្ធផលថាមពល នៅក្នុងលទ្ធកម្មសាធារណៈ ជាពិសេសសម្រាប់ផលិតផលទំនិញ សម្ភារ សេវាកម្ម ទម្លាប់អនុវត្ត និងប្រតិបត្តិការដែលត្រូវបាននាំចូលពីក្រៅប្រទេស។
- **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ដើរតួនាទីយ៉ាងសំខាន់ ជាពិសេសនៅក្នុង បរិបទនៃផលិតផល និងសេវាកម្មកសិកម្មបៃតង។ ក្រសួងអាចជំរុញទម្លាប់អនុវត្តកសិកម្មប្រកបដោយនិរន្តរភាព គាំទ្រវិញ្ញាបនបត្របញ្ជាក់ផលិតផលកសិកម្មប្រកបដោយនិរន្តរភាព និងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកទេសគ្រប់គ្រងដីប្រកបដោយនិរន្តរភាព។`
- **ក្រសួងសុខាភិបាល** ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឱ្យមានទម្លាប់អនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ការអនុវត្ត ជាពិសេសក្នុងការទិញផលិតផលសុខាភិបាល និងមិនមែនសុខាភិបាល ដែលរួមបញ្ចូលទាំងការថែទាំសុខភាព សេវាកម្ម ឧបករណ៍វេជ្ជសាស្ត្រ សម្ភារបរិក្ខារ និងផលិតផលឱសថ។

នៅក្នុងពេលពិគ្រោះយោបល់ តួអង្គពាក់ព័ន្ធមួយចំនួនបានលើកមតិរិះគន់ជុំវិញការណ៍ដែលក្រសួងមានសមត្ថកិច្ចចេះតែពឹងផ្អែកលើស្ថាប័នបច្ចេកទេសឱ្យផ្តោតការយកចិត្តទុកដាក់លើគោលការណ៍ណែនាំ និងស្តង់ដា ជាជាងបង្កើតច្បាប់ដាក់កំហិតដាក់លាក់។ កង្វល់ក៏ត្រូវបានលើកឡើងដែរជុំវិញទំនោររបស់ក្រសួងនីមួយៗ ក្នុងធ្វើប្រតិបត្តិការដាច់ដោយឡែក ហើយមើលរំលងសារៈសំខាន់នៃកិច្ចប្រឹងប្រែងរួមគ្នាក្នុងការបង្កើតប្រព័ន្ធ និងស្តង់ដារួម ឱ្យស្របតាមចក្ខុវិស័យរបស់កម្ពុជាសម្រាប់ឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ឧទាហរណ៍ តាមការសង្កេតគេឃើញថានៅមិនទាន់មានការច្របាច់បញ្ចូលគ្នានៅឡើយទេ រវាងប្រព័ន្ធលទ្ធកម្មសម្រាប់គម្រោង

ដែលផ្តល់មូលនិធិពីខាងក្រៅ គម្រោងប្រើប្រាស់មូលនិធិរបស់រាជរដ្ឋាភិបាល និងគម្រោងវិនិយោគទាំងអស់ដែលគ្រប់គ្រងដោយច្បាប់ភាពជាដៃគូសាធារណៈ និងឯកជន។ បច្ចុប្បន្ន គម្រោងនានាមានដំណើរការតាមប្រព័ន្ធលទ្ធកម្មដាច់ដោយឡែកៗ ដែលអាចនាំឱ្យគ្មានប្រសិទ្ធផល និងបាត់ឱកាសសម្រាប់ការសហការ និងគ្មានភាពចុះសម្រុងគ្នា។ ដើម្បីសម្រេចគោលដៅខាងលើបានប្រសិទ្ធភាព បណ្តាក្រសួងគួរតែចាប់យកវិធីសាស្ត្ររួមដែលសង្កត់ធ្ងន់លើការសម្របសម្រួលឱ្យមានប្រសិទ្ធភាព គួបផ្សំជាមួយយន្តការនយោបាយ និងការងារ ជាជាងពឹងផ្អែកតែលើវិធីសាស្ត្រសម្របសម្រួលបែបប្រពៃណី។ វិធីសាស្ត្របែបនេះនឹងជួយធ្វើឱ្យកិច្ចខិតខំនានាដំណើរការទៅព្រមគ្នា និងស្របតាមវិស័យ ដោយបង្កើនភាពស្អិតរមួតគ្នា និងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់អនុវត្ត SPP នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាប្រយោជន៍ដល់ការសម្រេចឱ្យបានចក្ខុវិស័យវែងឆ្ងាយរបស់កម្ពុជា។

## ផ្នែកសំខាន់ទី៤៖ យន្តការ SPP និង SCP បច្ចុប្បន្ន

ដូចត្រូវបានលើកឡើងនៅខាងលើ តាមរយៈការគាំទ្រពី GIZ និងក្រុមការងារបច្ចេកទេស SCP ដឹកនាំដោយក្រសួងបរិស្ថាន រាជរដ្ឋាភិបាលបានបង្កើតអនុក្រឹត្យស្តីពី SCP ដែលពេលនេះកំពុងឆ្លងកាត់ការពិនិត្យផ្ទៃក្នុងដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។ ការងារ SCP មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយមានការចូលរួមយ៉ាងសកម្មពីអ្នកបច្ចេកទេសពីក្រសួង និងស្ថាប័នសំខាន់ៗ រួមមាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃក្រសួងបរិស្ថាន, វិទ្យាស្ថានស្តង់ដាជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ និងក្រសួងពាណិជ្ជកម្ម និងអង្គការ UNDP និងសភាពាណិជ្ជកម្មកម្ពុជា។

អនុក្រឹត្យស្តីពី SPP ពិតជាកិច្ចការមួយសំខាន់។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនឹងដើរតួនាទីនាំមុខគេនៅក្នុងដំណើរការនេះ ដោយត្រូវសហការជាមួយក្រសួងមានសមត្ថកិច្ចផ្សេងទៀត ដែលមានកាតព្វកិច្ចពាក់ព័ន្ធជាក់លាក់ជាមួយ SPP។ វាជាការចាំបាច់ណាស់ដែលត្រូវថែងជាបញ្ញត្តិជាក់លាក់អំពីភាពខ្វះមិនបានក្នុងការបង្កើនសមត្ថភាពស្ថាប័ន និងយន្តការឱ្យបានរឹងមាំ។ ជាអនុសាសន៍ ទិដ្ឋភាពទាំងនេះគួរតែត្រូវចាត់ទុកថាកាតាលីករសម្រាប់ការអភិវឌ្ឍសមត្ថភាព គោលនយោបាយ ការបង្កើត និងការណែនាំសម្រាប់អ្នកធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត។ ប្រសិនបើអាចធ្វើទៅបាន គួពង្រីកក្រុមការងារ SCP ឱ្យទៅគ្របដណ្តប់លើ SPP ទៀត ហើយពង្រីកវិសាលភាពរបស់វាដើម្បីឱ្យមានការចូលរួមពីអ្នកធ្វើសេចក្តីសម្រេចពីក្រសួងពាក់ព័ន្ធ។ ការពង្រីកនេះអាចបង្កើតបានតាមរយៈការសម្រេចរួម (ហៅថា "ប្រកាស") ជាពិសេសរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។

## ផ្នែកសំខាន់ទី៥៖ ការយល់ដឹង និងការកសាងសមត្ថភាព

ជារួម គោលនយោបាយរបស់កម្ពុជាឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។ ទោះយ៉ាងណាក៏ដោយ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការពិនិត្យឡើងវិញនូវឯកសារគោលនយោបាយសំខាន់ៗ បានផ្តល់ភ័ស្តុតាងច្បាស់ថា ការយល់ដឹងជាសាធារណៈ និងការកសាងសមត្ថភាព គឺជាទិដ្ឋភាពស្នូលសំខាន់ពីរនៅក្នុង SCP និង SPP។ អ្នកធ្វើសេចក្តីសម្រេច និងអ្នកអនុវត្តនៅក្នុងវិស័យសាធារណៈ ដែលដើរតួនាទីសំខាន់ក្នុងការអនុវត្តប្រព័ន្ធទាំងនេះ នៅមានចំណេះដឹង និងបទពិសោធន៍តិចតួចណាស់អំពី SCP និង SPP។ ដូច្នេះ គេចាំបាច់ត្រូវធ្វើអាទិភាពនូវកិច្ចប្រឹងប្រែងដើម្បីពង្រឹងការកសាងសមត្ថភាពសម្រាប់អ្នកធ្វើសេចក្តីសម្រេច នៅក្នុងប្រព័ន្ធអេកូឡូស៊ីលទ្ធកម្មរបស់កម្ពុជា។

មានការលើកឡើងនូវសំណួរសំខាន់មួយថា៖ **"តើអ្វីទៅជាការលើកទឹកចិត្តដល់រាជរដ្ឋាភិបាល នៅក្នុងការជំរុញការអភិវឌ្ឍ និងការអនុវត្ត SCP និង SPP?"** តាមរយៈការសង្កត់ធ្ងន់លើ SCP និង SPP រាជរដ្ឋាភិបាលអាចជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បង្កើនប្រសិទ្ធផលធនធាន កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងជំរុញកំណើនដោយបរិយាបន្ន ហើយតាមរយៈនេះ រួមចំណែកដល់ការសម្រេចឱ្យបាននូវកំណើនដែលមាន **"ភាពធន់ និរន្តរភាព និងការអភិវឌ្ឍដោយបរិយាបន្ន"** ស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ការទម្លាប់អនុវត្ត SCP និង SPP អាចធ្វើឱ្យសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសកាន់តែមានភាពប្រសើរ ទាក់ទាញបានការវិនិយោគក្នុងឧស្សាហកម្មប្រកបដោយនិរន្តរភាព និងលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់កម្ពុជាថាជាប្រជាជាតិមួយដែលមានស្មារតីទទួលខុសត្រូវ និងយកចិត្តទុកដាក់ចំពោះបរិស្ថាន។ លើសពីនេះ ការចាប់យក SCP និង SPP អាចនាំឱ្យមានតម្លាភាព ការសន្សំការចំណាយ ការកែលម្អផលសុខភាពសាធារណៈ និងសុខុមាលភាពសង្គមបានកាន់តែប្រសើរឡើង។ ទាំងនេះជាប្រការលើកទឹកចិត្ត ដែលកាលណាគួបផ្សំជាមួយនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការសម្រេច CSDGs និងការលើកកម្ពស់និរន្តរភាពវែងឆ្ងាយ នឹងបង្កើតបានជាចលករខ្លាំងក្លាមួយសម្រាប់រុញទៅមុខនូវការបង្កើត និងការអនុវត្ត SCP និង SPP នៅកម្ពុជា។

អ្នកជំនាញបានធ្វើការពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរកដំណោះស្រាយទៅនឹងតម្រូវការ និងបញ្ហាប្រឈមនានាពាក់ព័ន្ធជាមួយនឹងការកែលម្អលទ្ធកម្មនៅថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន លេខាធិការដ្ឋាន សហការជាមួយអង្គការតម្លាភាពអន្តរជាតិកម្ពុជា និងផ្នែកបច្ចេកទេសផ្សេងទៀតនៅក្នុងលេខាធិការដ្ឋាន កំពុងធ្វើការពិនិត្យសៀវភៅស្តីពីគោលការណ៍ណែនាំការអនុវត្តគម្រោងដែលមានស្រាប់ (PIM)។ ក្នុងអំឡុងពេលពិភាក្សាអំពីការប្រេបាច់បញ្ចូលលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវស្តីពីនិរន្តរភាពទៅក្នុងប្រព័ន្ធលទ្ធកម្ម សម្រាប់ទំនិញ និងការងារស៊ីវិលនៅរដ្ឋបាលថ្នាក់មូលដ្ឋានទូទាំងប្រទេស លេខាធិការដ្ឋានបានទទួលស្គាល់សារៈសំខាន់នៃការប្រកាន់ខ្ជាប់គោលនយោបាយការពារជាមុន រួមទាំងការការពារបរិស្ថាន និងការកាន់កាប់ដីធ្លី ផងដែរ។ តាមរយៈនេះ លេខាធិការដ្ឋានយល់ឃើញថានៅមានការខ្វះខាតផ្នែកចំណេះដឹងអំពីលទ្ធកម្មប្រកបដោយនិរន្តរភាព ហើយទទួលស្គាល់សារៈសំខាន់ និងភាពបន្ទាន់ត្រូវធ្វើការកែសម្រួលឡើងវិញនូវផ្នែកលទ្ធកម្មថ្នាក់ក្រោមជាតិ នៅក្នុងសៀវភៅ PIM ដើម្បីបញ្ចូលគោលការណ៍ និងស្តង់ដានិរន្តរភាព។

## ៤.២ សហគមន៍សកល និងវិស័យឯកជន

វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងសហគមន៍មូលដ្ឋាន មានតួនាទីសំខាន់ក្នុងការគាំទ្រ និងធ្វើការឆ្លើយតបទៅនឹងការខ្វះខាតនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល។ ប៉ុន្តែ នៅពេលបង្កើតក្រុមការងារ SCP នៅឆ្នាំ២០២១ តួអង្គទាំងនេះ រួមទាំងសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ផង មិនត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃក្រុមការងារនេះទេ។ ម្យ៉ាងទៀត គ្មានការចែងកំណត់ឱ្យច្បាស់ទេថាតើគួរប្រឡូកពាក់ព័ន្ធជាមួយ និងផ្តល់ការគាំទ្របែបណាដល់តួអង្គទាំងនេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះចន្លោះកន្លងមក នៅក្នុងកិច្ចសម្របសម្រួលកិច្ចសន្ទនាគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព និងការចែករំលែកចំណេះដឹង ជាដើម។

ក្រុមការងារ SCP បានទទួលភារកិច្ចឱ្យកៀរគរការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីម្ចាស់ជំនួយ ដើម្បីអនុវត្តគំនិតផ្តួចផ្តើមសាកល្បង SPP។ ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព ការផ្តល់អាទិភាពដល់ភាពជាដៃគូជាមួយតួអង្គទាំងអស់គឺជារឿងមួយខ្វះមិនបាន។ ការធ្វើអាទិភាពបែបនេះនឹងជំរុញទឹកចិត្តឱ្យពួកគេចូលរួម នៅក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់សកម្មភាពនានាទៅថ្ងៃមុខ។ សកម្មភាពទាំងនេះមានដូចជា ការសន្ទនាគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព និងការអប់រំ ការអនុវត្តគំនិតផ្តួចផ្តើមសាកល្បង ការចងក្រងឯកសារមេរៀនដកពិសោធន៍ និងជោគជ័យ និងការប្រមូលព័ត៌មានបានកាន់តែល្អសម្រាប់រៀបចំគោលនយោបាយ និងផែនទីចង្អុលផ្លូវផ្នែកច្បាប់ស្តីពី SCP និង SPP នៅកម្ពុជា។ ក្រៅពីនេះ គេចាំបាច់ត្រូវសង្កត់ធ្ងន់ដែរ លើការចែករំលែកចំណេះដឹងជាមួយប្រទេស និងបណ្តាញនៅក្នុង និងក្រៅតំបន់។

សរុបមក ការចូលរួម និងសហការយ៉ាងសកម្មជាមួយតួអង្គនានា អាចនាំកម្ពុជាទៅបង្កើតបានអភិក្រមមួយកាន់តែមានបរិយាបន្ន និងគ្រប់ជ្រុងជ្រោយ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយប្រើប្រាស់អស់លទ្ធភាពនូវឯកទេស ធនធាន និងបទពិសោធន៍របស់ភាគីពាក់ព័ន្ធ។ នៅទីបំផុត វានឹងរួមចំណែកបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃសកម្មភាពនានារបស់ SCP និង SPP នៅក្នុងប្រទេស និងជួយសម្រួលដល់ការរៀនសូត្រ និងកិច្ចសហប្រតិបត្តិការឆ្លងព្រំដែន ទៀតផង។

កង្វះច្បាប់ និងបទប្បញ្ញត្តិជាក់លាក់ដើម្បីអនុវត្តច្បាប់ជាធរមាន គឺជាបញ្ហាគួរឱ្យកត់សម្គាល់មួយ។ ឧទាហរណ៍ ក្រសួងរ៉ែ និងថាមពល មានគោលនយោបាយប្រសិទ្ធផលថាមពល អមដោយសកម្មភាពទូលំទូលាយ ប៉ុន្តែការអនុវត្តរបស់វានៅតែមានបញ្ហាប្រឈម។ វាមិនមែនជាបញ្ហាដាច់ដោយឡែកសម្រាប់ផ្នែកប្រសិទ្ធផលថាមពលទេ ប៉ុន្តែផ្នែកដទៃទៀតដែលគ្រប់គ្រងដោយច្បាប់ក៏ជួបបញ្ហាស្រដៀងគ្នានេះដែរ។ ចំណុចមួយទៀតគឺកង្វះការតាមដាន និងការត្រួតពិនិត្យជាប្រព័ន្ធនៅក្នុងវិស័យសាធារណៈ ជាពិសេសក្នុងការតម្រូវឱ្យអនុវត្តការប្រើប្រាស់សម្ភារៈប្រកបដោយនិរន្តរភាព និងការសាងសង់បៃតង។

ការខ្វះចន្លោះក្នុងការប្រាស្រ័យទាក់ទងនៅក្នុងវិស័យសាធារណៈ ដែលជាហេតុនាំឱ្យមានការណែនាំ និងការត្រួតពិនិត្យមិនបានជិតដល់ផ្នែកគោលនយោបាយ គឺមិនមែនកើតឡើងចំពោះតែសកម្មភាពសាងសង់បៃតងទេ ប៉ុន្តែវាក៏មាននៅតាមវិស័យផ្សេងទៀតផងដែរ ភាគច្រើនដោយសារតែមានការយល់ឃើញថា ប្រធានបទមួយចំនួនមិនត្រូវបានកំណត់អាទិភាពពីមុនមក។ ស្ថានភាពនេះ កាន់តែសបញ្ជាក់អំពីតម្រូវការកាន់តែខ្លាំងឱ្យមានការធ្វើសុខដុមនីយកម្មនូវបទប្បញ្ញត្តិពាក់ព័ន្ធនិរន្តរភាពនៅក្នុងច្បាប់ផ្សេងៗជាមួយអនុក្រឹត្យស្តីពីលទ្ធកម្ម ដើម្បីគេអាចយកវាធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាបាននៅពេលធ្វើការសម្រេចចិត្តជាវផលិតផល ការងារ ឬសេវាកម្ម ណាមួយ។

នៅក្នុងពេលពិគ្រោះយោបល់ជាមួយសមាគមធុរកិច្ចឯកជន អ្វីដែលបានស្តែងឱ្យឃើញច្បាស់នោះគឺ ពួកគេអំពាវនាវឱ្យមានការជួយដល់ក្រសួងសំខាន់ៗក្នុងការរៀបចំវិធាន និងបទប្បញ្ញត្តិជាក់លាក់ និងផ្តល់ភាពអនុគ្រោះពិសេសសម្រាប់ការវិនិយោគដោយនិរន្តរភាព។ ពួកគេបានលើកឡើងថា ជាការចាំបាច់ណាស់ក្នុងការកំណត់ឱ្យបានច្បាស់នូវការទទួលខុសត្រូវរបស់ក្រសួង

នីមួយៗ និងបញ្ជាក់ឱ្យជាក់លាក់ថាតើសម្រាប់បញ្ហាជាក់លាក់មួយ ពួកគេត្រូវទៅរកក្រសួងមួយណា ឧទាហរណ៍ការរកអាជ្ញាបណ្ណដែលមានការណែនាំសម្រាប់ការកែច្នៃវាយនភ័ណ្ឌ ជាដើម។ ពិតណាស់ ការអនុវត្ត SPP អាចបង្កបញ្ហាប្រឈមចំពោះការចូលរួមរបស់វិស័យឯកជន ដូច្នេះហើយពួកគេទទូចអំពីតម្រូវការបន្ទាន់ឱ្យរាជរដ្ឋាភិបាលបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ដើម្បីជៀសវាងការភ័ន្តច្រឡំ ហើយជួយក្រុមហ៊ុននៅក្នុងការធ្វើអាជីវកម្មរបស់ខ្លួន។

វាអាចជារឿងល្អមួយដែរប្រសិនបើវិស័យសាធារណៈធ្វើការពាក់ព័ន្ធជាមួយវិស័យឯកជន នៅក្នុងក្រុមការងាររវាងផ្នែកសាធារណៈ និងឯកជនដោយឡែកមួយទៀត ជាជាងពឹងផ្អែកតែទៅលើភ្នាក់ងាររាជរដ្ឋាភិបាលនៅក្នុងក្រុមការងារបច្ចេកទេស។ ការបង្កើតក្រុមការងារបែបនេះទៅតាមប្រធានបទផ្សេងៗ នឹងជួយសម្រួលដល់កិច្ចសន្ទនាដែលកំពុងដំណើរការ បង្កលក្ខណៈងាយស្រួលដល់ការកំណត់អត្តសញ្ញាណបញ្ហាប្រឈមដែលក្រុមហ៊ុន និងអង្គការសង្គមស៊ីវិលជួបប្រទះ និងជំរុញការស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍ដល់បញ្ហាទាំងនោះ។ ឧទាហរណ៍ គេអាចពិចារណាជ្រើសរើសប្រធានបទជាក់លាក់ពីរនៅខាងក្រោមសម្រាប់ធ្វើការសាកល្បងកម្មវិធីលទ្ធកម្ម SPP នៅកម្ពុជា៖

- ការកែច្នៃឡើងវិញនៅក្នុងឧស្សាហកម្មវាយនភណ្ឌ៖ ក្នុងន័យនេះ គេអាចបង្កើតអង្គភាពមួយក្នុងចំណោមឧស្សាហកម្មសំខាន់ៗ សម្រាប់ធ្វើជាគម្រោងសាកល្បងអនុវត្ត SPP ដើម្បីរួមចំណែកដល់និរន្តរភាពបរិស្ថាន។

- ការជ្រើសរើសនិម្មិតកម្មសំណង់ប្រកបដោយនិរន្តរភាព៖ ជ្រើសយករោងមហោស្រពអេកូឡូស៊ីមួយធ្វើជាគម្រោងផ្សព្វផ្សាយការប្រកួតប្រជែងក្នុងចំណោមស្ថាបត្យករ ហើយអញ្ជើញក្រុមហ៊ុនធំៗឱ្យចូលរួមសហការ ដើម្បីធ្វើគម្រោងឱ្យចេញជាផ្លែផ្កា។

# ជំពូក ៥. សេចក្ដីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាយ៉ាងមុតមាំ ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs) ត្រឹមឆ្នាំ២០៣០។ ដើម្បីគាំទ្រការប្តេជ្ញាចិត្តនេះ រាជរដ្ឋាភិបាលបានបញ្ចូលគោលដៅទាំងនេះទៅក្នុងគោលនយោបាយជាតិ និងក្របខ័ណ្ឌច្បាប់ផ្សេងៗ រួមទាំងច្បាប់ដែលបានអនុម័តថ្មីៗ ដូចជា ក្រមបរិស្ថាន និងធនធានធម្មជាតិ (២០២៣), ច្បាប់លទ្ធកម្មសាធារណៈ(២០២៣) និងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន (២០២១)។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព និងក្រុមការងារបច្ចេកទេសអន្តររដ្ឋាភិបាលផ្សេងទៀត ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួល និងជ្រោមជ្រែងកិច្ចសន្ទនាគោលនយោបាយ និងការអភិវឌ្ឍលើវិស័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ កំណើនបៃតង ការគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ និងការការពារបរិស្ថានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី។ កិច្ចខិតខំទាំងនេះមានគោលបំណងដើម្បីសម្រេចបាននូវនិរន្តរភាពរយៈពេលវែង និងការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និងប្រកបដោយបរិយាបន្ន។

កិច្ចការស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) មានការរីកចម្រើនគួរឱ្យកត់សម្គាល់ នៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួងសំខាន់ៗ។ លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ត្រូវបានភ្ជាប់យ៉ាងជិតស្និទ្ធជាមួយ SCP ដូចមានចែងនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ និងដូចត្រូវបានគូសបញ្ជាក់នៅក្នុងច្បាប់លទ្ធកម្មសាធារណៈ (មាត្រា ៥៦)។ ទោះបីជាមានមហិច្ឆតាដូចគ្នាក៏ដោយ ក្រមបរិស្ថាន និងធនធានធម្មជាតិ និងច្បាប់លទ្ធកម្មសាធារណៈ ស្ថិតនៅក្រោមអាណត្តិស្ថលរបស់ក្រសួងពីរផ្សេងគ្នា (ក្រសួងបរិស្ថាន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ ដូច្នេះ កិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងក្រសួងទាំងពីរនេះ ជាពិសេសនាយកដ្ឋានមានសមត្ថកិច្ច ឬអគ្គនាយកដ្ឋាន គឺជាការចាំបាច់បំផុតដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាប្រឈមនានាទាក់ទងនឹងការអនុវត្ត SPP នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាអនុសាសន៍ គួរបង្កើតយន្តការរួមដែលពាក់ព័ន្ធជាមួយអ្នកធ្វើសេចក្តីសម្រេចនៅតាមកម្រិតផ្សេងៗគ្នា មន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជាវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ជាដើម។ យន្តការទាំងនេះនឹងជំរុញ និងផ្តួចផ្តើមសកម្មភាពចាំបាច់ ដើម្បីបំពេញតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល សម្រាប់ឆ្នាំ២០៣០។

# ជំពូក ៦. អនុសាសន៍សម្រាប់ធ្វើសកម្មភាព

## ៦.១ មេរៀនដកពិសោធន៍សំខាន់ៗ៖

ឆ្លងតាមការដកពិសោធន៍មេរៀនទាំងនេះនៅកម្ពុជា ខាងក្រោមនេះជាលទ្ធផលដែលបានមកពីការពិភាក្សាជាមួយ ដៃគូសំខាន់ៗ និងផ្អែកលើការពិនិត្យឯកសារពាក់ព័ន្ធ កន្លងមក។

- **ការសម្របខ្លួននៃអភិក្រមរបស់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍៖** ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ តែងធ្វើសកម្មលើគំនិតផ្តួចផ្តើម និងជួបបញ្ហាប្រឈមស្រដៀងគ្នា ដូចជា SCP, SPP, MAPS និងរបៀបវារៈគោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត។ នៅក្នុងទិដ្ឋភាពបែបនេះ គេចាំបាច់គួរសម្របការគាំទ្ររបស់ពួកគេ និងបង្កើតសហកម្មនៅក្នុងចំណោមដៃគូ ដើម្បីគាំទ្ររាជរដ្ឋាភិបាលឱ្យបានកាន់តែល្អ ឈានទៅជានាបាននូវការអនុវត្តស៊ីចង្វាក់គ្នាដោយរលូន។
- **ការពង្រីកកិច្ចខិតខំកសាងសមត្ថភាព៖** ការពង្រីកកិច្ចខិតខំកសាងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលទូទៅ និងអ្នកអនុវត្តលទ្ធកម្ម គឺជាកិច្ចការមួយសំខាន់ណាស់។ កិច្ចការនេះអាចធ្វើទៅបានតាមរយៈការរៀបចំសន្និសីទ និងការផ្លាស់ប្តូរទស្សនកិច្ច ដែលផ្តោតជាពិសេសទៅលើមន្ត្រីគោលនយោបាយនៃក្រសួងនាំមុខគេ មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។ ឱកាសទាំងនេះអាចបង្កលក្ខណៈឱ្យមន្ត្រីគោលនយោបាយទទួលបានការយល់ដឹងមានតម្លៃ ចែករំលែកឧត្តមានុវត្តន៍ និងអភិវឌ្ឍជំនាញចាំបាច់នៅក្នុង SCP និង SPP ។
- **ការពង្រឹងការចងក្រងឯកសារ និងការចែករំលែកចំណេះដឹង៖** ដោយសារតែគម្រោងសាកល្បងនៅតាមវិស័យជាក់លាក់មានតិចតួច ឯកសារនិងការចែករំលែកមេរៀនដកពិសោធន៍ និងជោគជ័យ ក៏មិនសូវមានដែរ។ ដូច្នេះ ជាការសំខាន់ដែលគេត្រូវខិតខំចងក្រងឯកសារអំពីឧត្តមានុវត្តន៍ និងជួយសម្រួលដល់ការចែករំលែកចំណេះដឹង ដើម្បីជំរុញឱ្យបានកាន់តែទូលំទូលាយនូវការទទួលយកអភិក្រមនៃកិច្ចលទ្ធកម្ម និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព។
- **ការចាប់យកនវានុវត្តន៍បច្ចេកវិទ្យា៖** ប្រព័ន្ធគ្រប់គ្រងរបស់ប្រទេសនៅខ្វះនវានុវត្តន៍បច្ចេកវិទ្យា រួមទាំងប្រព័ន្ធលទ្ធកម្មសាធារណៈ ផងដែរ។ រាជរដ្ឋាភិបាល និងដៃគូគួរផ្តល់អាទិភាពដល់ការច្បាមយកឱកាសពីបច្ចេកវិទ្យានវានុវត្តន៍ ដូចជាប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក ដើម្បីបង្កើនតម្លាភាព ប្រសិទ្ធផល និងនិរន្តរភាពក្នុងដំណើរការលទ្ធកម្មសាធារណៈ។ ការវិនិយោគលើបច្ចេកវិទ្យាជឿនលឿន និងដំណោះស្រាយឌីជីថល អាចជំរុញអន្តរកម្មនេះឱ្យកាន់តែលឿនទៅមុខ។
- ***ភាពចាស់ទុំនៃទីផ្សារសម្រាប់ផលិតផល ការងារ និងសេវាកម្មប្រកបដោយនិរន្តរភាព***

## ៦.២ អនុសាសន៍

ឆ្លងតាមការដកពិសោធន៍មេរៀនដូចបានរៀបរាប់ខាងលើ ករណីសិក្សានេះសូមជូនអនុសាសន៍ខាងក្រោមសម្រាប់យកទៅពិចារណាធ្វើសកម្មភាព ក្នុងការកសាងភាពជាដៃគូ ការបង្កើតគោលនយោបាយ និងការអនុវត្ត ដូចតទៅ៖

១. គាំទ្រដល់ការបង្កើតច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំ សម្រាប់លទ្ធកម្មប្រកបដោយនិរន្តរភាព រួមទាំងអនុក្រឹត្យជាតម្រូវការមុនគេសម្រាប់ SPP និងនីតិវិធីលម្អិតដែលភ្ជាប់ SPP ជាមួយនឹងការសិក្សាដែលកំពុងបន្ត, និងរៀបចំរចនាប្រព័ន្ធលទ្ធកម្មសាធារណៈអេឡិចត្រូនិករបស់រាជរដ្ឋាភិបាល (e-GP) ជាផ្នែកមួយនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ និងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

២. រៀបចំដំណើរទស្សនៈកិច្ចសិក្សាទៅកាន់ប្រទេសដែលមានស្ថានភាពស្រដៀងគ្នាជាមួយបរិការណ៍របស់កម្ពុជា ដើម្បីទទួលបាននូវការយល់ដឹង និងបទពិសោធន៍អំពីលទ្ធកម្មប្រកបដោយនិរន្តរភាព។ ពង្រឹងកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់មន្ត្រីរដ្ឋាភិបាល និងអ្នកអនុវត្តលទ្ធកម្ម ដើម្បីបង្កើនចំណេះដឹង និងជំនាញរបស់ពួកគេនៅក្នុងការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព។

៣. ការបង្កើតឱ្យមានថ្នាលបណ្តុះបណ្តាលអនឡាញជាកំហិតមួយ ដែលរចនាឡើងសម្រាប់អ្នកធ្វើសេចក្តីសម្រេច មន្ត្រីកម្រិតគោលនយោបាយ និងអ្នកអនុវត្តលទ្ធកម្ម គឺជាកិច្ចការសំខាន់ណាស់។ ថ្នាលបណ្តុះបណ្តាលបែបនេះគួរតែតម្រឹមតាមគោលការណ៍នៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព ក៏ដូចជាតាមច្បាប់ និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែរ។ តាមរយៈការអនុវត្តគំនិតផ្តួចផ្តើមទាំងនេះ គេអាចពង្រីកការកសាងសមត្ថភាពបានដោយប្រសិទ្ធភាព និងជំរុញការទទួលយកបានយ៉ាងទូលំទូលាយនូវទម្លាប់អនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព នៅគ្រប់កម្រិតនៃអភិបាលកិច្ច។

៤. ធ្វើសេចក្តីសង្ខេបគោលនយោបាយ ឬកំណត់ត្រាគោលគំនិតមួយ ដែលប្រើប្រាស់សេចក្តីព្រាងផែនទីចង្អុលផ្លូវ SPP ដែលបានអាប់ដេត, ការយល់ដឹងពីបទពិសោធន៍របស់ប្រទេសផ្សេងៗ និងការបង្កើតអនុក្រឹត្យស្តីពី SCP ដោយរំលេចពីសារៈសំខាន់ និងតម្រូវការសម្រាប់ការអនុវត្ត SPP នៅកម្ពុជា។

៥. ធ្វើសមាហរណកម្មប្រព័ន្ធលទ្ធកម្មរបស់គម្រោងដែលទទួលនិធិមកពីក្រៅប្រទេស និងគម្រោងដែលទទួលនិធិពីរាជរដ្ឋាភិបាល ឱ្យក្លាយទៅជាប្រព័ន្ធមួយឯកភាព និងចុះសម្រុងគ្នា។ ការរួមបញ្ចូលគ្នានេះគួរត្រូវបានធ្វើតាមរបៀបមួយដែលបញ្ចូលលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវស្តីពីនិរន្តរភាព ហើយឱ្យស្របតាមការអនុវត្តពេញលេញរបស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) នៅថ្ងៃខាងមុខ។

៦. ការពិនិត្យឡើងវិញនៃសៀវភៅស្តីពីគោលការណ៍ណែនាំការអនុវត្តគម្រោង (PIM) បច្ចុប្បន្ន កំពុងត្រូវបានអនុវត្តដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។ ជាអនុសាសន៍ ការពិនិត្យឡើងវិញនេះ គួរតែរួមបញ្ចូលកិច្ចលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព គោលការណ៍ និងស្តង់ដាសម្រាប់ប្រព័ន្ធលទ្ធកម្មថ្នាក់ក្រោមជាតិ បន្ថែមពីលើលក្ខខណ្ឌតម្រូវការពារដែលមានស្រាប់។ ដើម្បីសម្រេចបានកិច្ចការនេះ លេខាធិការដ្ឋាន គ.ជ.អ.ប គួរធ្វើការពិគ្រោះយោបល់ជាមួយនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូនានាដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីពាក់ព័ន្ធផ្សេងទៀត ដែរ។ អភិក្រមសហការគ្នានេះនឹងជួយធានាថា PIM ដែលបានកែសម្រួល មានបញ្ចូលគោលការណ៍ណែនាំទូលំទូលាយសម្រាប់ប្រព័ន្ធលទ្ធកម្មថ្នាក់ក្រោមជាតិ ស្របតាមទម្លាប់អនុវត្តដែលយល់ដឹងអំពីនិរន្តរភាព និងបរិស្ថាន។

៧. បន្តភាពជាដៃគូជាមួយអង្គការអន្តរជាតិ និងតួអង្គពាក់ព័ន្ធ ដើម្បីសម្រួលដល់ការចែករំលែកចំណេះដឹង នៅកម្រិតជាតិ ថ្នាក់តំបន់ និងពិភពលោក។ ជំរុញការផ្លាស់ប្តូរឧត្តមានុវត្តន៍ បទពិសោធន៍ និងមេរៀនដកពិសោធន៍ ដើម្បីពន្លឿនវឌ្ឍនភាពនៅក្នុង SPP និង SCP។ ជាផ្នែកមួយនៃផែនការកសាងសមត្ថភាព និងការកសាងស្ថាប័នសម្រាប់កម្រិតគោលនយោបាយ និងកម្រិតមុខងាររបស់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ វាជាការសំខាន់ដែលគេត្រូវកំណត់អត្តសញ្ញាណ និងយល់ព្រមគ្នាលើសេណារីយោភាពជាដៃគូសម្រាប់ SCP និង SPP ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

៨. សង្កត់ធ្ងន់លើការចាប់យកបច្ចេកវិទ្យានវានុវត្តន៍ ដូចជា លទ្ធកម្មអេឡិចត្រូនិក ដើម្បីបង្កើនតម្លាភាព ប្រសិទ្ធផល និងនិរន្តរភាពនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ។ នៅត្រង់នេះ គួរតែមានការពិចារណាបញ្ចូលអនុក្រឹត្យមួយស្តីពី SPP/SCP នាពេលខាងមុខ ផងដែរ។

៩. អនុវត្តយន្តការតាមដាន និងវាយតម្លៃ ដើម្បីវាយតម្លៃប្រសិទ្ធភាព និងឥទ្ធិពលរបស់គំនិតផ្តួចផ្តើម SPP និង SCP នៅតាមវិស័យសំខាន់ៗនៅក្នុងដំណាក់កាលសាកល្បងដំបូង មុននឹងឈានទៅពង្រីកការអនុវត្តវាឱ្យបានពេញលេញ នៅតាមវិស័យកាន់តែទូលំទូលាយ។ ការពិនិត្យមើលឡើងវិញជាទៀងទាត់នឹងជួយកំណត់បាននូវផ្នែកណាដែលត្រូវកែលម្អ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលបំណងអភិវឌ្ឍន៍ប្រកបដោយចីរភាព។

១០. ដើម្បីជំរុញកិច្ចសហការឱ្យមានប្រសិទ្ធភាពរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ក៏ដូចជាក្រសួងមានសមត្ថកិច្ចផ្សេងទៀត វាជារឿងសំខាន់ដែលក្រុមម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ត្រូវរកឱ្យឃើញថាតើអ្វីជាចំណុចផ្តើមដែលពួកគេអាចប្រើធ្វើជាច្រកសម្រាប់ចូលធ្វើការពាក់ព័ន្ធ និងជំរុញសកម្មភាពនានាជុំវិញនិរន្តរភាព ជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ចំណុចផ្តើមមួយដែលគេអាចប្រើធ្វើជាច្រកចូលមានប្រសិទ្ធភាពខ្ពស់ គឺតាមរយៈក្រុមការងារអន្តរក្រសួងស្តីពី SCP ដែលមានស្រាប់ ដែលប្រហែលជាចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពដែរ ដើម្បីឱ្យស្របតាមការផ្លាស់ប្តូរនៅក្នុងរាជរដ្ឋាភិបាលថ្មី។ លើសពីនេះទៀត ការចូលពាក់ព័ន្ធជាមួយអ្នកបង្កើតគោលនយោបាយ និងអ្នកតាក់តែងច្បាប់ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ដែលជាក្រសួងនាំមុខនៅក្នុងកិច្ចការនេះ គឺមានសារៈសំខាន់ខ្លាំងណាស់។ អភិក្រមនេះប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងក្រសួង ហើយតាមរយៈនេះវាបង្កើតបានជាវេទិកាស្វាហាប់មួយ សម្រាប់ការសម្របសម្រួល និងការអនុវត្តនូវទម្លាប់អនុវត្តប្រកបដោយនិរន្តរភាព។

# ឧបសម្ព័ន្ធ ក. ម៉ាទ្រីសសម្រាប់វិភាគកត្តានយោបាយ សេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា (PEST)

| PEST | កត្តាសំខាន់ៗ | ការពិចារណា |
|---|---|---|
| កត្តានយោបាយ | ការបង្កើតឡើងនូវគោលនយោបាយសំខាន់ៗ ដូចជា ក្រមបរិស្ថាន និងធនធានធម្មជាតិ (២០២៣), ច្បាប់លទ្ធកម្មសាធារណៈ (២០២៣) និង ច្បាប់ភាពជាដៃគូរវាងរដ្ឋ និងឯកជន (២០២១) បង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងសេដ្ឋកិច្ចចក្រា ការប្រែប្រួលអាកាសធាតុ និង ការអភិវឌ្ឍប្រកបដោយចីរភាព ។ ការបង្កើតភ្នាក់ងារអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងក្របខ័ណ្ឌ CSDG បានរំលេចឱ្យឃើញអំពីការសង្កត់ធ្ងន់ផ្នែកនយោបាយ លើការលើកកម្ពស់និរន្តរភាពនៅកម្ពុជា។ | រាជរដ្ឋាភិបាលគួរគាំទ្រឱ្យមានបរិស្ថានអំណោយផលសម្រាប់ PPP ដើម្បីលើកកម្ពស់ SCP និង SPP ។ ផ្អែកលើក្រមបរិស្ថាន និងធនធានធម្មជាតិ (២០២៣), ច្បាប់លទ្ធកម្មសាធារណៈ (២០២៣) និង ច្បាប់ភាពជាដៃគូរវាងរដ្ឋ និងឯកជន (២០២១) ជាមូលដ្ឋានគ្រឹះ គួរតែមានការរៀបចំបង្កើតវិធាន និងបទប្បញ្ញត្តិជាក់លាក់ សម្រាប់ការអនុវត្ត SCP និង SPP ឱ្យមានប្រសិទ្ធភាព ។ |
| | ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះគោលនយោបាយប្រកបដោយនិរន្តរភាព និងកម្មវិធីកំណែទម្រង់មានឥទ្ធិពលយ៉ាងសំខាន់ ទៅលើចក្ខុវិស័យរយៈពេលវែងសម្រាប់ឆ្នាំ ២០៣០ (ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់) និង២០៥០ (ក្លាយជាប្រទេសមានចំណូលខ្ពស់)។ | ជាការសំខាន់ដែលត្រូវស្វែងយល់អំពីតម្រូវការ និងបញ្ហាប្រឈមដែលអាចនឹងកើតឡើងនៅលើមាគ៌ានិរន្តរភាពនៅកម្ពុជា។ |
| | ឆន្ទៈនយោបាយនិងការគាំទ្រគឺជាចំណុចសំខាន់ក្នុងកំណត់ភាពជោគជ័យ និងប្រសិទ្ធភាពរបស់គំនិតផ្តួចផ្តើម SPP។ | អភិក្រមបែបប្រព័ន្ធដែលតភ្ជាប់កម្រិតនយោបាយជាមួយកម្រិតបច្ចេកទេសអាចពង្រឹងកិច្ចសន្ទនាគោលនយោបាយ ដំណើរការធ្វើសេចក្តីសម្រេច និងធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ក្នុងការអនុវត្ត។ |
| | សមត្ថភាពស្ថាប័ន និងអភិបាលកិច្ចខ្សោយ បង្កបញ្ហាប្រឈមសំខាន់ៗដល់គោលនយោបាយ SCP និង SPP។ | ទាញយកផលចំណេញពីការដកពិសោធន៍មេរៀនតាមរយៈកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ សមាគមធុរកិច្ច និងក្រសួងសំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីពង្រីកគំនិតផ្តួចផ្តើម។ |
| កត្តាសេដ្ឋកិច្ច | ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់កម្ពុជាក្រោយពីរងការប៉ះទង្គិចដោយសារជំងឺកូវីដ-១៩ បង្ហាញពីឱកាសសម្រាប់ការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព។ | ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់កម្ពុជា ជាឱកាសសម្រាប់ធ្វើការកំណត់អាទិភាព និងការវិនិយោគទៅលើគំនិតផ្តួចផ្តើមដោយនិរន្តរភាព ដោយដាក់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅជួរមុខនៃកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ។ |
| | ការរាតត្បាតជំងឺកូវីដ-១៩ បានបង្កើនកម្រិតភាពក្រីក្រ[9] និងភាពខុសគ្នានៃប្រាក់ចំណូល ដែលបង្កជាបញ្ហាប្រឈមមួយក្នុងការឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)។ | ការបញ្ចូលបញ្ហាសង្គមដូចជា របរចិញ្ចឹមជីវិត យេនឌ័រ ឧស្សាហកម្មធុនតូច សុខភាព និងសុវត្ថិភាពរបស់កម្មករ ។ល។ ទៅក្នុងគំនិតផ្តួចផ្តើមរបស់ SPP គឺមានសារៈសំខាន់សម្រាប់ត្រួសត្រាយផ្លូវទៅបញ្ចប់ភាពក្រីក្រ និងសម្រាប់កំណើនប្រកបដោយសមធម៌ស្របតាមគោលគំនិតនៅក្នុងក្របខណ្ឌ CSDG ដែលសន្យាថា "មិនទុកនរណាម្នាក់ចោលនៅក្រោយ"។ |
| | ទម្លាប់អនុវត្តលទ្ធកម្មសាធារណៈដែលមានស្រាប់ខ្វះការផ្តោតលើលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវស្តីពីនិរន្តរភាព ដែលនាំឱ្យកើតបន្ទុកលើការចំណាយសាធារណៈ។ | គួរផ្តល់អាទិភាពដល់គម្រោងដែលបង្កើតតម្លៃជាប្រាក់ ការសន្សំការចំណាយ និងនិរន្តរភាពរយៈពេលវែង។ អាទិភាពនេះគួរតែត្រូវបានពង្រីកលើសពីសេវាកម្ម និងទំនិញ ដើម្បីបញ្ចូលការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ។ |

9 poverty line declined from 33.8 percent in 2009 to 17.8 percent in 2019/20 https://www.worldbank.org/en/news/speech/2022/11/28/cambodia-poverty-assessment-opening-remarks-by-maryam-salim-world-bank-country-manager-for-cambodia

| PEST | កត្តាសំខាន់ៗ | ការពិចារណា |
|---|---|---|
| កត្តាសង្គម | ការរីកដុះដាលខ្លាំងនៃនគរូបនីយកម្ម ជាពិសេសក្នុងចំណោមប្រជាជនវ័យក្មេង ខណៈដែលពលរដ្ឋភាគច្រើនបន្តរស់នៅក្នុងតំបន់ជនបទ។ | រាជរដ្ឋាភិបាលអាចផ្តល់អាទិភាពដល់គំនិតផ្តួចផ្តើម SPP សម្រាប់គ្រួសារដែលមានចំណូលទាប សហគមន៍ជនជាតិដើមភាគតិច ជនបទ និងការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព។ |
| | ការផ្តល់កិច្ចគាំពារសង្គម ( ឧ. គ្រោងការណ៍ ID-Poor ) សម្រាប់ក្រុមងាយរងគ្រោះនៅមានកម្រិតនៅឡើយ។ | ការលើកកម្ពស់ប្រសិទ្ធផលធនធាន និងការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព ដោយបញ្ចូលបច្ចេកវិទ្យាទៅក្នុងប្រព័ន្ធលទ្ធកម្ម ដើម្បីកែលម្អសេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋ។ |
| | ការដោះស្រាយវិសមភាពយេនឌ័រនៅក្នុងទីផ្សារការងារ សហគ្រាសធុនតូច និងមធ្យម និងតំណាងនៅរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ការលើកកម្ពស់អាជីវកម្ម និងសហគ្រាសដែលគ្រប់គ្រងដោយស្ត្រី រួមទាំងសហគ្រាសធុនតូច និងមធ្យម និងអ្នកផលិតក្នុងស្រុក តាមរយៈការពង្រឹងសិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រី និង SPP តាមគោលដៅសម្រាប់ជាប្រយោជន៍ ដល់ស្ត្រី និងក្មេងស្រី។ |
| | កង្វះលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងអនាម័យនៅតំបន់ជនបទ បង្កបញ្ហាប្រឈមដល់ការរីកចម្រើនរបស់កម្ពុជា។ | ការធ្វើអាទិភាពលើសកម្មភាពផ្នែកទឹកស្អាត បង្គន់ និងអនាម័យ និងការកែលម្អគុណភាព និងលទ្ធភាពទទួលបានការអប់រំ។ |
| កត្តាបច្ចេកវិទ្យា | ច្បាប់លទ្ធកម្មសាធារណៈបញ្ចូលលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្របតាមគំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំបង្កើតប្រព័ន្ធលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ | ការធ្វើសមាហរណកម្មបច្ចេកវិទ្យានវានុវត្តន៍ទៅក្នុងប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកសម្រាប់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅគ្រប់កម្រិត។ |
| | ចាប់តាំងពីមានការរាតត្បាតជំងឺកូវីដ-១៩ មក វិស័យសាធារណៈ វិស័យឯកជន និងអង្គការសង្គមស៊ីវិល បានងាកទៅធ្វើប្រតិបត្តិការតាមអនឡាញច្រើន ដោយបង្កើតជាឱកាសសម្រាប់ការបញ្ចូលដំណោះស្រាយ ICT ដើម្បីឆ្លើយតបបញ្ហាប្រឈមគោលនយោបាយ ដូចជា ថវិកា ការធ្វើផែនការ លទ្ធកម្ម និងការកសាងសមត្ថភាពបច្ចេកវិទ្យា។ | មានសក្តានុពលសម្រាប់ពង្រីកដំណោះស្រាយតាមបច្ចេកវិទ្យានៅទូទាំងប្រព័ន្ធក្នុងប្រទេសទាំងមូល រួមទាំងហិរញ្ញវត្ថុ ការគ្រប់គ្រងលទ្ធកម្ម និងថ្នាលចែករំលែកចំណេះដឹង។ |
| | ការរីកចម្រើននៃបច្ចេកវិទ្យាប្រកបដោយនិរន្តរភាព រួមទាំងបច្ចេកវិទ្យាបៃតង កំពុងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងបរិស្ថាន ដែលជំរុញឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកនិរន្តរភាព។ | គួរពង្រីកវិសាលភាពបច្ចេកវិទ្យាដែលមានតម្លៃទាប ហើយភ្ជាប់វាយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់និរន្តរភាពនៅតាមវិស័យផ្សេងៗគ្នា។ |

# ឧបសម្ព័ន្ធ ខ. បញ្ជីឈ្មោះស្ថាប័ន/ទីភ្នាក់ងារ ដែលបានជួបពិគ្រោះយោបល់

| No. | Institutions/Agencies | Name | # Respondents | Date Interviewed |
|---|---|---|---|---|
| | | Government | | |
| 1 | Key Interview with the Department of Green Economy, MoE | Dr. Vanthoeun Keo; Ms. Sok Sreymom | 2 (1F) | Thursday, September 7, 2023 |
| 2 | An inception meeting with MEF/GDPP | MEF/GDPP: H.E Huot Vathana, Mr. Sopheap<br>EUD: Mr. Davide Berton, Ms. Cristina Novio Garcia<br>SWITCH ASIA Team (5) | 8 (3F) | Tuesday, October 3, 2023 |
| 3 | Meeting with Ministry of Environment (MoE) | MoE: Her Excellency Lina Ngin, Secretary of State, Dr. Keo Vanthoeun<br>EUD Cambodia: Mr. Davide Berton, Ms. Cristina Novio Garcia<br>SWITCH ASIA: Dr. Zinaida Fadeeva, Ms. Elodie Maria-Sube, Ms. Anne, Mr. Sylvie, Mr. Sanjay, Mr. Kuntheara | 10 (6) | Friday, September 15, 2023 |
| 4 | Key interview with NCDD's Secretariat (Topic: Revision of PIM) | Mr. Kong Meng, deputy director of department of local affairs and supports to SNAs and his team | 4 (1F) | Friday, December 22, 2023 |
| 5 | Key interview with MEF/ GDPP | Mr. Sopheap, deputy director for the department of sub-national procurement management | 1 | This is scheduled for the second week of January 2024 |
| | | Development Partners & Civil Society Organizations | | |
| 1 | Meeting with GiZ regional Office (online) | Ms. Khun Wilasinee (GiZ Project lead), Mr. Kai Hoffman (GiZ Director), and SWITCH ASIA full team | 2 (1F) | Friday, September 8, 2023 |
| 2 | WebEx Meeting with EUD Cambodia and GIZ (Thailand & Cambodia) | EUD Cambodia: Mr. Davide Berton, Ms. Cristina Novio Garcia<br>GIZ: Ms.Wilasinee (GIZ BKK), Mr. Frank (GIZ ASEAN Team, KH)<br>SWITCH-Asia: Mr. Sanjay Kumar (SNKE), Ms. Elodie Maria-Sube (SWITCH-Asia PSC), and Ms. Lunchakorn Prathumratana (JNKE, SWITCH-Asia PSC), Mr. Kuntheara Tep (JNKE) | 8 (4F) | Thursday, September 28, 2023 |
| 3 | Country NKE meeting (Cambodia) | Sanjay Kumar (SNKE), Kuntheara TEP (JNKE), Elodie Maria-Sube (SWITCH-Asia PSC), and Lunchakorn Prathumratana (JNKE, SWITCH-Asia PSC) | 4 (2F) | Thursday, October 26, 2023 |

| No. | Institutions/Agencies | Name | # Respondents | Date Interviewed |
|---|---|---|---|---|
| 4 | Meeting with EUD Cambodia | EUD: Cristina NOVIO GARCIA ; Cheavy CHOUP; Davide BERTON ; SWITCH ASIA: Sanjay Kumar ( SNKE ), Sylvie Zaitra ( SNKE ), Kuntheara TEP ( JNKE ), Elodie Maria-Sube ( SWITCH-Asia PSC ), and Lunchakorn Prathumratana ( JNKE, SWITCH-Asia PSC ) | 7 ( 4 ) | Tuesday, September 5, 2023 |
| 5 | Key Interview with GIZ Cambodia Team | Mr. Keo Bunly, SCP Project's National Coordinator | 1 | Friday, September 15, 2023 |
| 6 | Country NKE meeting ( Cambodia ) | Sanjay Kumar ( SNKE ), Sylvie Zaitra ( SNKE ), Kuntheara TEP ( JNKE ), Elodie Maria-Sube ( SWITCH-Asia PSC ), and Lunchakorn Prathumratana ( JNKE, SWITCH-Asia PSC ) | 5 ( 3F ) | Monday, September 4, 2023 |
| 7 | Meeting with key DPs in Cambodia | EUD, WB, ADB, GIZ | 10 ( 4F ) | Monday, September 25, 2023 |
| 8 | Meeting with WB's Procurement Team ( F2F ) | Mr. Latharo Lor, Senior Procurement Specialist, & Ms. Wathana | 2 ( 1F ) | Tuesday, December 19, 2023 |
| 9 | Key interviews with MoE's National Focal Points | H.E Ngin Lina's successor, and Dr. Keo Vanthoeun | 2 | Wednesday, December 20, 2023 |
| 10 | Key interview with UNDP Cambodia | Mr. Heng Socheath, Assistant Country Director & Mr. Aphik Kovith, Procurement Specialist | 2 | Monday, December 18, 2023 |
| 11 | Key interviews with Transparency International Cambodia | Mr. Pech Pisey, Country Director, Mr. Narin, program director, and Mr. Bunrith, PFM ( public resource budget transparency, open budget ) | 3 | Monday, December 18, 2023 |
| Private Sector | | | | |
| 1 | Meeting ( F2F ) with EUROCHAM Cambodia | Mr. Massimiliano | 1 | Tuesday, December 19, 2023 |

សម្គាល់៖ សូមជ្រាបថា ភាគីពាក់ព័ន្ធផ្សេងទៀតមិនអាចចូលរួមនៅក្នុងដំណើរការព្រាងរបាយការណ៍នេះ ដោយសារជាប់មមាញឹកនៅក្នុងកាលវិភាគរបស់ពួកគេរហូតដល់ដំណាច់ឆ្នាំ២០២៣ ប៉ុន្តែពួកគេបានសម្តែងឆន្ទៈថានឹងរួមចំណែកនៅក្នុងកិច្ចការនេះនៅដើមឆ្នាំ២០២៤។

# ឧបសម្ព័ន្ធ គ. បញ្ជីសំណួរ

| សំណួរ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ | | | |
|---|---|---|---|---|
| | ការវិភាគ PEST | រដ្ឋាភិបាល | ដៃគូអភិវឌ្ឍន៍ & សង្គមស៊ីវិល | វិស័យឯកជន |
| **ទិដ្ឋភាពទូទៅ៖ បញ្ហាសង្គម បរិស្ថាន និងការប្រើប្រាស់គ្មាននិរន្តរភាព** | | | | |
| នៅក្នុងបរិបទនៃការអភិវឌ្ឍប្រកបដោយចីរភាព តើអង្គភាពរបស់អ្នកផ្តោតទៅលើវិស័យជាក់លាក់អ្វីខ្លះ ហើយតើវារួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាយ៉ាងដូចម្តេច ? | ✅ | ✅ | ✅ | ✅ |
| តើមានលក្ខណៈវិនិច្ឆ័យ ឬការគិតគូរជាក់លាក់អ្វីខ្លះនៅក្នុងលទ្ធកម្មសាធារណៈបៃតង/ប្រកបដោយនិរន្តរភាព ( G/SPP ) ដែលឆ្លើយតបទៅនឹងបញ្ហាសង្គម បរិស្ថាន និងការប្រើប្រាស់គ្មាននិរន្តរភាព ? | ✅ | ✅ | ✅ | ✅ |
| ក្នុងការឆ្លើយតបជារួមទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព តើមានផែនការ ឬអាទិភាពអ្វីខ្លះសម្រាប់ជំរុញឱ្យមានលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅកម្ពុជានៅពេលអនាគត ? | ✅ | ✅ | | |
| **ការពិនិត្យមើលគោលនយោបាយស្តីពីលទ្ធកម្មសាធារណៈបៃតង/ប្រកបដោយនិរន្តរភាពរបស់កម្ពុជា** | | | | |
| តើអ្វីទៅជានិយមន័យ និងការយល់ដឹងរបស់រាជរដ្ឋាភិបាលស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ? តើអ្នកអាចរៀបរាប់អំពីទិដ្ឋភាពទូទៅនៃគោលនយោបាយ ឬបទប្បញ្ញត្តិបច្ចុប្បន្នក្នុងការលើកកម្ពស់លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជាបានទេ ? ? | ✅ | ✅ | | |
| តើអ្វីខ្លះដែលជាគោលដៅ ឬគោលបំណងជាក់លាក់ ដែលរាជរដ្ឋាភិបាលគ្រោងនឹងធ្វើសកម្មដើម្បីឈានទៅសម្រេចឱ្យបាន តាមរយៈលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ? | ✅ | ✅ | | |
| តើអ្នកយល់យ៉ាងណាចំពោះក្របខ័ណ្ឌគោលនយោបាយថ្មីស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព/បៃតង ( S/GPP ) នៅកម្ពុជា ? | ✅ | ✅ | ✅ | ✅ |
| តើអ្នកជឿថាលក្ខណៈវិនិច្ឆ័យសម្រាប់លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ( SPP ) អាចត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការដេញថ្លៃ ឬកិច្ចសន្យា ប្រកបដោយប្រសិទ្ធភាពប៉ុនណា ? សូមផ្តល់ឧទាហរណ៍ | ✅ | | ✅ | ✅ |
| តើមានយន្តការ ឬឧបករណ៍អ្វីខ្លះហើយ ដើម្បីវាយតម្លៃផលប៉ះពាល់លើបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដោយសារការសម្រេចចិត្តផ្នែកលទ្ធកម្ម ? ? | ✅ | ✅ | | |

| សំណួរ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ | | | |
|---|---|---|---|---|
| | ការវិភាគ PEST | រដ្ឋាភិបាល | ដៃគូអភិវឌ្ឍន៍ & សង្គមស៊ីវិល | វិស័យឯកជន |
| តើអ្នកមានអ្នកឯកទេស ឬអ្នកជំនាញផ្នែកលទ្ធកម្មដែលមានជំនាញក្នុងការលើកកម្ពស់ និងការអនុវត្តលក្ខណៈវិនិច្ឆ័យ G/SPP ដើម្បីជួយសម្រួល និងពន្លឿនដំណើរការអនុវត្ត ដែរឬទេ ? | | ✅ | ✅ | ✅ |
| ឧត្តមានុវត្តន៍ និងមេរៀនដកពិសោធន៍ | | | | |
| មេរៀនដកពិសោធន៍ និងជោគជ័យសំខាន់ៗនៅកម្ពុជា៖<br>• តើអ្វីខ្លះដែលជាមេរៀនដកពិសោធន៍សំខាន់ៗ ?<br>• តើមេរៀនទាំងនេះអាចយកទៅប្រើបានដូចម្តេចខ្លះនៅក្នុងបរិការណ៍នៃប្រទេសកម្ពុជា ?<br>• តើមានអ្វីខ្លះដែលជាជោគជ័យ ឬជាកត្តានាំឱ្យមានជោគជ័យសំខាន់ៗរបស់អ្នក ? | | ✅ | ✅ | ✅ |
| និន្នាការរបស់ G/SPP ទៅថ្ងៃមុខនៅកម្ពុជា៖<br>• តើអ្វីខ្លះទៅជាបញ្ហាប្រឈមចំពោះមុខដែលអាចនឹងកើតឡើងនៅក្នុងការជំរុញ G/SPP នៅប៉ុន្មានឆ្នាំខាងមុខ ?<br>• តើអ្នកយល់ថាអ្វីខ្លះទៅដែលជាដំណោះស្រាយ សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ ?<br>• តើអង្គភាពរបស់អ្នក និងដៃគូផ្សេងទៀត អាចធ្វើដូចម្តេចខ្លះ ដើម្បីរួមចំណែកដល់ និងសហការគ្នា ក្នុងការជំរុញលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅកម្ពុជា ? | | ✅ | ✅ | ✅ |
| កិច្ចខិតខំប្រឹងប្រែងក្នុងការរួមចំណែកដល់ G/SPP នៅកម្ពុជា៖<br>• តើដៃគូអភិវឌ្ឍន៍ រាប់ទាំងអង្គការរបស់អ្នកផង និងអង្គការសង្គមស៊ីវិល បានរួមចំណែកដូចម្តេចខ្លះ ដល់ការលើកកម្ពស់លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពនៅកម្ពុជា ?<br>• តើមានឧទាហរណ៍ជាក់លាក់អ្វីខ្លះអំពីផលឥទ្ធិពលនៃកិច្ចខិតខំទាំងនោះ ដែលអ្នកអាចចែករំលែកបាន ? | ✅ | | ✅ | ✅ |
| តើរាជរដ្ឋាភិបាលធ្វើដូចម្តេចខ្លះ ដើម្បីលើកទឹកចិត្ត និងជួយដល់អ្នកផ្គត់ផ្គង់ ឬ អ្នកម៉ៅការ ក្នុងការផ្គត់ផ្គង់ផលិតផល ឬសេវាកម្មប្រកបដោយនិរន្តរភាព ? | | ✅ | | |

| សំណួរ | ការចូលរួមរបស់ភាគីពាក់ព័ន្ធ | | | |
|---|---|---|---|---|
| | ការវិភាគ PEST | រដ្ឋាភិបាល | ដៃគូអភិវឌ្ឍន៍ & សង្គមស៊ីវិល | វិស័យឯកជន |
| យោបល់អំពីឧបករណ៍ G/SPP, ធនធាន និងការបណ្តុះបណ្តាល/កសាងសមត្ថភាព៖<br>• តើជំនួយបច្ចេកទេស ឬការគាំទ្រដល់ការកសាងសមត្ថភាពបែបណាខ្លះ ដែលអ្នកយល់ថាគួរតែមានសម្រាប់ពង្រីកទម្លាប់អនុវត្តន៍ G/SPP ថែមទៀត ?<br>• តើមានឧបករណ៍ ធនធាន ឬកម្មវិធីបណ្តុះបណ្តាលជាក់លាក់អ្វីខ្លះ ដែលអ្នកយល់ថាគួរតែមាន ដើម្បីជួយភ្នាក់ងាររដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធផ្សេងទៀត ក្នុងការលើកកម្ពស់ និងអនុវត្ត G/SPP ? | ✅ | ✅ | ✅ | ✅ |
| តួនាទីជាតួអង្គមួយនៅក្នុង G/SPP នៅកម្ពុជា៖<br>• ដោយឃើញថាមានតួអង្គជាច្រើនពាក់ព័ន្ធនៅក្នុងរឿងនេះ តើតួនាទីអ្វីខ្លះដែលដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល តួយ៉ាងដូចជាអង្គការរបស់អ្នកជាដើម មាន ឬបំពេញនៅក្នុង G/SPP និង/ឬ តម្រូវការនានា ?<br>• តើវិធានការអ្វីខ្លះដែលគេអាចចាប់យក សម្រាប់បង្កើនកិច្ចសហការ និងចែករំលែកចំណេះដឹងនៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ដើម្បីលើកកម្ពស់លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ? | ✅ | ✅ | ✅ | ✅ |
| **សកម្មភាព និងគម្រោងសាកល្បងដែលគួរពិចារណាធ្វើ** | | | | |
| សកម្មភាពដែលគួរពិចារណាធ្វើ៖<br>តើមានសកម្មភាព ឬអនុសាសន៍អ្វីជាក់លាក់ខ្លះ ដែលអ្នកស្នើឡើងបាន ដើម្បីលើកកម្ពស់ និងជំរុញទម្លាប់អនុវត្តន៍ G/SPP នៅកម្ពុជា ? | | ✅ | ✅ | ✅ |
| គម្រោងសាកល្បងដែលមានសក្តានុពលអាចធ្វើបាននៅកម្ពុជា៖<br>• តើអង្គការម្ចាស់ជំនួយមួយណា ដែលកំពុងធ្វើការសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើការអនុវត្តលក្ខណៈវិនិច្ឆ័យ ឬ ការគិតគូរអំពី G/SPP នៅក្នុងដំណើរការដាក់ដេញថ្លៃ និងធ្វើកិច្ចសន្យា ?<br>• តើអ្វីទៅដែលនឹងអាចជាគម្រោងសាកល្បង G/SPP មុនគេ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ? | | ✅ | ✅ | ✅ |

# ឯកសារយោង


European Commission. 2015, December 2. Communication from the Commission to the European parliament, the Council, the European economic and social committee and the Committee of the regions: Closing the loop: An EU action plan for the circular economy (Report COM/2015/0614). https://eur-lex.europa.eu/legal-content/EN/TXT/?uri=CELEX:52015DC0614

Saouter, E., Biganzoli, F., Ceriani, L., Versteeg, D., Crenna, E., Zampori, L., Sala, S., Pant, R. 2020. Environmental footprint: Update of life cycle impact assessment methods: Ecotoxicity freshwater, human toxicity cancer, and non-cancer (Report EUR 29495 EN). Publications Office of the European Union. https://op.europa.eu/en/publication-detail/-/publication/8c487174-5f58-11ea-b735-01aa75ed71a1/language-en

Pasanen, P., Castro, R. 2019. Carbon Heroes Benchmark Program: Whole building embodied carbon profiling. IOP Conference Series: Earth and Environmental Science. DOI:10.1088/1755-1315/323/1/012028

European Commission. Dutch Building Act (Bouwbesluit) 2012. PDF.

European Commission. Energy Efficiency Financial Institutions Group (EEFIG). https://ec.europa.eu/eefig/index_en

European Parliament. EU Regulation No. 517/2014 of the European Parliament and of the Council on Fluorinated Greenhouse Gases and repealing Regulation (EC) No. 842/2006. 2014.

European Parliament, Council of the European Union. Energy Performance of Buildings Directive 2010/31/EU. 2010.

Government of the Kyrgyz Republic. Law of the Kyrgyz Republic of June 8, 1998 No. 77: About Oil and Gas.

switchasia

Funded by
the European Union

www.switch-asia.eu

EU SWITCH-Asia Programme
@EUSWITCHAsia

SWITCH-Asia
@SWITCHAsia

SWITCH-Asia Official
@switch-asia-official